# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ




# របាយការណ៍បូកសរុបលទ្ធផល
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០១៩
# និងទិសដៅអនុវត្ត ឆ្នាំ ២០២០

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ

# អារម្ភកថា



*សម្តេច ឯកឧត្តម លោកជំទាវ*
*លោក លោកស្រី បងប្អូនជនរួមជាតិ ជាទីគោរព រាប់អាន*

ក្នុងឆ្នាំ២០១៩នេះ ព្រះរាជាណាចក្រកម្ពុជា បាន និងកំពុងខ្វាយខ្វល់អំពីជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ខិតខំរក្សាស្ថេរភាពនៃកំណើនសេដ្ឋកិច្ចដែលកំពុងតែបោះជំហានទៅមុខយ៉ាងស្វាហាប់ ឆ្លងកាត់ព្យុះព្យោមានៃវលកសេដ្ឋកិច្ចពិភពលោក ខិតខំអនុវត្តកម្មវិធីកំណែទម្រង់ជាតិដើម្បីលើកកម្ពស់ការទទួលបានសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋពីគ្រប់សេវាសាធារណៈដែលរាជរដ្ឋាភិបាលផ្តល់ជូន ។ តែទន្ទឹមនឹងនោះ ស្ថានភាពក្នុងតំបន់ ក៏ដូចជានៅក្នុងពិភពលោក បាន និងកំពុងមានការប្រែប្រួលជាខ្លាំង នាចុងឆ្នាំ២០១៩ និងនៅដើមឆ្នាំ២០២០នេះ អាស្រ័យដោយសង្គ្រាមពាណិជ្ជកម្ម របស់ប្រទេសមហាអំណាច និងបន្ថែមដោយជម្ងឺរាតត្បាតដ៏កាចសាហាវ ដែលមានឈ្មោះថា កូរ៉ូណា ឬ ខូវិដ-១៩ ។ ស្ថានភាពនេះ បានជះឥទ្ធិពលដ៏ចម្លែក ដែលធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅ រួមទាំងការធ្លាក់ចុះយ៉ាងគំហុកនូវកំណើនសេដ្ឋកិច្ចគ្រប់ប្រទេស ការព្រួយបារម្ភអំពីសុវត្ថិភាពស្បៀង បញ្ហាសុខភាព សុវត្ថិភាព អសន្តិសុខ រហូតដល់ការផ្លាស់ប្តូរទម្លាប់ក្នុងការរស់នៅ និងរបៀបរបបការងារជាដើម ។

បើស្ថានភាពនេះ នៅតែអូសបន្លាយ អ្វីៗ នឹងមានការប្រែប្រួលកាន់តែអាក្រក់ ហើយប្រទេសជាច្រើននៅទូទាំងពិភពលោក នឹងប្រឈមភាពក្រីក្រលំបាកជាថ្មី ។

តាមពិតទៅ ក្នុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជាយើង ក៏ដូចជាប្រទេសពាក់ព័ន្ធនានា បានធ្វើការងារយ៉ាងច្រើន សំដៅដោះស្រាយបញ្ហា កាត់បន្ថយភាពរងគ្រោះដោយអំពើជួញដូរ និងការកេងប្រវ័ញ្ចទាំងឡាយ ដែលនាំឲ្យមនុស្សបាត់បង់នូវសិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូរ និងតម្លៃជាមនុស្ស។ ទាំងក្រសួងស្ថាប័ននៅថ្នាក់ជាតិ ទាំងអាជ្ញាធរ មន្ទីរ អង្គភាព នៅថ្នាក់ក្រោមជាតិ ក៏ដូចជាអង្គការដៃគូជាតិ និងអន្តរជាតិ បានរួមគ្នាបំពេញភារកិច្ច យ៉ាងសកម្មទៅតាមការគ្រោងទុក និងទទួលបានលទ្ធផលយ៉ាងល្អប្រសើរ ។ ខ្ញុំសូមឆ្លៀតឱកាសនេះ ថ្លែងនូវអំណរគុណ និងការកោតសរសើរ ចំពោះគ្រប់ការចូលរួម ដោយប្រឹងប្រែង មិនខ្លាចនឿយហត់ របស់ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន អង្គភាព ក៏ដូចជាមន្ត្រីជំនាញគ្រប់លំដាប់ថ្នាក់ដែលបានរួមសហការគ្នាយ៉ាងល្អប្រសើរ បំពេញភារកិច្ច ក្នុងការបង្ការទប់ស្កាត់ ការអនុវត្តច្បាប់ដែលរួមមានការបង្ក្រាប និងការផ្តន្ទាទោស និងការជួយជនរងគ្រោះ បានយ៉ាងល្អប្រសើរ ។ ការងារបង្ការទប់ស្កាត់ បានបង្កើនសកម្មភាព ដោយចាត់ទុកជាអតិភាពចម្បង ដើម្បីបញ្ចៀសពីគ្រោះថ្នាក់ដែលត្រូវបានធ្វើឡើងតាមគ្រប់រូបភាព ។ ខ្ញុំក៏សូមកោតសរសើរផងដែរ ចំពោះក្រុមការងារទាំងប្រាំមួយ ដែលបានខិតខំសហការគ្នាទាំងនៅក្នុងស្រុក ទាំងជាមួយប្រទេសពាក់ព័ន្ធ ។

តែទន្ទឹមនឹងស្ថានភាពថ្មីនេះ យើងបារម្ភយ៉ាងខ្លាំងចំពោះស្ថានភាពរស់នៅ បញ្ហាសុខភាពរបស់ពលករ និងការប្រាស្រ័យទាក់ទងរវាងពលករ និងគ្រួសារ ដែលនៅក្នុងប្រទេស បន្ថែមលើការកេងប្រវ័ញ្ច និងអំពើជួញដូរមនុស្សផងដែរ ។

ខ្ញុំសង្ឃឹម និងជឿជាក់ថា សមាជិកសមាជិកានៃគណៈកម្មាធិការជាតិ គណៈកម្មាធិការថ្នាក់ក្រោមជាតិទាំងអស់ នឹងនៅតែបន្តសកម្មភាព និងខិតខំជម្នះឧបសគ្គគ្រប់បែបយ៉ាង ដើម្បីការពារប្រជាពលរដ្ឋយើង ក៏ដូចជាមនុស្សទាំងឡាយពីភាពរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព ក៏ដូចជាទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ ដែលឆ្លងកាត់ព្រំដែន ។

សូមបងប្អូនជនរួមជាតិ និងជនបរទេសទាំងអស់ ដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជា រួមគ្នាថែទាំសុខភាព គោរពច្បាប់កម្ពុជា និងជៀសឲ្យឆ្ងាយពីបទល្មើសផ្សេងៗ ជាពិសេស ការចូលរួមក្នុងសកម្មភាពជួញដូរមនុស្ស ដើម្បីការពារខ្លួនពីការដាក់ទោសទណ្ឌ និងដើម្បីរួមចំណែកការពារសុវត្ថិភាពប្រជាពលរដ្ឋ និងមនុស្សទូទៅ ពីភាពរងគ្រោះដោយអំពើជួញដូរមនុស្ស ។

ជាទីបញ្ចប់នេះ ខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ បារមី វត្ថុសក្តិសិទ្ធ មេត្តាប្រោះព្រំ ផ្តល់ភាពសុខដុមរម្យនា និងជៀសវាងបានពីភ័យន្តរាយ ក្នុងតំណាក់កាលដ៏លំបាកនេះកុំបីខាន និងសូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ថ្ងៃ ព្រហស្បតិ៍ ៥រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០

**ប្រធាន គ.ជ.ប.ជ**

**សម្តេចក្រឡាហោម ស ខេង**

# មាតិកា

I. ស្ថានភាពទូទៅ......1
II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ...... 3
ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ...... 3
ក.១. ការងារកសាងច្បាប់ ...... 3
ក.២. សន្ធិសញ្ញា ...... 3
ក.៣. អនុស្សរណៈនៃការយោគយល់គ្នា និងគោលនយោបាយ...... 3
ក.៤. លិខិតបទដ្ឋានគតិយុត្ត ...... 5
ខ. ការបង្ការ ទប់ស្កាត់...... 6
ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង...... 6
ខ.១.១. ការផ្សព្វផ្សាយជាសាធារណៈ......6
ខ.១.១.១. ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ......6
ខ.១.១.២. វេទិកាអន្តរសាសនា......7
ខ.១.១.៣. វេទិកាសាធារណៈ និងភូមិ-ឃុំមានសុវត្ថិភាព ......7
ខ.១.១.៤. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ ......9
ខ.១.២. ការផ្សព្វផ្សាយ តាមរយៈឧបករណ៍ផ្សព្វផ្សាយ ...... 11
ខ.១.៣. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និង ប្រព័ន្ធអេឡិចត្រូនិក ...... 12
ខ.១.៤. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា...... 14
ខ.២. ការបង្ការ ទប់ស្កាត់ តាមវិធានការជំនាញ ......17
ខ.២.១. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ...... 17
ខ.២.២. វិធានការជំនាញអន្តោប្រវេសន៍ ...... 19
ខ.២.៣. វិធានការគ្រប់គ្រងស្ថិតិៈ បច្ចុប្បន្នភាពចំណាកស្រុក ...... 19
ខ.២.៤. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ ... 21
ខ.២.៥. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរូបភាពអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ......22
ខ.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ...... 22
ខ.៤. ការលើកកម្ពស់ជីវភាព...... 24

ខ.៥. ការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន ............ 23
ខ.៦. ការផ្តល់ប័ណ្ណព្រំដែនដល់ប្រជាជនចល័តឆ្លងកាត់ព្រំដែន............ 23
គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស ............ 24
គ.១. ការងារអនុវត្តច្បាប់ ............ 24
គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ ............25
១. ករណីអំពើជួញដូរមនុស្ស ............25
២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ ............25
គ.១.២. ការកសាងសំណុំរឿង និងជនសង្ស័យបទល្មើសជួញដូរមនុស្ស បញ្ជូនទៅតុលាការ........26
គ.២. កិច្ចការយុត្តិធម៌ ............ 24
គ.២.១. លទ្ធផលចំណាត់ការផ្តន្ទាទោស ............28
១. ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ............28
២. ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត ............28
៣. ដំណាក់កាលចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត ............28
គ.៣. ការដោះស្រាយករណីវិវាទរវាងពលករទេសន្តរប្រវេសន៍ និងបណ្តាក្រុមហ៊ុននានា ............ 29
ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ ............ 29
ឃ.១. ការទទួល ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន............ 29
ឃ.១.១. ការទទួលសាកសពបញ្ជូនត្រឡប់............32
ឃ.២. ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ............ 32
ឃ.៣. ការធ្វើមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ ............ 33
III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល............34
ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា ............ 34
ក.១. ការងារបណ្តុះបណ្តាល ............ 34
ក.១.១. ការបណ្តុះបណ្តាលក្នុងប្រទេស............34
ក.១.២. ការបណ្តុះបណ្តាលក្រៅប្រទេស............35
ក.២. សិក្ខាសាលា ............ 35
ក.២.១. សិក្ខាសាលាក្នុងប្រទេស............35
ក.២.២. សិក្ខាសាលាក្រៅប្រទេស............36

ខ. សន្និសីទ កិច្ចប្រជុំ សិក្ខាសាលា ទស្សនកិច្ច និងជំនួបពិភាក្សាការងារ ........................................ 37
ខ.១. សន្និសីទថ្នាក់ជាតិ និងអន្តរជាតិ .......................................................................................... 37
ខ.២. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស ..................................................................................... 38
ខ.៣. ការទទួលជួបពិភាក្សាការងារ ..........................................................................................47
ខ.៤. វេទិកានៅក្រៅប្រទេស ....................................................................................................49
ខ.៥. ទស្សនកិច្ចក្នុងប្រទេស និងក្រៅប្រទេស ..................................................................................49
ខ.៦. ការងារសម្របសម្រួល ......................................................................................................49
IV. ការសន្និដ្ឋានវាយតម្លៃ.......................................................................................................................49
ក .ចំណុចខ្លាំង.......................................................................................................................... 50
ខ. ចំណុចខ្វះខាត ឬភាពប្រឈម....................................................................................................... 50
គ. សំណូមពរ ..............................................................................................................................51
V. ទិសដៅ ឆ្នាំ ២០២០ .......................................................................................................................51
- ឧបសម្ព័ន្ធ
- កម្រងរូបភាព

# របាយការណ៍បូកសរុប
# សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៩ និងទិសដៅ ឆ្នាំ២០២០

## I. ស្ថានភាពទូទៅ

ក្រោមម្លប់នៃសន្តិភាព ព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងធ្វើដំណើរឆ្ពោះទៅកាន់ការអភិវឌ្ឍន៍រីកចម្រើនឥតឈប់ឈរ បើទោះបីជាប្រទេសមួយចំនួនក្នុងពិភពលោក កំពុងប្រឈមនឹងភាពវឹកវរចលាចល ដោយការប្រកួតប្រជែងយ៉ាងស្រួចស្រាលរវាងនយោបាយពហុប៉ូលនិយម និងគាំពារនិយម បញ្ហាភេរវកម្ម អសន្តិសុខ ឬចម្បាំងរាំងដល់ក៏ដោយ ។ សង្គ្រាមពាណិជ្ជកម្មរវាងមហាអំណាចចិន និងអាមេរិកបានជះឥទ្ធិពលជាអវិជ្ជមានដល់សេដ្ឋកិច្ចពិភពលោក កួបផ្សំនឹងការផ្ទុះឡើងនូវជម្ងឺឆ្លងដ៏សាហាវនៃវីរុសថ្មី កូរ៉ូណា ឬ ខូវីត ១៩ (Covid-19) រឹតតែធ្វើឲ្យមានផលប៉ះពាល់កាន់តែខ្លាំងដល់សេដ្ឋកិច្ចនៃបណ្តាប្រទេសជាច្រើនក្នុងសាកលលោក ដែលពឹងផ្អែកទៅលើលំហូរពាណិជ្ជកម្ម ផ្គត់ផ្គង់ទំនិញ និងទេសចរណ៍ពីប្រទេសចិន ។ ដោយឡែក ព្រះរាជាណាចក្រកម្ពុជា ក៏រងផលប៉ះពាល់មួយផ្នែកពីសម្ពាធនយោបាយអន្តរជាតិ ដែលចាប់បង្ខំកម្ពុជាឲ្យអនុវត្តដោយបំពានលើអធិបតេយ្យភាពជាតិ រហូតដល់ឈានទៅលុបការអនុគ្រោះពន្ធនាំចេញលើមុខទំនិញមួយចំនួនទៅក្នុងសហភាពអឺរ៉ុប ក្នុង «ប្រព័ន្ធអនុគ្រោះពន្ធលើមុខទំនិញគ្រប់មុខ ក្រៅពីអាវុធយុទ្ធភ័ណ្ឌ»(EBA) តែអាស្រ័យដោយភាពវៃឆ្លាតប្រកបដោយបញ្ញាញាណរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី ក្នុងការដោះស្រាយបញ្ហាចំពោះមុខ សម្ពាធនេះ មិនបានធ្វើឲ្យកម្ពុជាខូចខាតសេដ្ឋកិច្ចធ្ងន់ធ្ងរឡើយ ។ អាស្រ័យដោយការផ្គត់ផ្គង់វត្ថុធាតុដើម ពីប្រទេសចិនមានការយឺតយ៉ាវដោយសារតែការវាយលុករបស់ជម្ងឺ ខូវីដ-១៩ បានធ្វើឲ្យរោងចក្រមួយចំនួន ត្រូវបង្ខំចិត្តបិទទ្វារ ហើយត្រូវរំសាយកម្មករ មួយរយៈ ដែលក្នុងនោះ រាជរដ្ឋាភិបាល បានធ្វើសម្បទាន (២០%) ជាមួយថៅកែរោងចក្រ (៤០%) ដើម្បីផ្តល់ថវិកាឧបត្ថម្ភកម្មករ កម្មការិនី ចំនួន៦០ភាគរយនៃប្រាក់បៀវត្សរ៍គោល និងបន្តផ្តល់ការបណ្តុះបណ្តាល និងឱកាសការងារថ្មីជាជម្រើស ដើម្បីកាត់បន្ថយការសម្រេចចិត្តធ្វើចំណាកស្រុកដោយប្រថុយប្រថាន ។

រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តការប្តេជ្ញាចិត្តខ្ពស់ ដោះស្រាយរាល់បញ្ហាប្រឆាំងរាល់បទល្មើសដែលកើតឡើងលើប្រជាពលរដ្ឋ រួមទាំងអំពើជួញដូរមនុស្សដែលជាបទឧក្រិដ្ឋបំផ្លាញសេចក្តីថ្លៃថ្នូរ សិទ្ធិសេរីភាព រហូតដល់អាយុជីវិតមនុស្សជាជនរងគ្រោះ ក្នុងនោះមានគ្រប់វ័យ តាំងពីទារក កុមារ យុវវ័យ ស្ត្រី បុរស និងមនុស្សចាស់ តាមរយៈអំពើកេងប្រវ័ញ្ច និងហិង្សាលើផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទយ៉ាងធ្ងន់ធ្ងរ រហូតក្លាយជាទាសភាពសម័យទំនើបគួរឲ្យស្អប់ខ្ពើម ។

រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី **នៃព្រះរាជាណាចក្រកម្ពុជា** បានប្តេជ្ញាចិត្តខ្ពស់ ប្រឆាំងការជួញដូរមនុស្ស ដែលជាបទឧក្រិដ្ឋបំផ្លាញមនុស្សជាតិ និងបានដាក់ចេញនូវគោលនយោបាយការងារ គោលនយោបាយគាំពារសង្គម លើកទឹកចិត្តអ្នកវិនិយោគក្នុងប្រទេស និងទាក់ទាញអ្នកវិនិយោគពីបរទេស ដើម្បីបង្កើនការងារជូនពលរដ្ឋក្នុងស្រុកបានរាប់លាននាក់ ក៏ដូចជាបើកច្រកឲ្យបញ្ជូនពលករខ្មែរទៅធ្វើការងារស្របច្បាប់ និងមានសុវត្ថិភាពនៅក្រៅប្រទេស ។

បទល្មើសជួញដូរមនុស្ស នៅតែបន្តកើតមានតាមរូបភាពថ្មីៗ តែត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាប ជាបន្តបន្ទាប់ អាស្រ័យដោយមានការខិតខំប្រឹងប្រែង និងមានកិច្ចសហការគ្នាបានល្អ រវាងក្រសួង ស្ថាប័ន អង្គភាពសមាជិកនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រួមទាំងលេខាធិការដ្ឋាន នៃគណៈកម្មាធិការថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) និងអង្គការដៃគូទាំងឡាយ ដែលមានសកម្មភាព និងគោលដៅរួមគ្នា។ ការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជា ប្រមាណមួយលានប្រាំបីម៉ឺននាក់ គឺជាលទ្ធផលជោគជ័យ សម្រាប់ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលនៃ ប្រទេសទាំងពីរ កម្ពុជា ថៃ ។ ទោះបីជាយ៉ាងនេះក្តី ក្នុងឆ្នាំ២០១៩ ក៏នៅមានពលករដែលមិនទាន់មានឯកសារច្បាប់ ត្រូវបានសមត្ថកិច្ចថៃ រកឃើញ ផាកពិន័យ ឃាត់ខ្លួន ឬបញ្ជូនត្រឡប់ជារៀងរាល់ថ្ងៃ។ ជនរងគ្រោះមួយចំនួន ត្រូវបានរកឃើញថា កាន់ឯកសារមិនត្រឹមត្រូវ ឬក្លែងបន្លំ និងមិនអាចទទួលផលប្រយោជន៍ស្របច្បាប់បាន ។ នៅមានជនបោកប្រាស់ ដែលបានប្រើរូបភាព ជាភ្នាក់ងារមានសមត្ថកិច្ច ផ្តល់ឯកសារក្លែងក្លាយ ជាអ្នករត់ការផ្តល់ភាពស្របច្បាប់ ឬឃោសនាជាអ្នកជ្រើសរើស ដើម្បីបញ្ជូនទៅរកការងារក្រៅប្រទេស ហើយប្រមូលកម្រៃសេវាពីពលករជាដើម ។ សមត្ថកិច្ចថៃ និងកម្ពុជា បានស្រាវជ្រាវចាប់ខ្លួន និងផ្តន្ទាទោសជាបន្តបន្ទាប់ ។

ដោយឡែក បទល្មើសថ្មី ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សឆ្លងដែន គឺអំពើពពោះជំនួស និងមេខ្យល់នាំស្ត្រីជាកូនក្រមុំឆ្លងដែនស្វែងរកគូស្រករនៅក្រៅប្រទេស ក៏ត្រូវបានរកឃើញ ទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលា និងនៅតែបន្តស្រាវជ្រាវ ថែមទៀត ។ ការកសាងច្បាប់ និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធ ក៏ត្រូវបានយកចិត្តទុកដាក់ ផងដែរ ដើម្បីបំពេញភាពខ្វះចន្លោះនៃច្បាប់ ។

ការផ្សព្វផ្សាយអប់រំ ដោយផ្ទាល់ និងដោយប្រយោល និងវិធានការបង្ការទប់ស្កាត់ភាពរងគ្រោះរបស់ប្រជាពលរដ្ឋពីអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាពនៅគ្រប់មូលដ្ឋាន ធ្វើឲ្យមនុស្សរាប់លាននាក់បានយល់ដឹង និងប្រុងប្រយ័ត្ន ។ ទោះបីជាយ៉ាងនេះក្តី ក៏នៅតែមានប្រជាពលរដ្ឋមួយចំនួន បន្តចាញ់បោកការឃោសនារបស់មេខ្យល់ និងត្រូវបានជនខិលខូចឆ្លៀតឱកាស ទាញយកផលចំណេញពីគ្រប់តំណាក់កាលនៃទេសន្តរប្រវេសន៍ ឲ្យធ្លាក់ចូលក្នុងភាពរងគ្រោះ ខូចខាត ទ្រព្យសម្បត្តិ បាត់បង់ផ្ទះសម្បែង បែកបាក់កូនចៅក្រុមគ្រួសាររហូតដល់ពិការ និងបាត់បង់អាយុជីវិត ក្នុងអំពើកេងប្រវ័ញ្ច គ្រប់រូបភាព ដែលហៅថា «ទាសភាពសម័យទំនើប» ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលនៅបន្តកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលដឹកនាំដោយ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិនានា ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីជំរុញសកម្មភាព និងកិច្ចប្រតិបត្តិការដោះស្រាយបញ្ហារួមគ្នា និងទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការងារកសាងច្បាប់

- **ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី** បានរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"។
- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងច្បាប់ ពីរគឺ ៖
  - ច្បាប់ស្តីពី "**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA)
  - ច្បាប់ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

#### ក.២. សន្ធិសញ្ញា

- **ក្រសួងយុត្តិធម៌**
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "**ការបញ្ជូនទណ្ឌិត**"។

#### ក.៣. អនុស្សរណៈនៃការយោគយល់គ្នា និងគោលនយោបាយ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)** បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គការដៃគូនានាដូចជា៖
  - អង្គការមូលនិធិដើម្បីកុមារ(Child Fund)កម្ពុជា ស្តីពី "សហគមន៍កុមារមេត្រីប្រឆាំងនឹងការជួញដូរកុមារ និងធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព" ចុះថ្ងៃទី០៧ ខែឧសភា ២០១៩ (២០១៩-២០២១)។
  - អង្គការសម្ព័ន្ធចាប់ដៃ (Chab Dai Coalition) ដែលរួមសហការជាមួយនឹងអង្គការ ERIKS ស្តីពី "ការចូលរួមសកម្មភាពបង្ការទប់ស្កាត់ អំពើជួញដូរកុមារ ការកេងប្រវ័ញ្ចផ្សេងៗ និងការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ" ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ (២០១៩-២០២៤)។
  - អង្គការដែនដីមនុស្ស-ហូឡង់ដ៏ប្រចាំកម្ពុជា (Terre Des Hommes) ស្តីពី "ការរួមគ្នាធ្វើសកម្មភាពបង្ការ ទប់ស្កាត់ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍" ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ (២០១៩-២០២១)។
  - អង្គការការីតាស ស្វីស (Caritas ) ស្តីពី "វិធីសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងការទប់ស្កាត់ ការការពារ និងសមាហរណកម្មចំពោះកុមារ យុវជន និងស្ត្រីវ័យក្មេងកម្ពុជាដែលងាយរងគ្រោះ/រងគ្រោះពីការចំណាកស្រុកអសុវត្ថិភាព និងការជួញដូរមនុស្ស" ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ (២០១៩-២០២១)។
- **ក្រសួងមហាផ្ទៃ** បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គការដៃគូនានា ដូចជា៖
  - អង្គការសកម្មភាពដើម្បីកុមារ (APLE) ស្តីពី "ការចូលរួមសកម្មភាពមនុស្សធម៌ក្នុងកិច្ចការការពារកុមារនៅព្រះរាជាណាចក្រកម្ពុជា" ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ (២០១៩-២០២៣)។
  - អង្គភាពការពារកុមារ (CPU) នៃអង្គការមូលនិធិកុមារកម្ពុជា ស្តីពី "ការរួមចំណែកនៅក្នុងសកម្មភាពមនុស្សធម៌ និងយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់អនីតិជន នៅព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ (២០១៩-២០២៣)។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
  - បានដឹកនាំគណៈប្រតិភូ ជាតំណាង ក្រសួង ស្ថាប័ន ស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃ និងអង្គការមិនមែនរដ្ឋាភិបាល ដោយមាន**ឯកឧត្តម ញឹក ឈណ្ណារ៉ា រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន**និងយុវនីតិសម្បទា និងខាងភាគីថៃដឹកនាំដោយ**ឯកឧត្តម ឧស្សនី តាំខ វ៉ានខិត អនុលេខាធិការអចិន្ត្រៃយ៍ ក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស** បានចុះហត្ថលេខាលើនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពី "ដំណើរការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស" នៅទីក្រុងបាងកក ប្រទេសថៃ នៅថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០១៩ ។
  - ចុះអនុស្សរណៈនៃកិច្ចព្រមព្រៀង (MOU) ជាមួយអង្គការចំនួន៨ គឺ៖ អង្គការមូនិធិហូលីបេប៊ី អង្គការ MRRCY Ministies Foundation អង្គការជំនួយស្ម័គ្រចិត្តដល់កុមារកម្ពុជា អង្គការសាលាសាធារណៈ និងសង្គមអេលីហ្សាបិត អង្គការមូលនិធិអូស្ត្រាលី-កម្ពុជា អង្គការតានី-ទស្សនៈវិស័យសំរាប់កម្ពុជា អង្គការសង្គ្រោះជោគវាសនាកម្ពុជា និងអង្គការស្បូននៃក្តីសង្ឃឹមនៅកម្ពុជា ដើម្បីជួយវិស័យសង្គមកិច្ច ជាពិសេសផ្តោតសំខាន់លើការជួយទៅដល់កុមាររងគ្រោះ ងាយរងគ្រោះ និងកុមារខ្វះខាត និងក្រីក្រនៅទូទាំងប្រទេស នៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៩។
- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន៖
  - ប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រីលើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី ស្តីពី "**ការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី**"។
  - បានចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពី កិច្ចសហប្រតិបត្តិការក្នុងវិស័យការងារ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។
  - បានប្រជុំក្រុមការងារបច្ចេកទេសថ្នាក់មន្ត្រីជាន់ខ្ពស់ កម្ពុជា ថៃ ស្តីពីការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការវិស័យការងារ និងកិច្ចព្រមព្រៀងស្តីពី ការប្រើប្រាស់កម្លាំងពលកម្ម ដើម្បីពិនិត្យ និងដោះស្រាយបញ្ហានានា ដែលកើតឡើង និងទប់ស្កាត់រាល់បញ្ហាដែលអាចកើតមានជាយថាហេតុ។
  - បានប្រជុំក្រុមការងារបច្ចេកទេសថ្នាក់មន្ត្រីជាន់ខ្ពស់កម្ពុជា បង់ក្លាដេស ស្តីពីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាស្តីពី "កិច្ចសហប្រតិបត្តិការលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ" ជាពិសេសការផ្លាស់ប្តូរព័ត៌មាន និងការគ្រប់គ្រងពលករទេសន្តរប្រវេសន៍នៃប្រទេសទាំងពីរ។
  - ទីប្រឹក្សាទទួលបន្ទុកពលករប្រចាំស្ថានទូតកម្ពុជានៅប្រទេសថៃ បានសហការជាមួយក្រសួងការងារថៃ បន្តដាក់ចេញនូវកម្មវិធីសម្រាប់ចុះផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងដល់ពលករ តាមឃ្លាំមើលលក្ខខណ្ឌការងារនិងសួរសុខទុក្ខពលករជាប្រចាំ។
  - បានរៀបចំសន្និសិទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារសម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម (CLMTV) ក្រោមប្រធានបទ«**ការឆ្ពោះទៅកាន់កិច្ចគាំពារពលករទេសន្តរប្រវេសន៍ នៅក្នុងប្រទេស CLMTV និងកិច្ចសហប្រតិបត្តិការវិស័យរបបសន្តិសុខសង្គម**» ។

-បានចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការងារនិងសុខុមាលភាពនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ។

## ក.៤. លិខិតបទដ្ឋានគតិយុត្ត

### • ថ្នាក់ជាតិ

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖**

-ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពី «របបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត» ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

-បានចេញសេចក្តីសំរេច ស្តីពីការតែងតាំង និងផ្លាស់ប្តូរសមាសភាពនៃក្រុមការងារការពារជនរងគ្រោះក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

▪ **ក្រសួងអប់រំយុវជន និងកីឡា**

-បាននឹងកំពុងរៀបចំមេរៀន ស្តីពីការបង្ការ ទប់ស្កាត់ នូវរាល់ទម្រង់នៃអំពើជួញដូរមនុស្ស សម្រាប់បង្ហាត់បង្រៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យនៅទូទាំងប្រទេស។

-បានចេញសេចក្តីសំរេច ស្តីពីការតែងតាំង និងផ្លាស់ប្តូរសមាសភាពនៃក្រុមការងារបង្ការ ទប់ស្កាត់ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចេញសេចក្តីសំរេច ស្តីពីការតែងតាំង និងផ្លាស់ប្តូរសមាសភាពនៃក្រុមការងារទេសន្តរប្រវេសន៍ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

▪ **ក្រសួងកិច្ចការនារី** បានចេញសេចក្តីសំរេច ស្តីពីការតែងតាំង និងផ្លាស់ប្តូរសមាសភាពនៃក្រុមការងារសហប្រតិបត្តិការអន្តរជាតិ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

▪ **ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ** បានចេញសេចក្តីសំរេច ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីពិនិត្យផ្តល់យោបល់លើការសិក្សាជ្រាវជ្រាវការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ិនធឺណិតនៅកម្ពុជា។

### • ថ្នាក់ក្រោមជាតិ

▪ **គណៈកម្មាធិការ គ.ខ.ប.ជ ខេត្តបន្ទាយមានជ័យ** បានចេញសេចក្តីសំរេច ស្តីពីការតែងតាំង និងផ្លាស់ប្តូរសមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត។

▪ **គណៈកម្មាធិការ គ.ខ.ប.ជ ខេត្តប៉ៃលិន** បានចេញសេចក្តីសំរេចស្តីពី ការតែងតាំង និងផ្លាស់ប្តូរសមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត។

▪ **គណៈកម្មាធិការ គ.ខ.ប.ជ ខេត្តកំពង់ឆ្នាំង** បានចេញសេចក្តីសំរេចស្តីពី ការតែងតាំង និងផ្លាស់ប្តូរសមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត។

▪ **គណៈកម្មាធិការ គ.ខ.ប.ជ ខេត្តសៀមរាប** បានចេញសេចក្តីសំរេចស្តីពី ការតែងតាំង និងផ្លាស់ប្តូរសមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត។

- **គណៈកម្មាធិការ គ.ខ.ប.ជ ខេត្តកំពង់ចាមៈ** បានចេញសេចក្ដីសំរេចស្ដីពី ការតែងតាំង និងផ្លាស់ប្ដូរសមាសភាព គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបានចេញសេចក្ដីសំរេច ស្ដីពីការកែសម្រួលសមាសភាពក្រុមការងារជំនាញទាំង៦ របស់គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត។
- **គណៈកម្មាធិការ គ.ខ.ប.ជ ខេត្តកណ្ដាល** បានចេញសេចក្ដីសំរេចស្ដីពី ការតែងតាំង និងផ្លាស់ប្ដូរសមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត។

## ខ. ការបង្ការ ទប់ស្កាត់

### ខ.១. ការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង

#### ខ.១.១.ការផ្សព្វផ្សាយជាសាធារណៈ

| ល.រ | ផ្សព្វផ្សាយតាមរយៈ | ចំនួនលើក | ចំនួនអ្នកចូលរួម |
|---|---|---|---|
| ១ | ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ៥.៤៦៣ | ១.៦០១.៨៩៤ អង្គ/នាក់ |
| ២ | វេទិកាអន្តរសាសនា | ០១ | ១.៥០០ អង្គ/នាក់ |
| ៣ | វេទិកាសាធារណៈ និងភូមិ-ឃុំមានសុវត្ថិភាព | ៨០.១៥១ | ៥.៤៩២.០៤៤ នាក់ |
| ៤ | កម្មវិធីផ្សេងៗ | ៣៥ | ១៤.១៦២ នាក់ |
| ៥ | អង្គការដៃគូនានា | ១០២ | ៦.០២២ នាក់ |
| សរុប | | ៨៥.៧៥២ លើក | ៧.១១៥.៦២២ នាក់ |

##### ខ.១.១.១.ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- **ថ្នាក់ជាតិ**

❖ នៅក្នុងរយៈពេលមួយឆ្នាំ២០១៩នេះ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាល ក៏ដូចជា **សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** តែងតែដាស់តឿនក្រើនរំលឹក រៀងរាល់កិច្ចប្រជុំ និងកម្មវិធីជាសាធារណៈនានា (ឧទាហរណ៍ ពិធីសម្ពោធសមិទ្ធិផល តាមបណ្ដាខេត្តជាដើម) ដល់មន្ត្រីរាជការ អាជ្ញាធរ សមត្ថកិច្ច និងប្រជាពលរដ្ឋ ឲ្យយកចិត្តទុកដាក់ បង្ការទប់ស្កាត់ បង្រ្កាប និងការពារប្រជាពលរដ្ឋពីអំពើជួញដូរមនុស្ស ការអូសទាញពីជនខិលខូច ជាមេខ្យល់ឲ្យធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងដាស់តឿនឲ្យជួយគាំទ្រ និងផ្ដល់កិច្ចការពារដល់ជនរងគ្រោះជាដើម។

❖ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)** បានសហការជាមួយក្រសួងស្ថាប័ន អង្គភាព និងអង្គការដៃគូពាក់ព័ន្ធ ផលិតសម្ភារផ្សព្វផ្សាយអប់រំ និងបានសហការជាមួយទូរទស្សន៍ BTV, PNN ផលិតជាខ្សែវីដេអូបទយកការណ៍ស្ដីពីស្ថានភាព និងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពពោះជំនួស ទេសន្តរប្រវេសន៍ដោយប្រថុយប្រថាន...។ លើសពីនេះទៅទៀត គណៈកម្មាធិការជាតិ និងគណៈកម្មាធិការខេត្តមួយចំនួន បានសហការជាមួយក្រសួង និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ និងអង្គការហ្វាពន្លឺសិល្បៈ(បាត់ដំបង) បានរៀបចំការសម្ដែងសិល្បៈចម្រុះ ដើម្បី

បញ្ជ្រាបការយល់ដឹងដល់អង្គពិធីទាំងមូល ក្នុងកម្មវិធីយុទ្ធនាការនៃទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ លើកទី១៣ ឆ្នាំ២០១៩។

នៅថ្នាក់ជាតិ ទិវាជាតិ១២ធ្នូ ប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ ដែលមានអ្នកចូលរួមប្រមាណ ៣.៥០០អង្គ/នាក់ រួមមានថ្នាក់ដឹកនាំកំពូលសំខាន់ៗ ក្នុងស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ អង្គទូតនានាដែលមាននិវេសនដ្ឋាននៅកម្ពុជា អាជ្ញាធរ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ តំណាងផ្នែកសាសនា និយោជិត កម្មករ និយោជក សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ** និងជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

- **ថ្នាក់ក្រោមជាតិ**

❖ **លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ចំនួន១៨ ខេត្ត** បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ រៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៩ និងផលិតសម្ភារផ្សព្វផ្សាយអប់រំក្នុងយុទ្ធនាការ ដែលមានអ្នកចូលរួមជាថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ទីរពាក់ព័ន្ធនានា សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ សរុបចំនួន ១៩លើក មនុស្សប្រមាណ ១១.០៣១នាក់ (ស្រី ៣.០៣៩នាក់)។

❖ **ដោយឡែកមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត** ទាំង២៥ និងគ្រឹះស្ថានសិក្សាគ្រប់កម្រិត ទាំងវិស័យរដ្ឋ និងឯកជន បានប្រារព្ធទិវាជាតិប្រឆាំងការជួញដូរមនុស្ស១២ធ្នូ ដែលមានថ្នាក់ដឹកនាំគ្រឹះស្ថានសិក្សា សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត ចំនួន **៥.៤៤៣**លើក មានអ្នកចូលរួមសរុបចំនួន **១.៥៨៧.៣៦៣**នាក់ (ស្រី **៩៦២.២៦៩**នាក់) ក្នុងនោះមានៈ(បុគ្គលិកអប់រំចំនួន ៦២.១៧៨នាក់ ស្រី ២២.៩៧៦នាក់ និងសិស្សានុសិស្ស និស្សិត ចំនួន១.៥២៥.១៨៥នាក់ (ស្រី ៩៣៩.២៩៣នាក់)។

### ខ.១.១.២.វេទិកាអន្តរសាសនា

❖ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ បានសហការជាមួយអង្គការកោរីតាសកម្ពុជា ក្រសួងធម្មការ និងសាសនា និងមេដឹកនាំនិកាយសាសនាធំៗ ក្នុងព្រះរាជាណាចក្រកម្ពុជា រៀបចំកម្មវិធីវេទិកាជាតិអន្តរសាសនាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប នៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** មានអ្នកចូលរួមប្រមាណ **១.៥០០**អង្គ/នាក់។

❖ មេដឹកនាំសាសនានីមួយៗ បានបន្តផ្សព្វផ្សាយទៅសាសនិករបស់ខ្លួន តាមរយៈកម្មវិធីសាសនានានា ការចុះអប់រំយុវវ័យតាមសហគមន៍ និងតាមសាលារៀន និងកម្មវិធីផ្សព្វផ្សាយអប់រំផ្លូវចិត្ត តាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ( ឧ. កម្មវិធីពុទ្ធសាសនាផ្សាភ្ជាប់នឹងសង្គម.....)។

### ខ.១.១.៣. វេទិកាសាធារណៈ និងទូរទស្សន៍ ឃុំសុវត្ថិភាព

❖ បំណែកងស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានធ្វើការផ្សព្វផ្សាយខ្លឹមសារ ស្តីពី **«ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព»** ដោយឡែកៗពីគ្នា និងដោយមានកិច្ចសហការជាមួយក្រសួង មន្ទីរពាក់ព័ន្ធ អង្គការដៃគូដល់

ប្រជាពលរដ្ឋតាមសហគមន៍ និងតាមវេទិកាសាធារណៈ ដើម្បីពង្រឹងការអនុវត្តគោលនយោបាយ «**ភូមិ-ឃុំ មានសុវត្ថិភាព**» និងការអប់រំជាប្រចាំដល់សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ កម្មករ កម្មការិនី និងប្រជាពលរដ្ឋ បានសរុបចំនួន **៨០.១៥១**លើក មានអ្នកចូលរួមសរុបចំនួន **៥.៤៩២.០៤៤** នាក់ ក្នុងនោះស្ត្រីចំនួន **២.៦៥៦.០៨៦**នាក់ មានដូចតារាងលម្អិតខាងក្រោម៖

## តារាងទិន្នន័យនៃការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| **ក្រសួង ស្ថាប័ន** | | | | | | | |
| ១ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១៥ | ៤០១.៤០២ | ២២.០២៥ | ៨២ | ១៦.២៥៨ | ៥៧ |
| ២ | ក្រសួងអប់រំ យុវជន និងកីឡា | ៧ | ៦.៥២៥ | ៣.៨៣១ | | | |
| ៣ | ក្រសួងកិច្ចការនារី | ១២ | ២.៤២៤ | ១.៥០៨ | ៩ | ៦១៦ | ៣៧៨ |
| ៤ | ក្រសួងឧស្សាហកម្ម-សិប្បកម្ម | ១៦ | ១៩៧ | ៦៥ | | | |
| ៥ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ២.០១៣ | ១៩២.៨៥៧ | ៦២.៣៩២ | ០ | ០ | ០ |
| ៧ | ក្រសួងសុខាភិបាល (ផ្សព្វផ្សាយ ច្បាប់ស្តីពី ការគ្រប់គ្រង ការបរិច្ចាក ការផ្សាំកោសិកា ជាលិកា សរីរាង្គមនុស្ស) | ៦ | ៥១០ | ៩៧ | ០ | ០ | ០ |
| ៨ | កាកបាទក្រហមកម្ពុជា | ២ | ៧៤ | ៧៤ | ៥ | ១០.០៣២ | ៥.៧០៦ |
| ៩ | សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ (ផ្សព្វផ្សាយតាមរោងចក្រ ) | ១៦ | ១.០១៦ | ៩៣៤ | ០ | ០ | ០ |
| | **សរុប ក្រសួង ស្ថាប័ន** | **២.០៨៧លើក** | **៦០៥.០០៥នាក់** | **៩០.៩២៦នាក់** | **៩៦លើក** | **២៦.៩០៦នាក់** | **៦.១៤១នាក់** |
| **រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | ១១ | ៥.៣២២ | ២.៧០៧ | ៦ | ៣.១២៥ | ១.៩៤៧ |
| ២ | ខេត្តកណ្តាល) | ៣.៨២០ | ១៤៧.៤៨៧ | ៦៧.៧៤៤ | ៨.៥០៩ | ៥៣៦.៥០០ | ២៦៦.៩៤៥ |
| ៣ | ខេត្តបាត់ដំបង | ៨.៩៧៧ | ៥៧២.៥៥៤ | ២៩៦.៨៧១ | ៤.៨៥២ | ២០០.០៤២ | ១០៣.១៨៩ |
| ៤ | ខេត្តពោធិ៍សាត់ | ៦.២៥២ | ៦៦៩.៧៩៩ | ៣៤៨.៥០១ | ២.០១៦ | ៧៣.៤៥២ | ៣៨.៣៨៤ |
| ៥ | ខេត្តសៀមរាប | ៤.៩៣៨ | ២៩៩.៦៤២ | ១៤៩.៩០៣ | ១.៥០៦ | ១០៥.២១៧ | ៥៦.៧២៣ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១០.៣២៣ | ៥៧១.៩៧២ | ៣១១.៥៦២ | ៦.៨០១ | ២៨០.២៣៣ | ១៥២.២៦១ |
| ៧ | ខេត្តកំពង់ចាម | ៣.៩២៨ | ២២៧.៤៩១ | ១២៩.៦៧០ | ២.៣៨០ | ១៣០.៥៦៥ | ១៥៣.៥៧១ |
| ៨ | ខេត្តព្រះសីហនុ | ២៥៥ | ១១.៤៤៧ | ៥.៣៦៧ | ៧៦ | ២.៧៨៩ | ១.១៤៤ |
| ៩ | ខេត្តព្រះវិហារ | ៨១ | ២៨.៣៣៤ | ១២.៩៩៥ | ៤២ | ១០.១៨១ | ៤.៥៣៨ |
| ១០ | ខេត្តស្វាយរៀង | ៩៦ | ១.២០២ | ៦០៣ | ៤.០៨៥ | ១៥៨.៦៨៧ | ៨៦.៥២៩ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១១ | ខេត្តប៉ៃលិន | ៤៤១ | ២៩.៧៨២ | ១៤.០២១ | ៣១៧ | ២០.៩៨៦ | ៨.៩៦១ |
| ១២ | ខេត្តកោះកុង | ២៩ | ៩.៣៥៣ | ៤.៤២៥ | ៦៨៩ | ៩៦.០១៣ | ១៣.៥១១ |
| ១៣ | ខេត្តកំពត | ១១១ | ៤.៨០៩ | ៣.០៧២ | ១ | ៨៥ | ៦០ |
| ១៤ | ខេត្តកំពង់ធំ | ១២៩ | ៣.៩៤១ | ២.១៦៩ | ៤ | ១.៧៤៤ | ៤៦៥ |
| ១៥ | ខេត្តតាកែវ | ១.៨៧៤ | ១០១.៧២៤ | ៤៦.៦៩៤ | ១.២៥៦ | ៤៨.០២០ | ២១.៥៧២ |
| ១៦ | ខេត្តក្រចេះ | ៥៥ | ២.៦៦៦ | ១.៦៥៦ | ១៣ | ១.៥៤៤ | ៥៩៦ |
| ១៧ | ខេត្តកែប | ២៤៩ | ៧០.៤០២ | ២៩.៧៧៨ | ១៩៦ | ៥០.៨៤៦ | ២២.៩៣២ |
| ១៨ | ខេត្តកំពង់ស្ពឺ | ១.៧៤៧ | ២៤៣.០០២ | ១២៩.០២៧ | ២៤៤ | ១១.៣២២ | ៦.២០៥ |
| ១៩ | ខេត្តស្ទឹងត្រែង | ៥ | ៤៣០ | ២២៩ | ៣២ | ២.១៣៨ | ១.១៩៧ |
| ២០ | ខេត្តរតនគិរី | ២៨៨ | ១៨.២៧៤ | ៧.៣៨៨ | ២២៧ | ១៧.០០១ | ៩.១១៥ |
| ២១ | ខេត្តព្រៃវែង | ៥១ | ៤៨.១២១ | ២៤.០១៥ | ១២ | ១.១៧០ | ០ |
| ២២ | ខេត្តត្បូងឃ្មុំ | ២៧ | ១.៥៥១ | ១.០៥៤ | ៨ | ៤៥៩ | ២២៩ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ៧៥០ | ១០.៩៤៩ | ៥.៨៣៣ | ២១៥ | ៥.២៦០ | ២.៩៨៦ |
| ២៤ | ខេត្តឧត្តរមានជ័យ | ៣៦ | ២.៣០២ | ១.៥៣៣ | | | |
| ២៥ | ខេត្តមណ្ឌលគិរី | ៨ | ២០.១៩៨ | ៩.១៤២ | | | |
| សរុប រាជធានី-ខេត្ត | | ៤៤.៤៨១លើក | ៣.១០២.៧៥៤នាក់ | ១.៦០៥.៩៥៩នាក់ | ៣៣.៤៨៧លើក | ១.៧៥៧.៣៧៩នាក់ | ៩៥៣.០៦០នាក់ |
| សរុបរួម<br>ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន<br>៨០.១៥១ លើក | | ចំនួនមនុស្សសរុប<br>៥.៤៩២.០៤៤ នាក់ | | ចំនួនស្ត្រី<br>២.៦៥៦.០៨៦ នាក់ | |

### ខ.១.១.៤.ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗសរុបបានចំនួន **៣៥**លើក មានអ្នកចូលរួមសរុប **១៤.១៦២**នាក់ ស្រី **៧.០១៨**នាក់ ដែលមានដូចខាងក្រោម៖

- **ថ្នាក់ជាតិ៖**
  - **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ៖** អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ និងមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តទូទាំងប្រទេស បានបញ្ជ្រាបសារស្តីពីការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្សក្នុងមហោស្រពសិល្បៈយុវជនទូទាំងប្រទេស ដល់ប្រជាពលរដ្ឋ សិល្បករ និងសិស្ស និស្សិត ចូលរួមប្រមាណ **៥.៥៦៧**នាក់ ស្រី **២.៦៣៣**នាក់។
  - **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការបង្ការ-ទប់ស្កាត់ អំពើជួញដូរមនុស្សក្នុងវិស័យកសិកម្ម នៅសាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង ក្រោមអធិបតីភាព **ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** មាននិស្សិតចូលរួមចំនួន **៧៥០**នាក់ (ស្រី ៣៩៤នាក់)។
  - **ក្រុមការងារកាយឫទ្ធិស្ត្រីកម្ពុជា** បានសហការជាមួយ ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយអំពីស្ថានភាពទូទៅនៃអំពើជួញដូរមនុស្ស ផ្តោតសំខាន់លើការធ្វើចំណាកស្រុក និងបទល្មើសស្ត្រីស៊ីឈ្នួលពពោះជំនួស ចំនួន ០២លើក នៅស្រុក

សំរោង ខេត្តតាកែវ និងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដល់លោកមេឃុំ សិស្សានុសិស្ស សមាជិកា ក្រុមកាយឫទ្ធិស្ត្រីកម្ពុជា សរុបចំនួន **១៥៤**នាក់ (ស្រី **១៥២**នាក់)។

- **ថ្នាក់ក្រោមជាតិ៖**
  - **ខេត្តកំពង់ស្ពឺ**
    - **មន្ទីរធម្មការ និងសាសនា** បានបញ្ជ្រាបការផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈវេទិកាអន្តរសាសនា បានចំនួន **០៦**លើក មានអ្នកចូលរួមចំនួន **៧.៣៤៤**នាក់ ស្រី **៣.៦៧៤**នាក់។
    - **មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ** បានបញ្ជ្រាបការផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការសម្តែងសិល្បៈ បានចំនួន **០១**លើក មានអ្នកចូលរួមចំនួន **៣៤៧**នាក់ ស្រី **១៦៥**នាក់។
- **អង្គការដៃគូ៖**

តាមរបាយការណ៍ដែលអង្គការដៃគូមួយចំនួន បញ្ជូនមកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានបង្ហាញថា មានការអប់រំផ្សព្វផ្សាយតាមគម្រោងកម្មវិធីរបស់ខ្លួន ដូចមានក្នុងតារាងខាងក្រោម៖

*តារាងទិន្នន័យនៃការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ របស់អង្គការដៃគូនានា*

| *ឈ្មោះអង្គការ* | *សកម្មភាព* | *ផ្សព្វផ្សាយតាមកម្មវិធីនានា* | | |
|---|---|---|---|---|
| | | **ចំនួនដង/លើក** | **ចំនួនមនុស្ស** | **ចំនួនស្ត្រី** |
| **អង្គការរីនរ៉ក់អន្តរជាតិ**/Sovann Phoum, & CEDAC | -បានដាក់បញ្ចូលការផ្សព្វផ្សាយសកម្មភាព បង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយ ប្រថុយប្រថានទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ នៅក្នុងខេត្ត /ខេត្ត ព្រៃវែង កំពង់ចាម កំពង់ធំ សៀមរាប បន្ទាយមានជ័យ ឧត្តរមានជ័យ និង រាជធានីភ្នំពេញ ចំនួន ០១លើក មានអ្នកចូលរួម ៤០នាក់។<br>-បានប្រជុំផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្ស នៅស្រុកពួក និងស្រុកជីក្រែង ខេត្តសៀមរាប ចំនួន ១០លើក មានអ្នកចូលរួម ២៧៧នាក់ (ស្រី២០៥នាក់)។<br>-សម្ភារៈផ្សព្វផ្សាយ/IEC materials ចំនួន ៣៧៦ ស្តីពី(ការទប់ស្កាត់អំពីជួញដូរ មនុស្ស និងចំណាកស្រុកប្រកបដោយសុវត្ថិភាព) នៅខេត្តស្វាយរៀង កោះកុង ព្រៃវែង កំពង់ចាម កំពង់ធំ សៀមរាប បន្ទាយមានជ័យ ឧត្តរមានជ័យ និងរាជធានីភ្នំពេញ ចែកជូនអ្នកចូលរួមចំនួន ៣៧៦នាក់។ | ១២ | ៦៩៣ | ២០៥ |
| **អង្គការសម្ព័ន្ធចាប់ដៃ** | ផ្សព្វផ្សាយស្តីពីការជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទលើកុមារ និងការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព នៅខេត្តកំពង់ឆ្នាំង និងរតនៈគិរី។ | ០២ | ១៣១ | ២១ |
| **អង្គការមូលនិធិកុមារ** (Child Fund) **និងអង្គការ CCPCR** | -អង្គការមូលនិធិកុមារ ផ្សព្វផ្សាយស្តីពីការជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទលើកុមារ និងការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព នៅខេត្តកោះកុង ចំនួន ២៤លើក មានអ្នកចូលរួម ៨៩៩នាក់(ស្រី | ៤២ | ២.២៤៨ | ១.៣៤០ |

| | | | | |
|---|---|---|---|---|
| | ៥៩០នាក់)។<br>-សហការជាមួយអ្នកសម្របសម្រួលព័ត៌មានចំណាកស្រុក ឃុំក្រសាំង និងឃុំអណ្តូងត្របែក ខេត្តស្វាយរៀង ធ្វើការផ្តល់សេវាប្រឹក្សាយោបល់នៅក្នុងមណ្ឌលព័ត៌មានចំណាកស្រុកដល់យុវជនស្ម័គ្រចិត្ត សិស្ស និងគ្រួសារក្នុងសហគមន៍ ដែលមានបំណងស្វែងយល់ពីបញ្ហាប្រឈមនៃការធ្វើចំណាកស្រុក ដោយគ្មានសុវត្ថិភាព និងល្បិចកលជនល្មើស ការកេងប្រវ័ញ្ច និងកិច្ចការពារកុមារ ចំនួន ០២លើក អ្នកចូលរួម ៥២៦នាក់(ស្រី២៩៧នាក់)។<br>-សហការជាមួយក្រុមយុវជន និងអ្នកស្ម័គ្រចិត្តភូមិ រៀបចំការប្រជុំផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកចំនួន ១២លើក មានអ្នកចូលរួម ៧២៩នាក់(ស្រី៤៥៧នាក់)។<br>-បានរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងពីបញ្ហាអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងការជួញដូរកុមារ ចំនួន ០៤លើក អ្នកចូលរួម ៩៤នាក់(ស្រី១៥នាក់)។ | | | |
| **សាម៉ារីតាន់ភឺស** | បានចែកប័ណ្ណផ្សព្វផ្សាយអប់រំ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ជនចំណាកស្រុក នៅក្នុងខេត្តបាត់ដំបង។ | ១០ | ១.១៩៨ | ៣៩០ |
| **អង្គការ** GVC | បានសហការជាមួយទីភ្នាក់ងារជាតិមុខរបរនិងការងារខេត្ត អាជ្ញាធរស្រុក និងឃុំគោលដៅ ទាំង៣ ប្រជុំផ្សព្វផ្សាយអំពីការចំណាកស្រុកប្រកបដោយសុវត្ថិភាព សិទ្ធិការងាររបស់ពលករចំណាកស្រុកក្នុងប្រទេសថៃ និងការទប់ស្កាត់នៃការជួញដូរមនុស្ស នៅក្នុងខេត្តបាត់ដំបង។ | ២០ | ១.១៧៨ | ៨៧៤ |
| **អង្គការ** Cambodia Act | បណ្តាញកុមារថ្នាក់ឃុំ ចុះអប់រំផ្សព្វផ្សាយស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវិធីសាស្ត្រក្នុងការអប់រំផ្សព្វផ្សាយនៅតាមសហគមន៍ និងសាលារៀន។ | ០៦ | ៣០៧ | ១៩៧ |
| **អង្គការ** We World/GVC | ប្រជុំផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្ស នៅស្រុកពួក ស្រុកជីក្រែង ខេត្តសៀមរាប។ | ១០ | ២៧៧ | ២០៥ |
| **សរុប** | | **១០២** | **៦.០២២** | **៣.២៣២** |

### ខ.១.២. ការផ្សព្វផ្សាយ តាមរយៈឧបករណ៍ផ្សព្វផ្សាយ

- **ថ្នាក់ជាតិ**
  - **គណៈកម្មាធិការជាតិ គ.ជ.ប.ជ** នៅថ្ងៃទិវាជាតិ១២ធ្នូ លើកទី ១៣ ឆ្នាំ២០១៩ បានផលិត៖
    - បដាធំជាពាក្យស្លោកចំនួន ០២ផ្ទាំង និងជាសារបង្ហោះតាមបាឡុងធំចំនួន០៣ និងប៉េងប៉ោងតូចៗសរុបចំនួន ១៦០សារ ដែលបញ្ជាក់ខ្លឹមសារពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
    - ឯកសារ ដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់ដាក់បញ្ចូលក្នុងថង់បរិស្ថាន ចំនួន ៣.៥០០ច្បាប់ ។

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន ៖
  - ផលិត និងបោះពុម្ពខិតប័ណ្ណសម្រាប់ផ្សព្វផ្សាយអំពីព័ត៌មានទីផ្សារការងារ ដល់ប្រជាពលរដ្ឋ ជាពិសេសយុវជន យុវនារី បានចំនួន **១៩៤.៥៨១**សន្លឹក។
  - រៀបចំពិព័រណ៍ការងារថ្នាក់ជាតិ/ខេត្តបានចំនួន ០៣លើក ដែលមានអ្នកចូលរួម ចំនួន **៣៨.៣៩១**នាក់។
  - បានរៀបចំពិព័រណ៍ការងារចល័តចំនួន **២១៧**ដង ដែលមានអ្នកចូលរួមចំនួន **៤០.០២៥**នាក់
- **ក្រសួងអប់រំ យុវជន និងកីឡា** បានបោះពុម្ពខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន ៣.០០០ច្បាប់ និងបានចែកចាយរាជធានី ខេត្តទាំង២៥ សម្រាប់ចុះទៅផ្សព្វផ្សាយបន្តនៅតាមសហគមន៍។
- **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** បានបញ្ចូលសារអប់រំពាក់ព័ន្ធអំពើជួញដូរមនុស្ស ក្នុងផលិតផលភាពយន្ត (CD,VCD,DVD) សរុបចំនួន **២.៥១៦.៣៨៦**ឌីស។
- **កាកបាទក្រហមកម្ពុជា** បានបោះពុម្ពប័ណ្ណផ្សព្វផ្សាយ អំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព សម្រាប់ចែកជូនសាខារាជធានី-ខេត្ត ដើម្បីផ្សព្វផ្សាយបន្ត ចំនួន **៣.០០០**ច្បាប់។

**• ថ្នាក់ក្រោមជាតិ**

- **រាជធានីភ្នំពេញ** បានផលិតបដាសម្រាប់ចងនៅថ្ងៃទិវាជាតិ១២ធ្នូ លើកទី ១៣ បានផលិតបដាជាពាក្យស្លោក ដែលបញ្ជាក់ខ្លឹមសារពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចំនួន **៤០**ផ្ទាំង។
- **ខេត្តកំពង់ស្ពឺ** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានផលិតបដា ជាពាក្យស្លោក ដែលបញ្ជាក់ខ្លឹមសារ ស្តីពីច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបានចងបដាទាំងនោះនៅតាមបណ្តាចំណុចសំខាន់ៗ ទូទាំងខេត្ត បានចំនួន **៥៤**ផ្ទាំង។
- **ខេត្តតាកែវ** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា បានផលិតបដាជាពាក្យស្លោក ដែលបញ្ជាក់ខ្លឹមសារ ស្តីពីច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ជាពិសេសលើស្ត្រី និងកុមារ បានចំនួន **៥៨**ផ្ទាំង។
- **សកម្មភាពរបស់អង្គការដៃគូ៖**
  - **អង្គការ Winrock និង Open Institute** ផលិតសម្ភារៈផ្សព្វផ្សាយ(IEC materials) ស្តីពីព័ត៌មានអំពីការទប់ស្កាត់អំពីជួញដូរមនុស្ស និងចំណាកស្រុកប្រកបដោយសុវត្ថិភាពនៅក្នុងរាជធានីភ្នំពេញ ខេត្តស្វាយរៀង កោះកុង ព្រៃវែង កំពង់ចាម កំពង់ធំ សៀមរាប បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ សរុបបានចំនួន **១.៦៤៤**នាក់។
  - **អង្គការសាម៉ារីតាន់ភឺស** បានអប់រំផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈការចែកខិត្តប័ណ្ណផ្សព្វផ្សាយដល់ពលករធ្វើចំណាកស្រុក ក្រោយពីអាជ្ញាធរថៃបញ្ជូនមកវិញ សរុបបានចំនួន **៥.៦២៥**នាក់(ស្រី **២.០៤២**នាក់)។
  - **អង្គការមូលនិធិកុមារ** (Child Fund) **និងអង្គការ**CCPCR បានបោះពុម្ពសៀវភៅ ខិត្តប័ណ្ណអប់រំផ្សព្វផ្សាយ និងរៀបចំដំឡើងផ្ទាំងប៉ាន់ណូថ្មី ចំនួន **៦**ផ្ទាំង ស្តីអំពីការអប់រំក្នុងការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងទប់ស្កាត់អំពើជួញដូរមនុស្ស និងប្តូរផ្ទាំងប៉ាន់ណូចាស់ចំនួន **១៣**ផ្ទាំង នៅឃុំក្រសាំង និងអណ្តូងត្របែក ខេត្តស្វាយរៀង។

### ៦.១.៣. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និង ប្រព័ន្ធអេឡិចត្រូនិក

**• ថ្នាក់ជាតិ**

- **ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ៖**

- ក្រសួងបានពង្រឹងយន្តការវេទិកាការងារ បង្កើនការងារផ្សព្វផ្សាយ និងបញ្ជ្រាបតាមព័ត៌មានទីផ្សារការងារ តាមរយៈ៖
  - គេហទំព័រNEA មជ្ឈមណ្ឌលការងារNEA Facebook និងកម្មវិធីនាទីទីផ្សារការងារ និងមុខរបរតាមស្ថានីយ៍ទូរទស្សន៍នានា សរុបចំនួន **១៣៤.៤១៥**នាក់។
  - ពង្រីកការផ្តល់ព័ត៌មានទីផ្សារការងារតាមរយៈ Facebook ចំនួន **១៧.៩១២**នាក់ Youtube ចំនួន **៨៦.៩៥២**នាក់ និងតាមរយៈកម្មវិធីស្វែងរកការងារលើទូរស័ព្ទ(Mobile App)ចំនួន **១.៦៥៩**នាក់។
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង បានសហការជាមួយមជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍(MRC)ខេត្ត ផ្សព្វផ្សាយការយល់ដឹងតាមរយៈកម្មវិធីវិទ្យុ ស្តីពីការធ្វើទេសន្តរប្រវេសន៍ដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ជនបទ ក្នុងខេត្តបាត់ដំបង និងមួយផ្នែកនៃខេត្តប៉ៃលិន ពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ។

- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**
  - **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**
  - បានសហការជាមួយស្ថានីយ៍ទូរទស្សន៍ចំនួន ០៤ (បាយ័ន្ត CNC PNN និង NICE TV) ធ្វើការផ្សព្វផ្សាយសារជាអក្សររត់លើអេក្រង់ទូរទស្សន៍ ដើម្បីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានខ្លឹមសារថា "(១)អបអរសាទរទិវាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សអន្តរជាតិ ៣០ កក្កដា ឆ្នាំ២០១៩ (២)រាជរដ្ឋាភិបាលកម្ពុជាបន្តប្តេជ្ញាចិត្ត ពង្រឹងកិច្ចសហការជាមួយដៃគូពាក់ព័ន្ធជាតិ និងអន្តរជាតិ ប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃអំពើជួញដូរមនុស្ស"។
  - បានសហការជាមួយនិយ័តករទូរគមនាគមន៍កម្ពុជា (TRC) និងក្រុមហ៊ុនផ្តល់សេវាកម្មទូរស័ព្ទចល័ត ដើម្បីបង្ហោះសារ ពាក់ព័ន្ធនឹងការបង្ការ ទប់ស្កាត់ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ តាមប្រព័ន្ធទូរស័ព្ទចល័ត៖
    - ក្នុងពិធីអបអរទិវាកុមារអន្តរជាតិ ០១ មិថុនា ២០១៩។
    - ក្នុងពិធីអបអរវេទិកាជាតិអន្តរសាសនាលើកទី៣ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
    - ក្នុងពិធីអបអរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៩ នៅកម្ពុជា។
  - **លេខាធិការដ្ឋានរដ្ឋបាលសរុប នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមប្រព័ន្ធគេហទំព័រព័ត៌មាននានាទាំងជាតិ និងអន្តរជាតិ បានចំនួន **១.១០២**ព័ត៌មាន ក្នុងនោះមានអន្តរជាតិចំនួន **៥៨**ព័ត៌មាន។

- **ថ្នាក់ក្រោមជាតិ**

ក្នុងការអប់រំ ផ្សព្វផ្សាយ តាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក មានរបាយការណ៍ពីខេត្តចំនួន៥ បានចំនួនសរុប **៥១.១៥៧ លើក**តាមតារាងខាងក្រោម៖

*តារាងនៃការអប់រំផ្សព្វផ្សាយ តាមវិទ្យុទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក*

| ល.រ | ខេត្ត | កម្មវិធី | ចំនួនលើក |
|---|---|---|---|
| ១. | សៀមរាប | ក្រុមការងារលេខាធិការដ្ឋានខេត្ត បានសហការជាមួយមន្ទីរព័ត៌មានខេត្ត និងអង្គភាពពាក់ព័ន្ធ ផលិតកម្មវិធី យើងធ្វើបានសន្ទនាមតិ និងចូលរួមជាវាគ្មិន ក្នុងនាទី | ៤៩.១៨៣ លើក |

| | | | |
|---|---|---|---|
| | | ស្រុកយើង ផ្សាយផ្ទាល់ និងចាក់ផ្សាយឡើងវិញ នៅវិទ្យុជាតិFMវិទ្យុនគរភ្នំ បណ្តាញទូរទស្សន៍ជាតិ ទូរទស្សន៍ខ្សែកាបអង្គរ ប្រព័ន្ធអនឡាញ ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស ចំណាកស្រុកប្រកបដោយសុវត្ថិភាព ជួញដូរផ្លូវភេទ ជួញដូរគ្រឿងញៀន និងអំពើហិង្សាក្នុងគ្រួសារ។ | |
| ២. | តាកែវ | មន្ទីរព័ត៌មាន បានផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវិទ្យុ និងទូរទស្សន៍គោកធ្លក។ | ៥៩២ លើក |
| ៣. | កំពង់ចាម | មន្ទីរព័ត៌មាន បានសហការជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ផ្សព្វផ្សាយរឿងអប់រំខ្លីៗ ស្តីពីចំណាកស្រុកប្រកបដោយសុវត្ថិភាព និងផ្សព្វផ្សាយតាមហ្វេសបុក នូវសេចក្តីជូនដំណឹង ព័ត៌មានពាក់ព័ន្ធពលករ និងកិច្ចប្រជុំនានារបស់ក្រុមការងារទេសន្តរប្រវេសន៍។ | ១២លើក |
| ៤. | កោះកុង | វិទ្យុសាគរ នៃមន្ទីរព័ត៌មាន កម្មវិធីពិភាក្សា ស្តីពីជម្រើសដោយសុវត្ថិភាព៖<br>-ផ្តោតលើការជួញដូរមនុស្ស<br>-ផ្តោតលើចំណាកស្រុក | <br>១.២០០ លើក<br>១៥០ លើក |
| ៥ | ស្វាយរៀង | អង្គការមូលនិធិកុមារ(Child Fund) និងអង្គការ CCPCR ក្រុមយុវជនស្ម័គ្រចិត្ត បានចាក់ផ្សាយខ្សែវីដេអូ ស្តីពីការធ្វើចំណាកស្រុកសុវត្ថិភាពស្របច្បាប់ និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន | ២០ លើក |
| **សរុប** | | | **៥១.១៥៧ លើក** |

### ខ.១.៤. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា

- **ថ្នាក់ជាតិ**
  - **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

-**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បាន អញ្ជើញចូលរួម៖

- ជាវាគ្មិនកិត្តិយសក្នុងកិច្ចសន្ទនាគោលនយោបាយថ្នាក់ជាតិ ស្តីពីអំពើហិង្សាផ្លូវភេទទៅលើកុមារ រៀបចំសម្របសម្រួលដោយអង្គការសីលការ(SILAKA) មានសមាសភាពចូលរួមចំនួន **៤៦**នាក់ (ស្រី **៣៣**នាក់) នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ។
- ជាវាគ្មិនក្នុងវេទិកាកុមារ និងអ្នកធ្វើគោលនយោបាយ ដែលមានអ្នកចូលរួមចំនួន **១៨០**នាក់ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- ធ្វើបទបង្ហាញ ក្នុងសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សក្នុងវិស័យកសិកម្ម នៅសាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង មាននិស្សិតចូលរួមចំនួន **៧៥០**នាក់។
- ជាវាគ្មិន ក្នុងកម្មវិធី "ដឹង គិត យល់ ជោគជ័យ" លើប្រធានបទ "យន្តការ និងគោលនយោបាយសម្រាប់ទេសន្តរប្រវេសន៍" របស់វិទ្យុស្ត្រី FM១០៣.៥MHz ដោយបានធ្វើការផ្សាយផ្ទាល់តាមវិទ្យុ និងបន្តផ្ទាល់តាមហ្វេសប៊ុក។

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**

-**ឯកឧត្តម ឧត្តមសេនីយ៍ឯក យឹម វិរៈ អគ្គលេខាធិការរង** បានអញ្ជើញចូលរួមជាវាគ្មិន៖

- ក្នុងការផ្សព្វផ្សាយផ្ទាល់របស់វិទ្យុក្នុងកម្មវិធីសំលេងសមភាពយេនឌ័រ ស្តីពីការចូលរួមចំណែកក្នុងការលើកកម្ពស់សមភាពយេនឌ័រ នៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាល និងក្នុងជីវភាពសាធារណៈនៅកម្ពុជា ដោយធានាថា ស្ត្រី ក្មេងស្រី និងអ្នកស្រឡាញ់ភេទដូចគ្នាដែលជាក្រុមគោលដៅទទួលបានសិទ្ធិអំណាចដើម្បីទាមទារសិទ្ធិរបស់ខ្លួន និងទទួលបានការគាំទ្របន្ថែមពីអាជ្ញាធរនិងសហគមន៍របស់ពួកគេ។
- ក្នុងវេទិកាពិភាក្សាតុមូលរបស់ទូរទស្សន៍ជាតិកម្ពុជា ស្តីពីការលើកកម្ពស់សិទ្ធិកុមារ តាមរយៈការលុបបំបាត់អំពើហិង្សាលើកុមារគ្រប់រូបភាព ក្នុងគោលបំណងបង្កើនការយល់ដឹងដល់សាធារណជន អំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់សិទ្ធិកុមារ និងការការពារកុមារ។
- ក្នុងការធ្វើបទបង្ហាញច្បាប់ជាតិ និងអន្តរជាតិ នៅក្នុងកម្មវិធីបណ្តុះបណ្តាល ស្តីពីការធ្វើអាជីវកម្មផ្លូវភេទលើកុមារ នៅរាជធានីភ្នំពេញ រៀបចំដោយសហព័ន្ធនគរបាលអូស្ត្រាលី ដោយមានសិក្ខាកាមនគរបាលជំនាញតាមបណ្តាខេត្ត និងព្រះរាជអាជ្ញា ចំនួន ៤០នាក់ នៅសណ្ឋាគារសូរីតែលភ្នំពេញ។

- **ឯកឧត្តម ឧត្តមសេនីឯក ស៊ុន រ៉ូ អគ្គលេខាធិការរង គ.ជ.ប.ជ** បានអញ្ជើញចូលរួម៖

- ជាវាគ្មិនក្នុងវេទិកាថ្នាក់ជាតិក្រោមប្រធានបទ "**ផលប៉ះពាល់នៃច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មកលើអ្នកប្រកបរបរផ្លូវភេទ**" អ្នកចូលរួមចំនួន ១៥៥នាក់ នៅសាលប្រជុំសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ។
- ជាគ្រូបង្គោលធ្វើបទឧទ្ទេសនាមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់សិក្ខាកាមកងរាជអាវុធហត្ថលេខ៨៦១ ចំនួន ៩០នាក់ (ស្រី ០៤នាក់) នៅមជ្ឈមណ្ឌលជាតិ គ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព និងបោសសំអាតកាកសំណល់សង្រ្គាម។
- ជាគ្រូបង្គោលធ្វើបទឧទ្ទេសនាមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់កងអនុសេនាធំវិស្វកម្មសំណង់លេខ៤៩៥ ចំនួន ១៩៤នាក់ (ស្រី ១០នាក់) នៅសាលាហ្វឹកហ្វឺនបណ្តុះបណ្តាលកងកម្លាំងរក្សាសន្តិភាពពហុជាតិ។
- ជាគ្រូបង្គោលធ្វើបទឧទ្ទេសនាមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់សិក្ខាកាមកងវិស្វកម្មលេខ៣៩៦ ចំនួន ១៨៤នាក់ (ស្រី ១០នាក់) នៅសាលាហ្វឹកហ្វឺនបណ្តុះបណ្តាលកងកម្លាំងរក្សាសន្តិភាពពហុជាតិ។

- **លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ** បានអញ្ជើញចូលរួមជាវាគ្មិន ក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់អង្គការ សម្ព័ន្ធចាប់ដៃ នៅក្នុងប្រធានបទ សកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅប្រទេសកម្ពុជា" នៅមជ្ឈមណ្ឌលព័ន្ធកិច្ចឯកភាពគ្រីស្ទបរិស័ទភ្នំពេញ (ICF) រាជធានីភ្នំពេញ ដែលមានអ្នកចូលរួមចំនួន១៥០នាក់ មកពីអង្គការនានាដែលជាសមាជិករបស់អង្គការចាប់ដៃ។

- **លោកឧត្តមសេនីយ៍ត្រី កែវ សុវណ្ណារ៉ា** ប្រធានក្រុមជំនួយកិច្ចការ បានចូលរួមជាវាគ្មិន ក្នុងសិក្ខាសាលាពង្រឹងសមត្ថភាពក្រុមសីលធម៌ និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់អ្នកអានព័ត៌មានពិធីករ និងពិធីការិនីវិទ្យុ ទូរទស្សន៍ ចំនួន ២១០នាក់ (ស្រី ១០០នាក់) នៅសាកលវិទ្យាល័យអន្តរជាតិ។

- **លោកវរសេនីយ៍ឯក អ៊ិន មាន** ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិនិងអន្តរជាតិ បានចូលរួមធ្វើបទបង្ហាញមួយស្តីពី៖ គម្រោងគ្រប់គ្រងទិន្នន័យនៃការផ្តល់សេវា និងការបញ្ជូន នៅក្នុងវគ្គសិក្ខាសាលាសេវាសង្គមកិច្ចផ្ទាល់នៅកម្ពុជា។ សិក្ខាសាលានេះមានការអញ្ជើញចូលរួមចំនួន ១៣០នាក់ មកពីក្រសួង មន្ទីរពាក់ព័ន្ធ អង្គការជាតិ អង្គការអន្តរជាតិ និងគ្រឹះស្ថានអប់រំ ដែលប្រព្រឹត្តិទៅនៅមជ្ឈមណ្ឌល អាយ ស៊ី អែហ្វ។

- **លោកវរសេនីយ៍ឯក អ៊ិន មាន និងលោកវរសេនីយ៍ទោ អ៊ឹង ហាក់លៀង** សហការធ្វើបទបង្ហាញមួយស្តីពី៖ "ការណែនាំ និងប្រើប្រាស់សាកល្បងកម្មវិធី NCCT Partner Resources ក្នុងទូរស័ព្ទដៃស្មាតហ្វូន និងតាមរយៈកុំព្យូទ័រ" ដែលជាគំរោងរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅភោជនីយដ្ឋានទន្លេបាសាក់២ ដោយមានការចូលរួមពី លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ លោកជំទាវអគ្គលេខាធិការ ឯកឧត្តម-លោកជំទាវអគ្គលេខាធិការរង ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានលេខាធិការដ្ឋាន និងក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ ប្រមាណ ៨០នាក់ ។

- **ថ្នាក់ក្រោមជាតិ**
  - **ខេត្តបាត់ដំបង៖**
    - សមាជិកគណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បានចូលរួមធ្វើជាវាគ្មិន ស្តីពីការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព ក្នុងកិច្ចប្រជុំផ្សព្វផ្សាយរបស់អង្គការដៃគូ នៅក្នុងស្រុកចំនួន ០៥៖
      - ស្រុកថ្មគោល រៀបចំដោយអង្គការ OCE អ្នកចូលរួមចំនួន **៤១**នាក់ (ស្រី **២៦**នាក់)
      - ស្រុកសំឡូត រៀបចំដោយអង្គការ ការីតាស់ អ្នកចូលរួមចំនួន **១៨**នាក់ (ស្រី **១៣**នាក់)
      - ស្រុកកំរៀង រៀបចំដោយអង្គការ ការីតាស់ អ្នកចូលរួមចំនួន **២៥**នាក់ (ស្រី **១០**នាក់)
      - ស្រុកភ្នំព្រឹក រៀបចំដោយអង្គការ ការីតាស់ អ្នកចូលរួមចំនួន **១៧**នាក់ (ស្រី **០៧**នាក់)
      - ស្រុកភ្នំព្រឹក រៀបចំដោយអង្គការ ការីតាស់ អ្នកចូលរួមចំនួន **២១**នាក់ (ស្រី **១២**នាក់)
      - ស្រុកសំពៅលូន រៀបចំដោយអង្គការ ការីតាស់ អ្នកចូលរួមចំនួន **១៨**នាក់ (ស្រី **១៤**នាក់)។
    - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិន ក្នុងវេទិកាផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងឱកាសស្វែងរកការងារ នៅសាលាស្រុកសង្កែ ចំនួន ០១លើក។
  - **ខេត្តក្រចេះ៖** បានចូលរួមជាវាគ្មិន ក្នុងកម្មវិធីបញ្ឈប់អំពើហិង្សាលើស្ត្រី និងកុមារ ក្រោមប្រធានបទ "**អំពើហិង្សា និងការរំលោភសេពសន្ថវៈលើស្ត្រី និងកុមារ**" តាមរយៈការផ្សាយសម្លេង និងការផ្សាយផ្ទាល់តាមគេហទំព័រហ្វេសប៊ុករបស់វិទ្យុសម្លេងស្ត្រីខេត្តក្រចេះ ចំនួន **០៧**លើក។
  - **ខេត្តកំពង់ចាម៖**
    - មន្ទីរព័ត៌មាន មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនក្នុងកម្មវិធី "យើងធ្វើបាន" នៅវិទ្យុFM ៩៩.៧០ MHZ **០១**លើក លើប្រធានបទ ស្តីពីការសម្របសម្រួល និងអន្តរាគមន៍ប្រជាពលរដ្ឋរងគ្រោះដោយការធ្វើចំណាកស្រុកខុសច្បាប់។
    - មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមជាវាគ្មិននៅរាជបណ្ឌិត្យសភាកម្ពុជា ស្តីពីលំហូរពលករទេសន្តរប្រវេសន៍ អត្ថប្រយោជន៍ និងបញ្ហាប្រឈម ចំនួន **០១**លើក។

- មន្ទីរអប់រំយុវជននិងកីឡា មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្នងការដ្ឋាននគរបាល បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិលើប្រធានបទ "អំពើជួញដូរមនុស្ស តាមរយៈការរៀបអាពាហ៍ពិពាហ៍ ជាមួយជនបរទេស"។
- បានចូលរួមជាវាគ្មិននៅស្ថានីយ៍វិទ្យុជាតិភ្នំស្រីភ្នំប្រុស លើប្រធានបទ ស្តីពី "បញ្ហាប្រឈមរបស់ស្ត្រីដែលរៀបការនៅវ័យក្មេង ការស្វែងរកការងារធ្វើក្នុងស្រុក និងការទប់ស្កាត់ចំណាកស្រុកមិនស្របច្បាប់" ចំនួន ០២លើក។

## ខ.២. ការបង្ការ ទប់ស្កាត់ តាមវិធានការជំនាញ

### ខ.២.១. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ

- **ថ្នាក់ជាតិ**
  - **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- ការដំឡើងប្រាក់ឈ្នួលអប្បបរមាដល់កម្មករនិយោជិត ផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង ពី ១៨២ដុល្លាអាមេរិក ដល់១៩០ដុល្លាអាមេរិកក្នុងមួយខែ សម្រាប់ឆ្នាំ២០២០ បូករួមទាំងប្រាក់អត្ថប្រយោជន៍ផ្សេងៗ កម្មករនិយោជិតម្នាក់ៗទទួលបានប្រាក់ឈ្នួលចាប់ពី **២០៧**ដុល្លាអាមេរិក ដល់ **២១៨**ដុល្លាអាមេរិកក្នុងមួយខែ។
- ក្រសួងបានអនុញ្ញាតឱ្យទីភ្នាក់ងារជ្រើសរើសឯកជនចំនួន១០៤ក្រុមហ៊ុន តាមប្រព័ន្ធវជ្ជនិងវជ្ជចំនួន ០១ និងបានកំណត់ឱ្យធ្វើការជ្រើសរើសពលករខ្មែរ មុនបញ្ជូនទៅធ្វើការងារនៅក្រៅប្រទេស ត្រូវធ្វើការបង្ហាត់បង្រៀនភាសា បណ្តុះបណ្តាលជំនាញបឋម របៀបរបបការងារ ច្បាប់ជាធរមានរបស់ប្រទេសទទួលពលករ លក្ខខណ្ឌការងារ លក្ខខណ្ឌរស់នៅ ទំនៀមទំលាប់ប្រពៃណីនៃពលរដ្ឋប្រទេសទទួល ត្រូវរៀបចំឯកសារផ្លូវច្បាប់ ក៏ដូចជាឯកសារបញ្ជាក់ទីកន្លែងធ្វើការដាក់លាក់មុននឹងបញ្ជូនពលករមួយលើកៗ ដោយត្រូវនាំពលករទៅដាក់ឲ្យដល់កន្លែងធ្វើការពិតប្រាកដផងដែរ និងបានអប់រំណែនាំតម្រង់ទិសដល់ពលករមុនពេលចេញដំណើរទៅធ្វើការនៅបរទេស ដូចមានប្រទេស(ថៃ ម៉ាឡេស៊ី សឹង្ហបូរី កូរ៉េខាងត្បូង ជប៉ុន និងប្រទេសអារ៉ាប៊ីសាអូឌីត) សរុបចំនួន **៥៦.៦៩៥**នាក់ (ស្រី **៣២.៣២១**នាក់)។
- បានចុះធ្វើអធិការកិច្ចទីភ្នាក់ងារឯកជនបានចំនួន **៨០**លើក ដើម្បីពង្រឹងសមត្ថភាព និងតម្រង់ទិសការងាររបស់ទីភ្នាក់ងាររបស់ជ្រើសរើសឯកជននីមួយៗ គោរពនិងអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវតាមច្បាប់ និងបទបញ្ញាជាធរមាន ដើម្បីប្រសិទ្ធភាពនៃការការពារ និងលើកកម្ពស់សិទ្ធិពលករខ្មែរនៅក្រៅប្រទេស។
- បានត្រួតពិនិត្យ ផ្សព្វផ្សាយ និងណែនាំ អំពីនីតិវិធីនៃការជ្រើសរើសកម្មករវ័យក្មេង នៅតាមរោងចក្រ សហគ្រាសចំនួន **១៤**លើក និងបានចុះផ្សព្វផ្សាយអំពីគោលការណ៍នៃច្បាប់ក្នុងការប្រើប្រាស់ពលកម្មកុមារចំនួន **១១៤**លើក ដែលមានអ្នកចូលរួមសរុបចំនួន **២.៥៨៥** នាក់ ស្រី **១.៣៣៣**នាក់។
- បានពង្រឹងផ្នែកមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ការងារ ដែលមាននៅក្នុងនាយកដ្ឋាន មុខរបរ និងហត្ថពលកម្ម នៅតាមមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទាំងនៅរាជធានី និងខេត្តទាំង២៤ សម្រាប់ទទួលពិនិត្យ ដោះស្រាយវិវាទពលករទេសន្តរប្រវេសន៍ និងការផ្តល់ប្រឹក្សាយោបល់។
- បានចេញសេចក្តីជូនដំណឹងលេខ០៥៦/១៩ក.ប/ស.ណ.ខ.ល ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការហាមក្មេងចូលទៅក្នុងបរិវេណខ្សែសង្វាក់ផលិតកម្មនៃសិប្បកម្មឡឥដ្ឋ។

- បានចុះសិក្សាប្រសិទ្ធភាពនៃការអនុវត្តក្របខណ្ឌច្បាប់ ពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងវិស័យអប់រំ លើខេត្តត្បូងឃ្មុំ កំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តតាកែវ មាននាយក នាយិកា លោកគ្រូ អ្នកគ្រូចូលរួមចំនួន **១៥០**នាក់ ស្រី **៣៨**នាក់។
- ក្រសួងបានបន្តពង្រឹងយន្តការផ្តល់សេវាមុខរបរ ការងារឱ្យកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋ ដោយបានចុះឈ្មោះអ្នកស្វែងរកការងារចំនួន **១៨.៦៥៦**នាក់(ស្រី **១០.៤៩១**នាក់ និងបានជួយស្វែងរកការងារធ្វើជូនប្រជាពលរដ្ឋតាមរយៈយន្តការផ្គូផ្គងការងារ តាមបច្ចេកវិទ្យាព័ត៌មាន មជ្ឈមណ្ឌលការងារ វេទិកាការងារថ្នាក់ជាតិ ខេត្ត និងតាមមូលដ្ឋាន បានចំនួន **២៧.៦៦៩**នាក់ (ស្រី **១៥.៥៨៣**នាក់)។

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

- បានចុះធ្វើអធិការកិច្ចនៅមណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលមានកិច្ចព្រមព្រៀងជាមួយក្រសួង ស.អ.យ ចំនួន ១២អង្គការ និងមណ្ឌលចំនួន ១៩ ដែលមាននៅរាជធានីភ្នំពេញ ១១មណ្ឌល ខេត្តបន្ទាយមានជ័យ ០១មណ្ឌល បាត់ដំបង ០១មណ្ឌល សៀមរាប ០៥មណ្ឌល និងខេត្តកំពង់ចាម ០១មណ្ឌល។
- បានចុះត្រួតពិនិត្យស្ថានភាពនៃការទទួលជនរងគ្រោះនិងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងពិនិត្យមណ្ឌលរបស់អង្គការដៃគូ នៅខេត្តប៉ៃលិន(ច្រកព្រំ) បាត់ដំបង(ច្រកដូង) បន្ទាយមានជ័យ (ច្រកបោយប៉ែត) កោះកុង(ច្រកចាំយាម) និងខេត្តស្វាយរៀង(ច្រកបាវិត)។
- បានសហការជាមួយអង្គការដៃគូ ចុះតាមដានស្ត្រីពពោះជំនួសចំនួន **១៤**នាក់(ក្នុងចំណោម ស្ត្រីពពោះ **៤៣**នាក់) ដែលមានទីលំនៅរាជធានីភ្នំពេញ **០៥**នាក់ ខេត្តកណ្តាល **០១**នាក់ កំពង់ស្ពឺ **០៣**នាក់ កំពង់ឆ្នាំង **០២**នាក់ ពោធិ៍សាត់ **០១**នាក់ កំពង់ចាម **០១**នាក់ និងខេត្តត្បូងឃ្មុំ **០១**នាក់ ។
- បានសហការជាមួយអង្គការសម្រាលទុក្ខមនុស្សជាតិកម្ពុជា (World Relief Cambodia) ចុះត្រួតពិនិត្យតាមដានការបណ្តុះបណ្តាល ថ្នាក់ឃុំចំនួន០៥ គឺមានឃុំកក់ ពពេល កោងកាង កណ្តោលជ្រុំ និងឃុំដូនតី ក្នុងស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ លើគោលការណ៍ស្តីពី "បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប"។

▪ **ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ** បានការពារជនរងគ្រោះ ផ្តល់សេវាគាំទ្រលើប្រទេសគោលដៅ ស្ថានទូត និងស្ថានអគ្គកុងស៊ុលកម្ពុជា បានធ្វើអន្តរាគមន៍លើករណីរំលោភបំពានដល់ពលករ អំពើហិង្សា ករណីពលករជួបគ្រោះថ្នាក់ការងារ ឬបាត់បង់ជីវិត និងទាមទារប្រាក់សំណងដែលថៅកែមិនបើកឲ្យពលករ ឬបើកឲ្យមិនគ្រប់ចំនួន។ បន្ថែមលើសនេះ ស្ថានតំណាងកម្ពុជា សហការជាមួយអាជ្ញាធរពាក់ព័ន្ធបានចុះសាកសួរសុខទុក្ខ ចុះធ្វើអធិការកិច្ចនៅតាមទីតាំងដែលពលករបំពេញការងារ ផ្សព្វផ្សាយអប់រំពីសិទ្ធិ និងច្បាប់ក្នុងប្រទេសគោលដៅ ក៏ដូចជាដើម្បីបង្កិតសេវាឲ្យកាន់តែខិតទៅជិតពលករ និងទទួលយកសំណូមពរផ្សេងៗរបស់ពួកគាត់ដែលមាន។

▪ **ក្រសួងសុខាភិបាល៖** បានធ្វើសេចក្តីណែនាំជម្រាបដល់មូលដ្ឋានសុខាភិបាលទាំងរដ្ឋ និងឯកជន ដែលកំពុងបម្រើសេវាសុខាភិបាល ដោយមិនអនុញ្ញាតឲ្យធ្វើការផ្សាំ ឬជួញដូរកោសិកា ជាលិកា សរីរាង្គមនុស្ស កោសិកាមេជីវិត (ញី ឬឈ្មោល) តាមលិខិតលេខ ១២៥អបស.មព ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧។

- **ថ្នាក់ក្រោមជាតិ**
  - **ខេត្តកែប៖** មន្ទីរអប់រំ យុវជន និងកីឡាបានសហការជាមួយកម្លាំងប៉ុស្តិ៍រដ្ឋបាល ឃុំ សង្កាត់ បង្កើតក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម។
  - **ខេត្តតាកែវ៖** បានសហការជាមួយ(ប.ស.ស)ខេត្ត ចុះធ្វើអធិការកិច្ចការងារនៅតាមបណ្តារោងចក្រសហគ្រាសទូទាំងខេត្ត ដើម្បីត្រួតពិនិត្យមើលលក្ខខណ្ឌការងារ ការអនុវត្តច្បាប់ ផ្សព្វផ្សាយច្បាប់ស្តីពីការងារការធ្វើចំណាកស្រុក និងផលប៉ះពាល់នៃការធ្វើចំណាកស្រុកខុសច្បាប់នៅតាមបណ្តារោងចក្រសហគ្រាស សិប្បកម្ម ចំនួន **៤៩**លើក អ្នកចូលរួម **៣៤៨**នាក់ ស្រី **២២០**នាក់។
  - **ខេត្តកោះកុង៖** មន្ទីរការងារ សហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី បានចុះស្រាវជ្រាវពិភាក្សា និងចែករំលែកព័ត៌មានសិទ្ធិពលករចំណាកស្រុក បញ្ហាការចំណាកស្រុក អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចពលកម្ម ដល់ក្រុមជួយខ្លួនឯង និងជនបង្គោលក្នុងសហគមន៍ទាំង៥ក្នុងស្រុកមណ្ឌលសីមា និងក្រុងខេមរភូមិន្ទ ចំនួន **១០**លើក អ្នកចូលរួម **២៣៥**នាក់ ស្រី**១៦៧**នាក់។
  - **ខេត្តសៀមរាប៖** មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះអធិការកិច្ចពលកម្មកុមារនៅក្នុងវិស័យឡឥដ្ឋចំនួន ០៣លើក (ក្នុងស្រុកសូទ្រនិគម ស្រុកបន្ទាយស្រី និងស្រុកអង្គរជុំ) បានផ្សព្វផ្សាយពីផលប៉ះពាល់នៃទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ព្រមទាំងបានពិនិត្យលើបច្ចេកទេស និងការប្រើប្រាស់កម្លាំងពលកម្ម ពិសេសពលកម្មកុមារ ហើយក៏បានណែនាំអោយម្ចាស់សិប្បកម្មមានការប្រុងប្រយ័ត្នខ្ពស់ចំពោះកុមារ ដែលធ្វើការនៅក្នុងសិប្បកម្មរបស់ខ្លួន។

### ខ.២.២. វិធានការជំនាញអន្តោប្រវេសន៍

ការគ្រប់គ្រងជនបរទេស មុខសញ្ញាពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្សដែលចូលមកកម្ពុជា

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានរកឃើញមុខសញ្ញាពាក់ព័ន្ធនឹងបទល្មើស៖
  - **ជួញដូរមនុស្ស** ចំនួន០២លើក ដែលមានជនល្មើសចំនួន **០៤**នាក់ ក្នុងនោះជនជាតិវៀតណាម **០៣**នាក់ និងជនជាតិឥណ្ឌា **០១**នាក់(បានបញ្ជូនទៅតុលាការ ករណីកើតឡើងនៅភ្នំពេញ)។
  - **ជួញដូរផ្លូវភេទ** ចំនួន០២លើក ដែលមានជនល្មើសចំនួន **១១**នាក់ ក្នុងនោះជនជាតិចិន **១០**នាក់ និងអង់គ្លេស ០១នាក់ (បានបញ្ជូនទៅតុលាការ ករណីកើតឡើងនៅភ្នំពេញ)។
  - **អំពើអនាចារ** ចំនួន១២លើក ដែលមានជនល្មើសចំនួន **២៣**នាក់ ក្នុងនោះជនជាតិចិន១៧នាក់ អាមេរិក០២, អូស្ត្រាលី០២នាក់, អង់គ្លេស០១នាក់ និងអាល្លឺម៉ង់០១នាក់ (ករណីកើតឡើងនៅភ្នំពេញ ខេត្តសៀមរាប កំពង់ស្ពឺ និងខេត្តកំពត)។
  - **សញ្ចារកម្ម** ចំនួន០២លើក ដែលមានជនល្មើសចំនួន **២៥**នាក់ ក្នុងនោះជនជាតិថៃ **១៥**នាក់ និងចិន **១២**នាក់។

### ខ.២.៣. វិធានការត្រួតត្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិបានធ្វើបច្ចុប្បន្នភាពលើស្ថិតិពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកទៅក្រៅប្រទេសប្រចាំខែនីមួយៗ បានពិនិត្យឃើញថា ការធ្វើចំណាក

ស្រុករបស់ពលរដ្ឋនៅតែបន្តមានជាប្រក្រតី ជាមធ្យមចំនួនពលរដ្ឋដែលអវត្តមានជាប្រចាំពីលំនៅដ្ឋាន មូលហេតុចាកចេញទៅស្នាក់នៅធ្វើការក្នុងប្រទេសគោលដៅ ប្រមាណជា **៣៦០.០០០**នាក់ ក្នុងមួយខែៗ ក្នុងនោះមានស្ត្រីប្រមាណ **១៦៣.០០០**នាក់ **(៤៥.២៧%)** និងកុមារប្រមាណ ៨.៨០០នាក់ (២.៤៤%) ដែលមានអ្នកចេញទៅរកការងារ និងស្នាក់នៅប្រទេសគោលដៅដោយស្របច្បាប់ ប្រមាណ **២១០.០០០**នាក់ **(៥៨.៣៣%)** និងប្រមាណ **៤១.៦៧%** មិនបានចាកចេញដោយស្របច្បាប់ទេ ។

ចំនួនដែលមានក្នុងតារាងខាងក្រោមនេះបញ្ជាក់ថា ប្រជាពលរដ្ឋដែលធ្វើចំណាកស្រុក ទោះបីជាមានការវិលត្រឡប់មកវិញមួយចំនួន ក៏នៅតែមានអ្នកចាកចេញទៅវិញឬថែមទាំងនាំមនុស្សថ្មីទៅជាមួយទៀតផង។ ឯមួយចំនួនតូច បានវិលត្រឡប់មករស់នៅក្នុងស្រុកវិញ និងមួយចំនួន កំពុងតែបាត់ដំណឹងទាក់ទងមិនបាន ដោយមូលហេតុផ្សេងៗ។ ទិន្នន័យនេះក៏អាចបញ្ជាក់បានដែរថា វត្តមានពលករកម្ពុជាដែលនៅក្រៅប្រទេស មានតួលេខប្រចាំខែថេរ តែមនុស្សមានការផ្លាស់ប្តូរដោយសារមានអ្នកត្រឡប់មកវិញដោយមូលហេតុធ្វើការលែងកើត ឬចង់ត្រឡប់មករស់នៅក្នុងស្រុកវិញជួបជុំគ្រួសារ ត្រូវជំនួសដោយមនុស្សថ្មីទៀត ដើម្បីបង្គ្រប់សេចក្តីត្រូវការ រក្សាតួលេខនៃពលករដែលមានក្នុងប្រទេសគោលដៅ ។

***តារាងតាមដានបច្ចុប្បន្នភាពលើទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុក***

| ប្រចាំខែ | សរុបរួម | | | | ស្របច្បាប់ | | | | មិនស្របច្បាប់ | | | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | |
| | | | សរុប | ស្រី | | | សរុប | ស្រី | | | សរុប | ស្រី | |
| មករា | ៣៧១.៥៤៧ | ១៦១.២២៣ | ៩.៣៥៦ | ៣.៥៣២ | ២១០.០៨៥ | ៩៥.៣៩០ | ៦៥៤ | ២៧៧ | ១៦១.៤៦២ | ៦៥.៨៣៣ | ៨.៧០២ | ៣.២៥៥ | កើនឡើង ៦៤ |
| កុម្ភៈ | ៣៦៣.៣៥៧ | ១៥៩.៣៨៧ | ១០.២៨០ | ៣.៨២២ | ២០២.៨៨៤ | ៩៤.០០៨ | ១.៥៧៩ | ៥៦២ | ១៦០.៤៧៣ | ៦៥.៣៧៩ | ៨.៧០១ | ៣.២៦០ | ថយចុះ ៨.១៩០ |
| មីនា | ៣៥៨.៩១៣ | ១៥៩.១៤១ | ១០.៥៥៣ | ៤.០៨៧ | ២០៨.៧២៧ | ៩៤.០២០ | ១.៩២៦ | ៨៦៥ | ១៥០.១៨៦ | ៦៥.១២១ | ៨.៦២៧ | ៣.២២២ | ថយចុះ ៤.៤៤៤ |
| មេសា | ៣៥២.៥៣០ | ១៨៤.៥៩៨ | ៨.៦៤១ | ៣.៤២៥ | ២០៧.៧២៥ | ១២០.០៥៨ | ១.៩៩៥ | ៨៧២ | ១៤៤.៨០៤ | ៦៤.៥៤០ | ៦.៦៤៦ | ២.៥៥៣ | កើនឡើង ៦៥៥ |
| ឧសភា | ៣៥១.៩០៥ | ១៥៥.៤០៦ | ៦.៩៣៤ | ២.៧០២ | ២១០.២៥៩ | ៩២.២៥៨ | ៦៥៦ | ២៧៨ | ១៤១៦៤៦ | ៦៣.១៤៨ | ៦.២៧៨ | ២.៤២៤ | ថយចុះ ៦២៥ |
| មិថុនា | ៣៦០.៤៤២ | ១៥៧.៦៤៥ | ៦.៩១២ | ២.៧១៤ | ២១៩.១៤៣ | ៩៣.៨១២ | ៦៥៧ | ២៧៨ | ១៤១.២៩៩ | ៦៣.៨៣៣ | ៦.២៥៧ | ២.៤៣៦ | កើនឡើង ៨.៥៣៧ |
| កក្កដា | ២៩៩.៥៣៨ | ១២៩.៨៧២ | ៦.០៨១ | ២.៣៧១ | ១៩០.៨៤៤ | ២៩.១៤៣ | ៤៦៦ | ១៧៨ | ១០៨.៥៩៤ | ៥០.៧២៩ | ៥.៦១៥ | ២.១៩៣ | ថយចុះ ៦០.៩០៤ |
| សីហា | ៣៦១.៧១៥ | ១៤៣.២៤២ | ៦.៨៧០ | ២.៧០២ | ២២១.៩១៩ | ៨១.៤៥៧ | ៦៥៨ | ២៧៨ | ១៣៩.៧៩៦ | ៦១.៧៨៥ | ៦.២១២ | ២.៤២៤ | កើនឡើង ៦២.១៧៧ |
| កញ្ញា | ៣៤៥.៥២៨ | ១៣៧.០៤៩ | ៦.៣៣៤ | ២.៤៧២ | ២១៧.៩១២ | ៨២.៧៣៣ | ៦៥៤ | ២៧៨ | ១២៧.៣៧២ | ៥៤.៣១៦ | ៥.៦៨០ | ២.១៩៤ | ថយចុះ ១.៦៤៣ |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| តុលា | ៣៤៣.១៨៧ | ១៣៧.០៤៩ | ៦.៣៣៤ | ២.៤៧២ | ២១៧.៤៩៧ | ៨២.៧៣៣ | ៦៥៤ | ២៧៨ | ១២៥.៦៩០ | ៥៤.៣១៦ | ៥.៦៨០ | ២.១៩៤ | ថយចុះ ២.០៩៧ |
| វិច្ឆិកា | ៣៤៦.៤១០ | ១៤៨.២២៧ | ៥.៦៧១ | ២.២៥២ | ២២១.១១៦ | ៩៨.០០១ | ៦៦២ | ២៨២ | ១២៥.២៩៤ | ៥០.២២៦ | ៥.០០៩ | ១.៩៧០ | កើនឡើង ៣២.២៣ |
| ធ្នូ | ៣៥៧.៧៩១ | ១៥៩.២៤៣ | ៦.៧៤២ | ២.៧១៤ | ២៣១.៦០៨ | ១០៨.៣៨៩ | ១.៧៨៣ | ៧៥៤ | ១២៦.១៨៣ | ៥០.៨៥៤ | ៤.៩៥៩ | ១.៩៦០ | កើនឡើង ១១.៣៨១ |

- **ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន វរៈសេនាតូចលេខ ៨១៥ បានធ្វើការទប់ស្កាត់ពលរដ្ឋខ្មែរ ឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់ ចំនួន **១៧**លើក មនុស្ស**១៣០**នាក់(ស្រី**៥៥**នាក់) អនីតិជន**០៩**នាក់ ដោយបានធ្វើការអប់រំ និងណែនាំឱ្យត្រឡប់ទៅលំនៅដ្ឋានវិញ។
- **ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែនរបស់វរៈនគរបាលការពារព្រំដែនគោក វរៈសេនាតូចលេខ ៨១៧ ៨១៩ ៨២៣ និង៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួនបានចំនួន **៧៥២**លើក បានទប់ស្កាត់ពលរដ្ឋដែលបំរុងឆ្លងដែនខុសច្បាប់ចំនួន **០៣**លើក ឃាត់ខ្លួន **១៦**នាក់ ស្រី**០២**នាក់។
- **ស្នងការដ្ឋាននគរបាលខេត្តរតនគិរី៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែនរបស់វរៈនគរបាលការពារព្រំដែនគោក បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួន ចំនួន **១៨៣**លើក (ព្រំដែនកម្ពុជា វៀតណាម **១៥២**លើក និងព្រំដែនកម្ពុជា ឡាវ **៣១**លើក) ដើម្បីទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់។

### ខ.២.៤. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

**អគ្គស្នងការដ្ឋាននគរបាលជាតិ៖** នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត១៣ (ខេត្តតាកែវ កំពង់ឆ្នាំង កែប មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង កំពង់ចាម ឧត្តរមានជ័យ រតនគិរី កោះកុង បន្ទាយមានជ័យ សៀមរាប និងខេត្តស្វាយរៀង) បានធ្វើសកម្មភាពបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមគោលដៅបម្រើសេវាកំសាន្តដែលអាចបង្កប់សេវាផ្លូវភេទ ដោយចុះធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា និងខារ៉ាអូខេ ដូចមានតារាងខាងក្រោម៖

*តារាងបច្ចុប្បន្នភាពគោលដៅសេវាកំសាន្ត ដែលបានធ្វើការអប់រំដើម្បីបង្ការ ទប់ស្កាត់*
*អំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ក្នុងឆ្នាំ២០១៩*

| បរិយាយ | ខែមករា | ខែកុម្ភៈ | ខែមីនា | ខែមេសា | ខែឧសភា | ខែមិថុនា | ខែកក្កដា | ខែសីហា | ខែកញ្ញា | ខែតុលា | ខែវិច្ឆិកា | ខែធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំនួនគោលដៅ | ៥៦៣ | ៥៥១ | ៤៦៩ | ៤៤៣ | ៣១០ | ២៨០ | ៥២១ | ៥៥២ | ៤៨៧ | ៥២១ | ៤៣៥ | ៥៩៧ |
| ចំនួនមនុស្ស | ២.២៤២ | ៣.១៩៧ | ១.៩៣៥ | ២.៣៤៣ | ១.៣០៤ | ១.១៥២ | ២.២១០ | ២.៣២៧ | ៧.២៥០ | ១២.២៨៨ | ១.៩៥៩ | ២.៣៦៩ |
| ចំនួនស្ត្រី | ១.៣៩៧ | ២.២៩២ | ១.៦២០ | ១.៩២៧ | ១.០៩២ | ៩៥០ | ១.៩៩៣ | ១.៧៤៦ | ៤.៧១២ | ៥.០៣៧ | ១.៤១៧ | ១.៧៣៩ |

*ក្នុងនោះ៖*

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ធ្វើបច្ចុប្បន្នភាពគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួន **៧៥**គោលដៅ ក្នុងនោះអំពើជួញដូរមនុស្សចំនួន **០៩**គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន **៦៦**គោលដៅ។

- ស្នងការដ្ឋាននគរបាលខេត្ត បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន **៣៨៦**លើក នៅខេត្តក្រចេះ ស្ទឹងត្រែង ព្រះវិហារ ពោធិ៍សាត់ តាកែវ កំពង់ស្ពឺ ស្វាយរៀង និងខេត្តព្រៃវែង។

*ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ*

| ស្នងការដ្ឋានរាជធានី-ខេត្ត | ឆ្នាំ២០១៩ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| | ៣៥លើក | ៣៩លើក | ៣៣លើក | ២២លើក | ៤៦លើក | ៣៤លើក | ១៨លើក | ៣៩លើក | ៣៤លើក | ៣៥លើក | ១៨លើក | ៣៣លើក |
| សរុប | ៣៨៦ លើក | | | | | | | | | | | |

### ខ.២.៩. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរូបភាពអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

ក្នុងឆ្នាំ២០១៩នេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួលសំណើសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន **២.៦៤១**គូ ក្នុងនោះមានតែចំនួន **២.០១៦**គូប៉ុណ្ណោះ ដែលត្រូវបានក្រសួងមហាផ្ទៃ ចេញសេចក្តីជូនដំណឹងអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ ស្របតាមផ្លូវច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ក្រុមការងារជំនាញរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទំនាក់ទំនងសាកសួរព័ត៌មានអំពីនារីខ្មែរដែលទៅរស់នៅជាមួយស្វាមីនៅក្រៅប្រទេស បានចំនួន **១៦៨**នាក់ ដើម្បីតាមដានស្ថានភាពដែលសង្ស័យថា អាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

## ខ.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

**▪ខេត្តសៀមរាប៖**

- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះអធិការកិច្ចពលកម្មកុមារ នៅក្នុងវិស័យឡឥដ្ឋ ចំនួន ០៣លើក នៅស្រុកសូទ្រនិគម ស្រុកបន្ទាយស្រី ស្រុកក្រឡាញ់ ស្រុកជីក្រែង និងស្រុកអង្គរជុំ ដោយក្រុមការងារបានចែកជូនសេចក្តីប្រកាសព័ត៌មាន ស្តីពីករណីគ្រោះថ្នាក់ក្នុងសិប្បកម្មផលិតឥដ្ឋ និងផ្សព្វផ្សាយផលប៉ះពាល់ នៃទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ បានពិនិត្យទៅលើបច្ចេកទេស និងការប្រើប្រាស់កម្លាំងពលកម្ម (ពិសេសពលកម្មកុមារ) បន្ទាប់មកបានធ្វើការណែនាំដល់ម្ចាស់សហគ្រាសឲ្យមាន ការប្រុងប្រយ័ត្នចំពោះកុមារដែលធ្វើការនៅក្នុងទីតាំងឡឥដ្ឋរបស់ខ្លួន។
- មន្ទីរទេសចរណ៍ខេត្ត បាន (១)ចុះធ្វើបច្ចុប្បន្នភាពក្រុមនារីបម្រើការងារនៅតាមមូលដ្ឋានអាជីវកម្ម ផ្ទះសំណាក់ និងសណ្ឋាគារ ចំនួន ០៦លើក (២)ចុះត្រួតពិនិត្យការបិទបំរាមអំពីការជួញដូរកុមារ ឬការនាំកុមារមិនទាន់គ្រប់អាយុចូលក្នុងបន្ទប់ស្នាក់នៅ (ករណីមិនមែនអាណាព្យាបាល) ចំនួន **២២**កន្លែង (៣)ចុះត្រួតពិនិត្យខារ៉ាអូខេ ចំនួន ០៦កន្លែង។
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ និងវិធានការចំពោះសហគ្រាសដែលប្រព្រឹត្តល្មើសច្បាប់ស្តីពីការងារ រួមមាន អធិការកិច្ចសាមញ្ញ ចំនួន ០៣សហគ្រាស និងអធិការកិច្ចពិសេស ចំនួន ០៤សហគ្រាស។
- ស្នងការដ្ឋាននគរបាលខេត្ត បានចុះត្រួតពិនិត្យ និងស៊ើបអង្កេតតាមសិប្បកម្មផលិតឥដ្ឋ ស្តីពី ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ និងប្រមូលកុមារដែលងាយរងគ្រោះ នៅស្រុកសូទ្រនិគម និងស្រុកក្រឡាញ់ បានចំនួន ០៥នាក់(ស្រី០២នាក់) និងបានប្រគល់អោយគ្រួសារ ០២នាក់ មន្ទីរសង្គមកិច្ច ០៣នាក់។

- **ខេត្តកំពង់ធំ៖**
  - មន្ទីរ**សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**ខេត្ត បានចុះអធិការកិច្ច វាយតម្លៃកន្លែងថែទាំជំនួសចំពោះកុមារកំព្រាងាយរងគ្រោះដោយអំពើហឹង្សា ការធ្វើចំណាកស្រុក ការជួញដូរ ការរំលោភ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងទីទ័លក្រ បានចំនួន **៣១**កន្លែង កុមារ **៨៩២**នាក់ (ស្រី **៤៥២**នាក់) ក្នុងនោះ៖
    - ○ មណ្ឌលថែទាំកុមាររដ្ឋ ចំនួន **១០**មណ្ឌល កុមារ **៣៨៩**នាក់ (ស្រី **១៨០**នាក់)
    - ○ កន្លែងថែទាំសហគមន៍ ចំនួន **១៧**កន្លែង កុមារ **២៨៩**នាក់ (ស្រី **១៣២**នាក់)
    - ○ កន្លែងអន្តេវាសិកដ្ឋានរដ្ឋ ចំនួន **០៣**កន្លែង កុមារ **២១១**នាក់ (ស្រី **១៣៩**នាក់)
    - ○ ផ្ទះសហគមន៍គ្រួសារធម៌ ចំនួន **០១**កន្លែង កុមារ **០៣**នាក់ (ស្រី **០១**នាក់)។
- **ខេត្តព្រះសីហនុ** ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ សហការជាមួយអង្គការម្លប់តាប៉ាង ដើម្បីការពារសុវត្ថិភាពកុមារ បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ និងផ្នែកភ្នាក់ងារទេសចរណ៍ សរុបចំនួន **១.១៣៣**នាក់។
- **ខេត្តរតនគិរី** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចសាមញ្ញចំនួន **២៤**លើក ចុះធ្វើអធិការកិច្ចពិសេស **០៩**លើក និងអធិការកិច្ចពិសេសក្រៅកម្មវិធី **០២**លើក ក្នុងគោលបំណងពិនិត្យលើការងារអនុវត្តច្បាប់ ស្តីពី ការងារ និងការបង្ការការប្រើប្រាស់កម្លាំងពលកម្មខុសច្បាប់ និងការប្រើប្រាស់ពលកម្មកុមារ។
- **ខេត្តស្វាយរៀង** កម្លាំងអធិការដ្ឋាននគរបាលក្រុងបាវិតបានចុះស្រង់ទិន្នន័យគោលដៅ និងធ្វើកិច្ចសន្យានៅតាមគោលដៅរោងចក្រ សហគ្រាស សិប្បកម្ម ដែលសង្ស័យអាចពាក់ព័ន្ធការកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារចំនួន **២០**លើក ស្មើ **៨៨**គោលដៅ មានកម្មករសរុបចំនួន **៨០.០៩៣**នាក់(នីតិជនទាំងអស់) និងបានណែនាំ ធ្វើកិច្ចសន្យាដល់ម្ចាស់សិប្បកម្មទាំងអស់កុំឲ្យទទួលយកកុមារ(អនីតិជន)មកធ្វើការ។
- **ខេត្តប៉ៃលិន** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះអធិការកិច្ច ដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថាន ដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា រោងសម្ងួត និងថ្លឹងកសិផល កាស៊ីណូ ឡតដ្ឋ ភោជនីយដ្ឋាន និងអាហារដ្ឋាន ចំនួន **៨០**កន្លែង។
- **ខេត្តក្រចេះ** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បាន៖
  - ○ បានសហការជាមួយអង្គការភូមិកុមារកម្ពុជា SOS ទទួលកុមារមករស់នៅសរុបចំនួន **៩៥**នាក់។
  - ○ បានផ្តល់អាហារូបត្ថម្ភ និងសម្ភារសិក្សាដល់កុមារក្នុងសហគមន៍ ចំនួន **៤០០**នាក់។
  - ○ ចុះត្រួតពិនិត្យមណ្ឌលអង្គការដំណឹងល្អទាំង៨មានកុមារ ចំនួន **១៧**នាក់ (កុមារី **០៥**នាក់)។
- **ខេត្តកំពង់ចាម៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះអធិការកិច្ចត្រួតពិនិត្យ និងទប់ស្កាត់ពលកម្មកុមារបានចំនួន **៤៤**សហគ្រាស មានកុមារ **២០០**នាក់ (កុមារី **៨៨**នាក់)។
- **ខេត្តតាកែវ៖**
  - ○ លោកស្រីអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានដឹកនាំមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ត្រួតពិនិត្យលើពលកម្មកុមារ នៅវិស័យឡឥដ្ឋ ចំនួន **០១**លើក។
  - ○ មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ នៅតាមឧបណ្តារោងចក្រ សហគ្រាស ដើម្បីត្រួតពិនិត្យមើលលក្ខខ័ណ្ឌការងារ ការអនុវត្តច្បាប់ស្តីពីការងារ និងផ្សព្វផ្សាយ ច្បាប់ស្តីពីការធ្វើចំណាកស្រុក និងផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយខុសច្បាប់ សរុបចំនួន **០២**លើក អ្នកចូលរួមចំនួន **៤៥**នាក់ (ស្រី **៣៥**នាក់)។

- **ខេត្តកែប៖** មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានបង្កើតក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្ម ពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដែលមានសមាសភាពពាក់ព័ន្ធចំនួន **១១**នាក់ (ស្រី **០១**នាក់) ។
- **ខេត្តកោះកុង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ និងផ្សព្វផ្សាយអប់រំដល់កម្មករ និយោជិក និងនិយោជក ចំនួន **០៣**លើក។

## ខ.៤. ការលើកកម្ពស់ជីវភាព

**ខេត្តសៀមរាប** ស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយអង្គការសេដាក ផ្សព្វផ្សាយ កសិករឱ្យយល់ដឹងអំពីការជួញដូរមនុស្ស ការជួញដូរកម្លាំងពលកម្ម ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងបណ្តុះបណ្តាលការងារធ្វើកសិកម្មធម្មជាតិជាលក្ខណៈគ្រួសារ នៅក្នុងស្រុកគោលដៅចំនួន**០៦** (ស្រុកស្រីស្នំ វ៉ារិន្ទ សូទ្រនិគម ជីក្រែង អង្គរជុំ និងស្រុកពួក) មាន **១១**ឃុំ និង **៦១**ភូមិ សរុបបាន **៤៧**លើក អ្នកចូលរួមចំនួន **១៦៥**នាក់(ស្រី **៩៥**នាក់)។

## ខ.៥. ការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

ទីភ្នាក់ងារជ្រើសរើសឯកជន ដែលមានអាជ្ញាប័ណ្ណ និងការជ្រើសរើសតាមប្រព័ន្ធ អនុគ្រោះមុខរបរ Employment Permit System (EPS) របស់រាជរដ្ឋាភិបាលកម្ពុជា និងបានបញ្ជូនពលករទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេស សរុបចំនួន **៦៨.០៤០**នាក់ (ស្រី **២៨.២០១**នាក់) ក្នុងនោះ៖

| | | |
|---|---|---|
| - ប្រទេសថៃឡង់ដ៍ | ចំនួន **៥៧.៨២៣**នាក់ | (ស្រី **២៤.៩៨៩**នាក់) |
| - ប្រទេសជប៉ុន | ចំនួន **៣.៩៤៥**នាក់ | (ស្រី **១.៧៤៤**នាក់) |
| - ប្រទេសសឹង្ហបូរី | ចំនួន **១៣៥**នាក់ | (ស្រី **១៣៥**នាក់) |
| - តំបន់រដ្ឋបាលពិសេសហុងកុង | ចំនួន **៧២**នាក់ | (ស្រី **៧២**នាក់) |
| - ប្រទេសអារ៉ាប៊ីសាអូឌីត | ចំនួន **៥៨**នាក់ | (ស្រី **៥៨**នាក់) |
| - ប្រទេសម៉ាឡេស៊ី | ចំនួន **៦៩**នាក់ | (ស្រី **៣៣**នាក់) |

➢ **ជាពិសេសប្រទេសកូរ៉េតាមប្រព័ន្ធអនុគ្រោះមុខរបរ (EPS)** ចំនួន **៥.៩៣៨**នាក់ (ស្រី **១.១៧០**នាក់)។

## ខ.៦. ការផ្តល់ប័ណ្ណព្រំដែនដល់ប្រជាជនចល័តឆ្លងកាត់ព្រំដែន

ដើម្បីសម្រួលដល់ការឆ្លងដែនស្របច្បាប់ របស់ប្រជាជនដែលចល័តឆ្លងកាត់ព្រំដែនរយៈពេលខ្លី រដ្ឋបាលខេត្តចំនួន**០៣** គឺខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ (Border Pass) សរុបចំនួន **៨២.២៥០**ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មាន៖

| | | |
|---|---|---|
| ○ ខេត្តបាត់ដំបង | ចំនួន | **៥៧.៧៧៧**ប័ណ្ណ |
| ○ ខេត្តបន្ទាយមានជ័យ | ចំនួន | **១០.៤៤៨**ប័ណ្ណ |
| ○ ខេត្តប៉ៃលិន | ចំនួន | **១៤.០២៤**ប័ណ្ណ។ |

# គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

## គ.១. ការអនុវត្តច្បាប់

❖ តាមរបាយការណ៍ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដែលប្រមូលបានពីជំនាញរបស់នាយកដ្ឋាន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ទូទាំងប្រទេស

បានបង្ហាញអំពីលទ្ធផលនៃការបង្ក្រាបបទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ថា មានភាពប្រសើរជាងមុន បើប្រៀបធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០១៨។

### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានីខេត្ត**២២** បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបានចំនួន **១៦៩/១៣៤**ករណី កើន **៣៥**ករណី ស្មើ**២៦,១១%** ឃាត់ខ្លួនជនសង្ស័យបានចំនួន **២២៩/២២៤នាក់** (ស្រី**៧២**នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន**១១**នាក់ និងជនបរទេស ចំនួន**៤០**នាក់ មាន**០៧**សញ្ជាតិ (សញ្ជាតិអូស្ត្រាលី**០២**នាក់ រុស្ស៊ី**០១**នាក់ អង់គ្លេស**០២**នាក់ ថៃ**០១**នាក់ ចិន**២៩**នាក់ អាមេរិក**០៤**នាក់ និងឥណ្ឌា**០១**នាក់ )។

សង្គ្រោះជនរងគ្រោះបាន ចំនួន**៤៥៦/២៣០**នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំ**១៤១**នាក់ អាយុ១៥-១៧ឆ្នាំ**៥៥**នាក់ និងអាយុ១៨ឆ្នាំឡើង**២៦០**នាក់ (ប្រគល់មន្ទីរសង្គមកិច្ចចំនួន**១៦៥**នាក់ និងប្រគល់ឲ្យគ្រួសារវិញចំនួន**២៩១**នាក់។

***បែកចេញជា៖***

#### *១. ករណីអំពើជួញដូរមនុស្ស*

បង្ក្រាបបាន **៣៨/៣៩**ករណី ជនសង្ស័យ **៦១**នាក់(ស្រី**៣៨**នាក់) អនីតិជន**០១**នាក់ ជនបរទេស **០៦**នាក់ និងសង្គ្រោះជនរងគ្រោះបានចំនួន**១៥១**នាក់។

| ល.រ | បរិយាយ | ករណី | ជនសង្ស័យ | សញ្ជាតិ |
|---|---|---|---|---|
| ១ | ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០៣ | ០៣ | |
| ២ | ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០៩ | ១១ | ឥណ្ឌា ០១នាក់ |
| ៣ | ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១០ | ១៥(អនីតិជន០១នាក់) | |
| ៤ | ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ | ០១ | |
| ៥ | អំពើលក់ដូរមនុស្ស | ០១ | ០១ | |
| ៦ | អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ០៨ | ២៤ | ចិន ០១នាក់ |
| ៧ | អំពើនាំឆ្លងដែន | ០១ | ០១ | |
| ៨ | ការទិញពេស្យាចារកុមារ | ០៥ | ០៥ | រុស្ស៊ី ០១នាក់<br>អាមេរិក ០២នាក់<br>អូស្ត្រាលី ០១នាក់ |
| សរុប | | ៣៨ | ៦១នាក់(អនីតិជន០១នាក់) | ០៦នាក់ |

***ជនរងគ្រោះដោយអំពើជួញដូរមនុស្ស***

| ចំនួនជនរងគ្រោះសរុប | អាយុក្រោម ១៥ឆ្នាំ | ពី១៥ឆ្នាំដល់ ១៧ឆ្នាំ | អាយុ១៨ឆ្នាំ ឡើង | ការបញ្ជូនជនរងគ្រោះ | | |
|---|---|---|---|---|---|---|
| | | | | ទៅមន្ទីរស/ក | ទៅអង្គការ | ទៅគ្រួសារ |
| ១៥១ | ៣២ | ៣០ | ៨៩ | ៣៥ | ០០ | ១១៦ |

### ២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបានចំនួន **១៣១/៩៥**ករណី ជនសង្ស័យ **១៦៨**នាក់(ស្រី**៣៤**នាក់) អនីតិជន**១០**នាក់ ជនបរទេស **៣៤**នាក់ និងសង្គ្រោះជនរងគ្រោះបានចំនួន **៣០៥**នាក់។

| ល.រ | បរិយាយ | ករណី | ជនសង្ស័យ | សញ្ជាតិ |
|---|---|---|---|---|
| ១ | សញ្ចារកម្ម | ១៥ | ២៧ | ចិន ១៥ |
| ២ | សញ្ចារកម្ម(មានអនីតិជន) | ០៩ | ១២ | |
| ៣ | ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | ០១ | ០៧ | ចិន ០៧ |
| ៤ | ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ០១ | ០៥ | ចិន ០៥ |
| ៥ | សញ្ចារកម្ម(ទាក់ទងនឹងពេស្យាចារកុមារ) | ០៨ | ១២ | អូស្ត្រាលី០១<br>អង់គ្លេស០១ |
| ៦ | ការដឹកនាំគ្រឹះស្ថានពេស្យាចារ | ០១ | ០២ | |
| ៧ | ការផ្ដល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ០៤ | ១០ | ថៃ០១ |
| ៨ | រូបភាព និងសម្ភារៈអាសអាភាស | ០១ | ០១ | |
| ៩ | អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៥៧ | ៥៨(អនីតិជន ០៧នាក់) | ចិន ០១ |
| ១០ | អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ៣៤ | ៣៤(អនីតិជន ០៣នាក់) | អង់គ្លេស០១<br>អាមេរិក ០២ |
| **សរុប** | | **១៣១** | **១៦៨នាក់**(អនីតិជន១០នាក់) | **៣៤នាក់** |

### ជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទ

| ចំនួនជនរងគ្រោះសរុប | អាយុក្រោម ១៥ឆ្នាំ | ពី១៥ឆ្នាំដល់ ១៧ឆ្នាំ | អាយុ១៨ឆ្នាំឡើង | ការបញ្ជូនជនរងគ្រោះ | | |
|---|---|---|---|---|---|---|
| | | | | ទៅមន្ទីរស/ក | ទៅអង្គការ | ទៅគ្រួសារ |
| ៣០៥ | ១០៩ | ២៥ | ១៧១ | ១៣០ | ០០ | ១៧៥ |

### គ.១.២. ការកសាងសំណុំរឿង និងជនសង្ស័យបទល្មើសជួញដូរមនុស្ស បញ្ជូនទៅតុលាការ

#### តារាងបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទឆ្នាំ២០១៩

| ល.រ | អំពើ | មាត្រា | ចំនួនករណី | | ចំនួនជនសង្ស័យ | | ចំនួនជនរងគ្រោះ | |
|---|---|---|---|---|---|---|---|---|
| | | | ជួញដូរមនុស្ស | អាជីវកម្មផ្លូវភេទ | ជួញដូរមនុស្ស | អាជីវកម្មផ្លូវភេទ | ជួញដូរមនុស្ស | អាជីវកម្មផ្លូវភេទ |
| ១ | ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ៩* | ៣ | | ៣ | | ៤ | |
| ២ | ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ១០* | ៩ | | ១១ | | ៦៣ | |
| ៣ | ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១១* | ១០ | | ១៥ | | ៤៩ | |
| ៤ | ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ចន៍ | ១២* | ១ | | ១ | | ៥ | |
| ៥ | អំពើលក់ដូរមនុស្ស | ១៤* | ១ | | ១ | | ២ | |
| ៦ | អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ១៦* | ៨ | | ២៤ | | ៦ | |
| ៧ | អំពើនាំឆ្លងដែន | ១៨* | ១ | | ១ | | ៥ | |
| ៨ | ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ២១* | | ១ | | ៥ | | ១ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៩ | សញ្ចារកម្ម | ២៦* | | ១៥ | | ២៧ | | ៦៤ |
| ១០ | សញ្ចារកម្ម (មានអនីតិជន) | ២៦* | | ៩ | | ១២ | | ៥៥ |
| ១១ | ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | ២៧* | | ១ | | ៧ | | ២៧ |
| ១២ | សញ្ចារកម្ម( ទាក់ទងនឹងពេស្យាចារកុមារ ) | ២៨* | | ៨ | | ១២ | | ៣០ |
| ១៣ | ការដឹកនាំគ្រឹះស្ថានពេស្យាចារ | ៣១* | | ១ | | ២ | | ២ |
| ១៤ | ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ៣២* | | ៤ | | ១០ | | ២២ |
| ១៥ | ការទិញពេស្យាចារកុមារ | ៣៤* | ៥ | | ៥ | | ១៧ | |
| ១៦ | រូបភាព និងសម្ភារៈអាសអាភាស | ៣៩* | | ១ | | ១ | | ១ |
| ១៧ | អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤២* | | ៥៧ | | ៥៨ | | ៦២ |
| ១៨ | អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤៣* | | ៣៤ | | ៣៤ | | ៤១ |
| | សរុប | | ៣៨ | ១៣១ | ៦១ | ១៦៨ | ១៥១ | ៣០៥ |
| | សរុបរួម | | ១៦៩ ករណី | | ២២៩ នាក់ | | ៤៥៦ នាក់ | |

ក្រាហ្វិកប្រៀបធៀបបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៨-២០១៩




➢ *ដោយឡែក*

❖ **តាមរបាយការណ៍ពីនាយកដ្ឋានអន្តោប្រវេសន៍** បានកសាងសំណុំរឿងបញ្ជូនជនបរទេសពាក់ព័ន្ធបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទទៅតុលាការចំនួន **១៨** លើក មនុស្ស **៦៥** នាក់ ស្មើនឹង ០៨ សញ្ជាតិ ដែលមាននៅក្នុងតារាងខាងក្រោម៖

| ល.រ | បរិយាយ | ករណី | ជនសង្ស័យ | សញ្ជាតិ |
|---|---|---|---|---|
| ១ | អំពើអនាចារ | ១២ | ២៣ | ចិន១៧, អាមេរិក២, អូស្ត្រាលី២, អង់គ្លេស១ និងអាល្លឺម៉ង់១ (កើតឡើងនៅ ភ្នំពេញ.សៀមរាប.កំពង់ស្ពឺ និងកំពត)។ |
| ២ | សញ្ចារកម្ម | ២ | ២៧ | ថៃ១៥ និងចិន១២។ |
| ៣ | ជួញដូរផ្លូវភេទ | ២ | ១១ | ចិន១០ និងអង់គ្លេស១ (ភ្នំពេញ)។ |
| ៤ | ជួញដូរមនុស្ស | ២ | ៤ | វៀតណាម៣ និងឥណ្ឌា១ ។ |
| | សរុប | ១៨ | ៦៥ | |

## គ.២. កិច្ចការយុត្តិធម៌

### គ.២.១. លទ្ធផលចំណាត់ការផ្តន្ទាទោស

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ ដូចមានក្នុងតារាងលម្អិតខាងក្រោម៖

*១. ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ៖*

ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន **១៩៩/១៥៤**ករណី ជនរងគ្រោះចំនួន **២៤៩/១៨៣**នាក់ (ស្រី **២០៩**នាក់) អនីតិជន **១២១/១០២**នាក់(ស្រី **១០៥**នាក់) ជនត្រូវចោទមានចំនួន **២២០/១៩៦**នាក់ (ស្រី **៤៤**នាក់) អនីតិជន **២១**នាក់(ស្រី **០១**នាក់) ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន **១៣៤**ករណី តម្កល់ទុកឥតចាត់ការ (០០ករណី) និងកំពុងចាត់ការចំនួន **៦៥** ករណី៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់អយ្យការអមសាលាដំបូង*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនល្មើស | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | តម្កល់ទុកឥតចាត់ការ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | |
| សរុប | ២៤ | ១០៤ | ១៦ | ១០៥ | ១៥៦ | ៤៣ | ២០ | ១ | ១៣៤ | ០ | ៦៥ |
| ១៩៩ | ១២៨ នាក់ | | ១២១ នាក់ | | ១៩៩ នាក់ | | ២១ នាក់ | | ១៩៩ ករណី | | |

*២. ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត ៖*

ចំណាត់ការរបស់ចៅក្រមស៊ើបសួររាជធានី-ខេត្ត សរុបមានចំនួន **២០៧/៤២០**ករណី ជនរងគ្រោះចំនួន **២៦៧/៥២៣**នាក់(ស្រី **២១៣**នាក់) អនីតិជន **១៥៩/៣០៧**នាក់ (ស្រី **១០៨**នាក់) ជនត្រូវចោទមានចំនួន **២៦១ /៥៣៨**នាក់ (ស្រី **៥០**នាក់) អនីតិជន **៣១**នាក់(ស្រី **០១**នាក់) នៅក្នុងឃុំចំនួន **២២១**នាក់(ស្រី **៣៧**នាក់) អនីតិជន **០៧**នាក់ នៅក្រៅឃុំចំនួន **៤០**នាក់(ស្រី **១៣**នាក់) អនីតិជន **២៤**នាក់(ស្រី**០១**នាក់) និងបានចំណាត់ការបញ្ជូនទៅជម្រះចំនួន **៦៣**ករណី លើកលែងចោទគ្មាន និងកំពុងចាត់ការចំនួន **១៤៤**ករណី៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមស៊ើបសួរ៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | នៅក្នុងឃុំ | | | | នៅក្រៅឃុំ | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | ជូនទៅជម្រះ | លើកលែងចោទ | កំពុងចាត់ការ |
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | | | |
| សរុប | ២៦ | ១០៥ | ២៨ | ១០៨ | ១៨១ | ៤៩ | ៣០ | ១ | ១៧៧ | ៣៧ | ៧ | ០ | ៤ | ១២ | ២៣ | ១ | ៦៣ | ០ | ១៤៤ |
| ២០៧ | ១៣១ នាក់ | | ១៣៦ នាក់ | | ២៣០ នាក់ | | ៣១ នាក់ | | ២២១ នាក់ | | | | ៤០ នាក់ | | | | ២០៧ ករណី | | |

*៣. ចំណាត់ការរបស់ចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត៖*

ចំណាត់ការរបស់ចៅក្រមជំនុំជម្រះរាជធានី-ខេត្ត សរុបមានចំនួន **១៦៦/២១៤**ករណី ជនរងគ្រោះចំនួន **២៣៥/២៧៣**នាក់(ស្រី **២០៦**នាក់) អនីតិជន **១៥៨/១១៤**នាក់(ស្រី **១៣៦**នាក់) ជនជាប់ចោទសរុប **២២៥/**

២៥៣នាក់(ស្រី ៣៨នាក់) និងប្រភេទចំណាត់ការ(ទោសព្យួរគ្មាន ពិន័យជាប្រាក់គ្មាន រួចផុតពីបទចោទគ្មាន រំលត់បណ្តឹងអាជ្ញាគ្មាន ចាត់ការរួច ៦៣ករណី ផ្តន្ទាទោសដាក់ពន្ធនាគារក្នុងឃុំ ១៤០នាក់ នៅក្រៅឃុំ ៣០នាក់ និង កំពុងចាត់ការ ១០៣ករណី)៖

### *តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមជំនុំជម្រះ*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនជាប់ចោទ | | ប្រភេទចំណាត់ការ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | | | ទោសព្យួរ | ពិន័យជាប្រាក់ | រួចផុតពីបទចោទ | រំលត់បណ្តឹងអាជ្ញា | ចាត់ការរួច | ផ្តន្ទាទោសពន្ធនាគារ | | កំពុងចាត់ការ |
| | | | | | | | | | | | | ក្នុងឃុំ | ក្រៅឃុំ | |
| | ប | ស | ប | ស | ប | ស | | | | | | | | |
| សរុប | ៧ | ៧០ | ២២ | ១៣៦ | ១៨៧ | ៣៨ | គ្មាន | គ្មាន | គ្មាន | គ្មាន | ៦៣ | ១៤០ | ៣០ | ១០៣ |
| ១៦៦ | ៧៧ នាក់ | | ១៥៨ នាក់ | | ២២៥ នាក់ | | | | | | ករណី | នាក់ | នាក់ | ករណី |

ក្រាហ្វិកប្រៀបធៀបចំណាត់ការរបស់ចៅក្រមជំនុំជម្រះ ឆ្នាំ២០១៨-២០១៩




## គ.៣.ការដោះស្រាយករណីវិវាទរវាងពលករទេសន្តរប្រវេសន៍ និងបណ្តាក្រុមហ៊ុននានា

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

បានទទួលនិងដោះស្រាយវិវាទផ្នែកទេសន្តរប្រវេសន៍ ចំនួន ២០ក្រុមហ៊ុន មានសំណុំរឿងចំនួន ២៩ករណី ក្នុងនោះមានពលករចំនួន ១៥៣នាក់ (ស្រី ៨៩នាក់)។ បណ្តឹងសះជាចំនួន ២០ករណី បណ្តឹងមោឃៈ ០១ករណី និងបណ្តឹងកំពុងតាមដានដោះស្រាយបន្តមានចំនួន ០៨ករណី។

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន

- **តាមរបាយការណ៍ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** ពលរដ្ឋខ្មែរសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលត្រូវបានសម្របសម្រួល បញ្ជូនតាមរយៈស្ថានទូត ស្ថានអគ្គកុងស៊ុលកម្ពុជានៅបរទេស និងបានសហការជាមួយអង្គការដៃគូ មានចំនួន ៣៦.២៧១នាក់ (ប្រុស២០.៤១៩នាក់ និងស្រី ១៥.៨៥២នាក់) ក្នុងនោះមាន៖

| ល.រ | ឈ្មោះប្រទេសគោលដៅ | មូលហេតុនៃការវិល ត្រឡប់ | សរុប | ប្រុស | ស្រី |
|---|---|---|---|---|---|
| ១ | ម៉ាឡេស៊ី | ពលករខុសច្បាប់ | ៥៥ | ១៧ | ៣៨ |
| ២ | ចិន | សង្ស័យជួញដូរ | ៨៨ | ០៦ | ៨២ |
| ៣ | សិង្ហបុរី | ទ្រាំការងារមិនបាន | ៥ | ០ | ៥ |

| | | | | | |
|---|---|---|---|---|---|
| ៤ | វៀតណាម | ធ្វើការខុសច្បាប់ | ៥៦ | ១៨ | ៣៨ |
| ៥ | ឡាវ | ធ្វើការខុសច្បាប់ | ២ | ២ | ០ |
| ៦ | ថៃ(ខេត្តស្រះកែវ) | ពលករខុសច្បាប់ | ៣៦.០៥៩ | ២០.៣៧៣ | ១៥.៦៨៦ |
| ៧ | អារ៉ាប៊ីសាអ៊ូឌីត | ធ្វើការខុសច្បាប់ | ៣ | ០ | ៣ |
| ៨ | ឥណ្ឌូណេស៊ី | ធ្វើការខុសច្បាប់ | ៣ | ៣ | ០ |
| **សរុប** | | | **៣៦.២៧១** | **២០.៤១៩** | **១៥.៨៥២** |

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ច រាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះ ដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសនានា និងនៅក្នុងប្រទេស សរុបចំនួន **១.១២៥**នាក់ (ស្ត្រី **៦៣៩**នាក់ កុមារ **៤០**នាក់) ដូចមានលម្អិតខាងក្រោមនេះ៖

➢ **ការទទួលជនរងគ្រោះ និងងាយរងគ្រោះ នៅក្រៅប្រទេស**

-**ក្រុមការងារការពារជនរងគ្រោះ** នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការ ជាមួយអង្គការសម្ព័ន្ធចាប់ដៃ បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា នៅព្រលានយន្តហោះអន្តរជាតិ និងច្រក(ប៉ោយប៉ែត/បាវិត) សរុបចំនួន **២៩០**នាក់(ស្ត្រី **២០៩**នាក់ កុមារា **២៣**នាក់ កុមារី **១៥**នាក់) ក្នុងនោះមាន៖ ប្រទេសចិន **១១១**នាក់ ម៉ាឡេស៊ី **៤៣**នាក់ វៀតណាម **១៦**នាក់ ប្រទេសថៃ **៤៧**នាក់ និងអារ៉ាប៊ីសាអូឌីត **០២**នាក់(ករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ/បង្ខំ **១១២**នាក់ ករណីងាយរងគ្រោះ **២៣**នាក់ ជួញដូរមនុស្ស **០៣**នាក់ និងជួញដូរកម្លាំងពលកម្ម **១៥០**នាក់ ករណីពពោះជំនួស **០១**នាក់ និងរំលោភសេពសន្ថវៈ **០១**នាក់)។

-**មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានទទួលជនចំណាកស្រុក ដែលអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន **១១.៨០៦**នាក់(ស្ត្រី **៣.៦៣៣**នាក់ កុមារា **៨០២**នាក់ កុមារី **៦៨៦**នាក់)។

➢ **ការទទួលជនរងគ្រោះ និងងាយរងគ្រោះ នៅក្នុងប្រទេស**

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី-ខេត្ត បានសហការជាមួយអង្គការដៃគូ ទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សនៅក្នុងស្រុកសរុបចំនួន **៥៦៣**នាក់ (ស្ត្រី **៣៥៨**នាក់ កុមារា **៣២**នាក់ កុមារី **១៥៤**នាក់) មានករណី( ***ជួញដូរមនុស្ស ២៣៣នាក់ ជួញដូរផ្លូវភេទ ១០៨នាក់ រំលោភបំពានផ្លូវភេទ ១៨៣នាក់ ជួញដូរកម្លាំងពលកម្ម ១៥នាក់ ពេស្យាចារ ០២នាក់ និងងាយរងគ្រោះ ២២នាក់***) ក្នុងនោះ៖

- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី-ខេត្ត ទទួលជនរងគ្រោះចំនួន **១៥៥**នាក់ និង
- អង្គការដៃគូទទួលជនរងគ្រោះចំនួន **៤០៨**នាក់។

▪ **អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

ពលរដ្ឋខ្មែរ ត្រូវអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកវិញ( **ស្នាក់នៅ និងធ្វើការខុសច្បាប់**) ទាំងផ្លូវគោក និងផ្លូវអាកាសសរុបចំនួន **១៤.៥៣៧**នាក់ (ស្រី៤.៤៩៣នាក់ កុមារ ១.៤៦២នាក់) ក្នុងនោះរួមមាន៖

| | | |
|---|---|---|
| - ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ | មនុស្សចំនួន | **៧៧១**នាក់ |
| - ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ | មនុស្សចំនួន | **១៣,៧១៤**នាក់ |
| - ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម | មនុស្សចំនួន | **៥២** នាក់ ។ |

### *តារាងទិន្នន័យ ដែលអាជ្ញាធរបរទេសបញ្ជូនពលករត្រឡប់មកវិញ*

| ល.រ | ប្រទេស | ការប្រៀបធៀប | | ភាគរយ |
|---|---|---|---|---|
| | | ឆ្នាំ២០១៩ | ឆ្នាំ២០១៨ | |
| ១ | ថៃ | ១៣,៧១៤នាក់ | ៣០,៦៤២នាក់ | ថយ ៥៥,២៤% |
| ២ | ជប៉ុន | ២០៥នាក់ | ៩២នាក់ | កើន ១២២,៨២% |
| ៣ | ម៉ាឡេស៊ី | ១៨២នាក់ | ១៧២នាក់ | កើន ៥,៨១% |
| ៤ | កូរ៉េខាងត្បូង | ១៤១នាក់ | ២៧០នាក់ | ថយ ៤៧,៧៧% |
| ៥ | ចិន | ១៤៧នាក់ | ១៥៦នាក់ | ថយ ៥,៧៦% |
| ៦ | អាមេរិក | ៧៧នាក់ | ៧៦នាក់ | កើន ១,៣១% |
| ៧ | វៀតណាម | ៥២នាក់ | ៨៤នាក់ | ថយ ៣៨,០៩% |
| ៨ | ឥណ្ឌូនេស៊ី | ៤នាក់ | ៧នាក់ | ថយ ៤២.៨៥% |
| ៩ | បារាំង | ៤នាក់ | ៥នាក់ | ថយ ២០,០០% |
| ១០ | សិង្ហបូរី | ៤នាក់ | ៧៥នាក់ | ថយ ៩៤,៦៦% |
| ១០ | អ៊ីតាលី | ២នាក់ | ៥នាក់ | ថយ ៦០,០០% |
| ១២ | កាណាដា | ១នាក់ | ១នាក់ | ស្មើ |
| ១៣ | អង់គ្លេស | ២នាក់ | ពុំមាន | គ្មានតួលេខប្រៀបធៀប |
| ១៤ | ឥណ្ឌា | ២នាក់ | ពុំមាន | គ្មានតួលេខប្រៀបធៀប |
| សរុប | | **១៤,៥៣៧នាក់** | **៣១,៦០៩នាក់** | **ថយ ៥៤,០០%** |

▪ **អគ្គបញ្ជាការដ្ឋាន ទីចាត់ការការងារព្រំដែន**

បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ សរុបចំនួន **១២.៥៣២**នាក់ (ស្រី **៣.៩២២**នាក់ អនីតិជន **១.៤៣៧**នាក់) ។

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

**ស្នងការដ្ឋាននគរបាលខេត្ត** ចំនួន០៥ បានទទួល និងសម្ភាសន៍ពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងតាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជាវៀតណាម សរុបចំនួន **៧៤២**លើក មនុស្សចំនួន **១៣.៣៤៣**នាក់ (ស្រី **៤.១៦១**នាក់ អនីតិជន **១.៦៤៩**នាក់) ដូចមានតារាងខាងក្រោម៖

| ល.រ. | ច្រកព្រំដែនខេត្ត | ចំនួនលើក | ចំនួនមនុស្សសរុប | ចំនួនស្រី | ចំនួនអនីតិជន |
|---|---|---|---|---|---|
| ១. | បន្ទាយមានជ័យ | ៥៧៧ លើក | ១២.១២០ នាក់ | ៣.៧២៩ នាក់ | ១.៥៥៧ នាក់ |
| ២. | បាត់ដំបង | ១១១ លើក | ៩៣៤ នាក់ | ៣៣៧ នាក់ | ២៦ នាក់ |
| ៣. | កោះកុង | ៤៣ លើក | ១៤៩ នាក់ | ២២ នាក់ | ០១ នាក់ |
| ៤. | ព្រះវិហារ | ០៦ លើក | ៣៦ នាក់ | ០១ នាក់ | ០០ |
| ៥. | ស្វាយរៀង | ០៥ លើក | ១០៤ នាក់ | ៧២ នាក់ | ៦៥ នាក់ |
| **សរុប** | **៥ខេត្ត** | **៧៤២ លើក** | **១៣.៣៤៣ នាក់** | **៤.១៦១ នាក់** | **១.៦៤៩ នាក់** |

*ដោយឡែក៖*

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសពលករខ្មែររងគ្រោះ ដែលត្រឡប់ពីបណ្ដាប្រទេសផ្សេងៗ សរុបចំនួន **១៥៧**នាក់ (ស្រី **១៣៥**នាក់) ក្នុងនោះ មកពីប្រទេសចិន **១០២**នាក់ ម៉ាឡេស៊ី **៣២**នាក់ ឥណ្ឌូនេស៊ី **០៥**នាក់ វៀតណាម **១៧**នាក់ និងអារ៉ាប៊ីសាអូឌីត **០១**នាក់។

❖ **ក្នុងនោះបានសម្ភាសតែចំនួន ១៥៤នាក់ រកឃើញថា៖**
- ទៅតាមរយៈមេខ្យល់ចំនួន **១៣១**នាក់ ក្នុងនោះមកពីប្រទេស(ចិន ៩៩នាក់ ម៉ាឡេស៊ី ១៥នាក់ និងវៀតណាម ១៧នាក់)
- ទៅតាមរយៈក្រុមហ៊ុនចំនួន **១៣**នាក់(ម៉ាឡេស៊ី១២នាក់ ចិន ០១នាក់)
- ទៅដោយខ្លួនឯងចំនួន **១០**នាក់(ឥណ្ឌូនេស៊ី ០៥នាក់ ម៉ាឡេស៊ី ០៤នាក់ អារ៉ាប៊ីសាអូឌីត ០១នាក់)
- មិនបានសម្ភាស ០១នាក់

❖ **ក្នុងនោះរកឃើញមេខ្យល់ ០២នាក់ ត្រូវបានបង្ក្រាប(មកពីប្រទេសចិន)។**

*ក្រោយពីការសម្ភាសន៍រួច សមត្ថកិច្ចយើងបានបញ្ជូនទៅមូលដ្ឋានវិញ។*

### ឃ.១.១. ការទទួលសាកសពបញ្ជូនត្រឡប់

▪ **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

ក្នុងឆ្នាំ២០១៩នេះ បានទទួលសាកសព និងអដ្ឋធាតុបញ្ជូនត្រឡប់ ចំនួន **៥៥**សព មកពីប្រទេសកូរ៉េ ១២សព ថៃ ៣៥សព ជប៉ុន ០១សព និងប្រទេសម៉ាឡេស៊ី ០៧សព។

▪ **អគ្គបញ្ជាការដ្ឋាន ទីចាត់ការការងារព្រំដែន នៃក្រសួងការពារជាតិ**

តាមទិន្នន័យរបស់សមត្ថកិច្ចតាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ បានទទួលសាកសពពលករ និងពលរដ្ឋខ្មែរតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត ច្រកដូង និងច្រកទ្វារតំបន់ ៤០០ ដែលបានស្លាប់ដោយសារគ្រោះថ្នាក់ផ្សេងៗ សរុបចំនួន **១២៦**សព(ស្រី **២៤**សព កុមារ **០២**សព)

## ឃ.២. ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការងារការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ច រាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន **៩៦៨**នាក់(ស្រ្តី **៤៩៧**នាក់ កុមារ **៣៩៦**នាក់) រួមមានករណី៖ ***(ងាយរងគ្រោះ៣០០នាក់ រំលោភបំពានផ្លូវភេទ១៨៣នាក់ ជួញដូរកម្លាំងពលកម្ម២២នាក់ ជួញដូរផ្លូវភេទ១០៨នាក់ ជួញដូរមនុស្ស៣១៣នាក់ ពេស្យាចារ០២នាក់ និងអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ៤០នាក់)*** ដូចមានក្នុងតារាងលម្អិតខាងក្រោមនេះ៖

***តារាងទទួលជនសង្ស័យរងគ្រោះ និងជនរងគ្រោះ ឆ្នាំ២០១៩***

| ល.រ | ក្រសួង ស្ថាប័ន | ជនរងគ្រោះ | | | |
|---|---|---|---|---|---|
| | | សរុប | ស្ត្រី | កុមារា | កុមារី |
| ១ | នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនៃក្រសួងសង្គមកិច្ច បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ទៅទទួលសេវាបន្តនៅអង្គការសួននៃក្តីសង្ឃឹមនៅកម្ពុជា អង្គការ MOI អង្គការរតនៈអ៊ិនធើណេសិនណល អង្គការមេត្រីអន្តរជាតិ អង្គការសង្គ្រោះដោគវាសនា អង្គការសង្គ្រោះនិងថែទាំស៊ីធីភញ អង្គការកម្ពុជាដើម្បីជួយស្រីមានវិបត្តិនិងអង្គការបេសកកម្មអន្តរជាតិ(IJM)។ | ៩៣ | ៦១ | ០០ | ០៩ |

| | | | | | |
|---|---|---|---|---|---|
| ២ | **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត**បានផ្តល់សេវាស្នាក់នៅរយៈពេលខ្លី និងស្តារនីតិសម្បទាដល់ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងបានបញ្ជូនទៅទទួលសេវាបន្តនៅអង្គការលុបបំបាត់ការជួញដូរមនុស្សសតវត្សទី២១ (A21) អង្គការតំណក់ទឹក អង្គការគ្រួសារថ្មី អង្គការក្តីសង្ឃឹមនិងយុត្តធម៌ អង្គការក្តីសង្ឃឹមពិភពលោក អង្គការក្តីស្រឡាញ់គ្មានព្រំដែន និងអង្គការម៉ារីតាន់កីស អង្គការកម្ពុជាដើម្បីជួយស្រីមានវិបត្តិ និងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ដើម្បីស្នាក់នៅ ទទួលសេវាអប់រំក្នុងនិងក្រៅប្រព័ន្ធ និងជំនាញវិជ្ជាជីវៈ មុនពេលធ្វើសមាហរណកម្មត្រឡប់ទៅផ្ទះវិញ។ | ៣១២ | ៧៨ | ១០៤ | ៩៧ |
| ៣ | **មន្ទីរ ស.អ.យ រាជធានី-ខេត្ត** បានផ្តល់សេវា និងប្រឹក្សាយោបល់រួចបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទៅទទួលសេវាស្តារនីតិសម្បទាបន្តនៅមណ្ឌល និងអង្គការដៃគូ និងបន្តសេវានៅសហគមន៍ ក្នុងនោះមានៈ មន្ទីរ ស.អ.យ រាជធានីភ្នំពេញ **១១១**នាក់ មន្ទីរ ស.អ.យ ខេត្តពោធិ៍សាត់ **០១**នាក់ មន្ទីរ ស.អ.យ ខេត្តក្រចេះ **១១**នាក់ មន្ទីរ ស.អ.យ ខេត្តកំពង់ធំ **០២**នាក់និងមន្ទីរ ស.អ.យ ខេត្តសៀមរាប **៣០**នាក់។ | ១៥៥ | ១៤៥ | ០០ | ០៧ |
| ៤ | **អង្គការដៃគូក្រៅរដ្ឋាភិបាល** បានទទួលជនរងគ្រោះ និងងាយរងគ្រោះ ដែលមានអង្គការបេសកកម្មពិភពលោក **១១**នាក់ អង្គការស្ពានក្តីសង្ឃឹមកម្ពុជា **៤៧**នាក់ អង្គការពន្លកថ្មី**១៦**នាក់ អង្គការសង្គ្រោះដោតវ៉ាសនាកម្ពុជា**៥៣**នាក់ សមាគមទឹកដីសន្យា**១៣**នាក់ និងសមាគមកុមារីរីករាយ **១៣**នាក់ អង្គការមេត្រីអន្តរជាតិ **១០៦**នាក់ អង្គការសង្គ្រោះនិងថែទាំ (Citipointe) **៣៥**នាក់ អង្គការមូលនិធិហាការ **១១៤**នាក់។ | ៤០៨ | ២១៣ | ៣២ | ១៤៧ |
| | *សរុប* | *៩៦៨នាក់* | *៤៩៧នាក់* | *១៣៦ នាក់* | *២៦០នាក់* |

## ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សឱ្យទៅតាមសហគមន៍វិញ សរុបចំនួន **៤០៣**នាក់ (ស្ត្រី **៣១២**នាក់ និងកុមា **៣៧**នាក់) មានតារាងលម្អិតដូចខាងក្រោមនេះ៖

*តារាងធ្វើសមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះ ឆ្នាំ២០១៩*

| ល.រ | ក្រសួង ស្ថាប័ន | ជនរងគ្រោះ | | | |
|---|---|---|---|---|---|
| | | សរុប | ស្រី | កុមារា | កុមារី |
| ១ | **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនៃក្រសួងសង្គមកិច្ច** បានធ្វើសមាហរណកម្មស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស **ឲ្យ ត្រឡប់ទៅសហគមន៍របស់ខ្លួនវិញ** ដោយមានកិច្ចសហការជាមួយអង្គការដៃគូក្នុងការជូនជនរងគ្រោះ ក្នុងនោះមានៈ អង្គការរតនៈអន្តរជាតិ០៩នាក់ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ០៤នាក់ និងអង្គការមេត្រីអន្តរជាតិ ០២នាក់ (*ករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ០៩នាក់ និងជួញដូរកម្លាំងពលកម្ម ០៤នាក់*)។ | ១៥ | ១៤ | ០០ | ០០ |

| | | | | | |
|---|---|---|---|---|---|
| ២ | **មន្ទីរ ស.អ.យ រាជធានី-ខេត្ត** បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ដោយមានកិច្ចសហការជាមួយអង្គការដៃគូ ក្នុងការជូនជនរងគ្រោះដូចជា៖ (អង្គការសម្ព័ន្ធចាប់ដៃ អង្គការ អេ.អ.អឹម អង្គការកុមាររីករាយខេត្តបាត់ដំបង អង្គការក្តីសង្ឃឹម និងយុត្តិធម៌ អង្គការសួននៃក្តីសង្ឃឹមកម្ពុជា អង្គការ សង្គ្រោះដោគវាសានាកម្ពុជា សមាគមទឹកដីសន្យា(ផ្ទះនាងអេសធើ អង្គការមេត្រីអន្តរជាតិ អង្គការសង្រោះ និងថៃទាំស៊ីធីភញ អង្គការរេណាសេដើរជាមួយស្ត្រីកម្ពុជា និងអង្គការរតនៈអន្តរជាតិ) ករណី(*រំលោភ បំពានផ្លូវភេទ៤០នាក់ ជួញដូរមនុស្ស ១២៦នាក់ ជួញដូរផ្លូវភេទ ៣៥នាក់ ជួញដូរកម្លាំងពលកម្ម ១៦៣នាក់ និងរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ/បង្ខំ ២៤នាក់*)។ | ៣៨៨ | ២៩៨ | ០២ | ៣៥ |
| *សរុប* | | *៤០៣ នាក់* | *៣១២* | *០២ នាក់* | *៣៥ នាក់* |

➢ ***ដោយខ្មែរ***

**នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នៃក្រសួង ស.អ.យ** បានសហការជាមួយក្រសួង ស្ថាប័ន មន្ទីរ ស.អ.យ ខេត្ត និងអង្គការដៃគូពាក់ព័ន្ធ ធ្វើសមាហរណកម្មជនរងគ្រោះជនជាតិវៀតណាមចំនួន **០៩**នាក់(ស្រី **០៥**នាក់) ឲ្យវិលត្រឡប់ទៅប្រទេសកំណើតវិញ មានករណី(អំពើជួញដូរមនុស្ស **០៧**នាក់ ការរំលោភបំពានផ្លូវភេទ **០១**នាក់ និងសញ្ញារកម្ម **០១**នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

##### ក.១.១. ការបណ្តុះបណ្តាលក្នុងប្រទេស

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.ជ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ បើកវគ្គបណ្តុះបណ្តាលចំនួន **១៦៣**វគ្គ មានសិក្ខាកាមចូលរួមចំនួន **៦.៨៩៤** នាក់ ក្នុងនោះមានស្ត្រី **២.៨៧៦**នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ សមាជិក គ.ជ.ប.ជ/គ.ខ.ប.ជ ដូចមានក្នុងតារាងវគ្គបណ្តុះបណ្តាលខាងក្រោម៖

**តារាងវគ្គបណ្តុះបណ្តាល**

| |
|---|
| ក្រសួង-ស្ថាប័ន បានសហការជាមួយអង្គការដៃគូ មានអង្គការ MOI, UNICEF, UN WOMEN, ILO, អង្គការដែនដីមនុស្សហូឡង់ដ៍(Terre Des Hommes), AIM SWAT, CPU, អង្គការសង្គ្រោះដោគវាសនា(DR) អង្គការសម្ព័នចាប់ដៃ អង្គការសម្រាលទុក្ខមនុស្សជាតិកម្ពុជា អង្គការមូលនិធិកុមារ(Child Fund) អង្គការទស្សនៈពិភពលោក អង្គការសកម្មភាពដើម្បីកុមារ(APLE) អង្គការ Cambodia Act និងអង្គការ GVC បានបើកវគ្គបណ្តុះបណ្តាលទាំងទ្រឹស្តី និងការអនុវត្ត ស្តីពី៖<br>- ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សាលើស្ត្រី និងកុមារ ការកេងកម្លាំងពលកម្ម ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទូទាំងប្រទេស។<br>- ទេសន្តរប្រវេសន៍ និងសមភាពយេនឌ័រ ដល់អាជ្ញាធរភូមិ/ឃុំ/សង្កាត់ រាជធានី ខេត្ត។<br>- ការថែទាំសុខភាពកុមាររងគ្រោះដោយអំពើហិង្សា និងការរំលោភបំពាន ដល់លោកគ្រូ អ្នកគ្រូ និងបុគ្គលិកមន្ទីរសុខាភិបាល និងការសង្គ្រោះចិត្តសាស្ត្របឋមរបស់សហគមន៍ជួយដល់ជនរងគ្រោះដោយការជួញដូរមនុស្ស និងជនងាយរងគ្រោះនៅរាជធានី ខេត្ត។<br>- ជំនាញទន់ គន្លឹះក្នុងការស្វែងរកការងារ និងបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស។<br>- ច្បាប់ និងបទដ្ឋានគតិយុត្តនានាដល់ប្រតិបត្តិករទេសចរណ៍ វិនិយោគិន បញ្ជ្រាបនិងផ្សព្វផ្សាយក្នុងការចូលរួមទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទេសចរណ៍ផ្លូវភេទ ដល់មន្ទីរទេសចរណ៍រាជធានី ខេត្ត។ |

| ល.រ | សកម្មភាពរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០៤ | ៨៧៣ | ២៦០ |
| ២ | ក្រសួងធម្មការនិងសាសនា | ០២ | ១៤០ | |
| ៣ | ក្រសួងសុខាភិបាល | ០១ | ២៤ | |
| ៤ | ក្រសួងកិច្ចការនារី | ០៤ | ១៦៨ | ១៤៧ |
| ៥ | ក្រុមប្រឹក្សាជាតិដើម្បីកុមារ | ០១ | ៣៦ | ១៤ |
| ៦ | អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ០២ | ១០៣ | ៥២ |
| ៧ | កាកបាទក្រហមកម្ពុជា | ០១ | ២៥ | ០០ |
| ៨ | អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន | ០៥ | ១៤៦ | ៣៥ |
| ៩ | ខេត្តត្បូងឃ្មុំ | ០៣ | ២៣៩ | ២៣ |
| ១០ | ខេត្តបាត់ដំបង | ០៤ | ១១២ | ៦៣ |
| ១១ | ខេត្តពោធិ៍សាត់ | ០២ | ៥១ | ២១ |
| ១២ | ខេត្តស្វាយរៀង | ៦០ | ១.៧៤៥ | ៩៧០ |
| ១៣ | ខេត្តកោះកុង | ០៦ | ៣០៣ | ១៧១ |
| ១៤ | ខេត្តកំពង់ឆ្នាំង | ០១ | ១០៥ | ៤៥ |
| ១៥ | ខេត្តសៀមរាប | ២០ | ១.០០៤ | ៣៧៥ |
| ១៦ | ខេត្តព្រះវិហារ | ០៤ | ១៥៧ | ២៦ |
| ១៧ | ខេត្តព្រះសីហនុ | ០៣ | ១៥៧ | ៤៧ |
| ១៨ | ខេត្តកំពត | ១០ | ៣៩២ | ១៦៦ |
| ១៩ | ខេត្តតាកែវ | ០១ | ៥១ | ២៣ |
| ២០ | ខេត្តកណ្តាល | ០៦ | ២៧៩ | ២០៨ |
| ២១ | ខេត្តព្រៃវែង | ០១ | ៣៩ | ២០ |
| ២២ | ខេត្តក្រចេះ | ០៣ | ៩៦ | ១៨ |
| ២៣ | ខេត្តស្ទឹងត្រែង | ០១ | ២០ | |
| ២៤ | ខេត្តកែប | ០១ | ៩០ | ១១ |
| ២៥ | ខេត្តកំពង់ចាម | ០៣ | ១៥០ | ២៧ |
| ២៦ | អង្គការ Cambodia Act | ០៩ | ៣០០ | ១១៨ |
| ២៧ | អង្គការ GVC | ០១ | ៨៩ | ៣៦ |
| | **សរុប** | **១៦៣** | **៦.៨៩៤** | **២.៨៧៦** |

### គ.១.២. ការបណ្តុះបណ្តាលក្រៅប្រទេស

▪**អគ្គស្នងការដ្ឋាននគរបាលជាតិ៖** នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន បានចាត់មន្ត្រីជាន់ខ្ពស់ចំនួន **០២**រូប ដើម្បីទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេតការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមបណ្តាញអ៊ីនធើណេត នៅប្រទេសថៃ។

## គ.២. សិក្ខាសាលា

### គ.២.១. សិក្ខាសាលាក្នុងប្រទេស

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.ជ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ រៀបចំសិក្ខាសាលាបានចំនួន**៣៧**វគ្គ មានសិក្ខាកាមចូលរួមចំនួន **៣.១៦០**នាក់ ក្នុងនោះមានស្ត្រី **១.១៥១**នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ សមាជិកគ.ជ.ប.ជ/គ.ខ.ប.ជ ដូចមានក្នុងតារាងវគ្គសិក្ខាសាលាខាងក្រោម៖

## តារាងវគ្គសិក្ខាសាលា

| | | | | |
|---|---|---|---|---|
| ក្រសួង ស្ថាប័ន បានសហការជាមួយអង្គការដៃគូ មានអង្គការ UN WOMEN, ILO, IOM, អង្គការសកម្មភាពដើម្បីកុមារ(APLE), Plan International, Cambodia Act, UNICEF, Hope for justice, អង្គការការីតាស់ បានរៀបចំសិក្ខាសាលា ស្តីពី៖<br>- ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សាលើស្ត្រី និងកុមារ ការកេងកម្លាំងពលកម្ម ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទូទាំងប្រទេស។<br>- បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ។<br>- ការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការ នៅបរទេសតាមរយៈភ្នាក់ងារឯកជន និងបទបញ្ញាផ្សេងៗទៀតដល់អាជ្ញាធរថ្នាក់ស្រុក និងថ្នាក់មូលដ្ឋាន។<br>- ទេសន្តរប្រវេសន៍ការងារ និងសមភាពយេនឌ័រ ដល់អាជ្ញាធរភូមិ/ឃុំ/សង្កាត់ រាជធានី ខេត្ត។<br>- ពិនិត្យសម្រេចលើលទ្ធផលសិក្សាអំពីសេវាសង្គម ដើម្បីលើកកម្ពស់ការឆ្លើយតបទៅនឹងផលប៉ះពាល់លើកុមារ ក្នុងទេសន្តរប្រវេសន៍។<br>- ការថែទាំសុខភាពកុមាររងគ្រោះដោយអំពើហិង្សា និងការរំលោភបំពាន ដល់លោកគ្រូ អ្នកគ្រូ និងបុគ្គលិកមន្ទីរសុខាភិបាល និងការសង្គ្រោះចិត្តសាស្ត្របឋមរបស់សហគមន៍ជួយដល់ជនរងគ្រោះដោយការជួញដូរមនុស្ស និងជនងាយរងគ្រោះនៅរាជធានី ខេត្ត។<br>- ច្បាប់ និងបទដ្ឋានគតិយុត្តនានាដល់ប្រតិបត្តិករទេសចរណ៍ វិនិយោគិន បញ្ជ្រាបនិងផ្សព្វផ្សាយក្នុងការចូលរួមទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទេសចរណ៍ផ្លូវភេទកុមារ ដល់មន្ទីរទេសចរណ៍រាជធានី ខេត្ត។<br>- ស្តីពីយុទ្ធនាការ និងវិធានការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅសិប្បកម្មផលិតឥដ្ឋ<br>- ការទប់ស្កាត់ ការឆ្លើយតបចំពោះការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធើណែត។<br>- ពង្រឹងសមត្ថភាពក្រុមសីលធម៌ និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់អ្នកអានព័ត៌មាន ពិធីករ និងពិធីការិនីវិទ្យុ ទូរទស្សន៍ | | | | |
| **ល.រ** | **សកម្មភាពរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** | **ចំនួនវគ្គ** | **សិក្ខាកាមសរុប** | **សិក្ខាកាមជានារី** |
| ១ | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ០៣ | ២០៤ | ៦០ |
| ២ | ក្រសួងអប់រំ យុវជន និងកីឡា | ០៣ | ២២៧ | ៥៨ |
| ៣ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ) | ០៦ | ៤២៩ | ១៤៣ |
| ៤. | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០៦ | ៨០៧ | ២៥១ |
| ៥ | ក្រសួងកិច្ចការនារី | ០៣ | ២២១ | ១៥៦ |
| ៦ | ក្រសួងទេសចរណ៍ | ០៤ | ៣២០ | ១៦៥ |
| ៧ | ក្រសួងពត៌មាន | ០១ | ២១០ | ១០០ |
| ៨ | ក្រុមប្រឹក្សាជាតិដើម្បីកុមារ | ០១ | ៩៥ | ០០ |
| ៩ | អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន | ០២ | ១៣៥ | ៨២ |
| ១០ | ខេត្តបាត់ដំបង | ០១ | ១០០ | ០៥ |
| ១១ | ខេត្តប៉ៃលិន | ០១ | ៨០ | ៤០ |
| ១២ | ខេត្តកោះកុង | ០៣ | ១៨៩ | ៦១ |
| ១៣ | ខេត្តសៀមរាប | ០៣ | ១៤៣ | ៣០ |
| | **សរុប** | **៣៧វគ្គ** | **៣.១៦០នាក់** | **១.១៥១នាក់** |

### ក.២.២. សិក្ខាសាលាក្រៅប្រទេស

- **ថ្នាក់ជាតិ**

  - **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)** បានចាត់៖
    - មន្ត្រីជំនាញទៅចូលរួមសិក្ខាសាលាថ្នាក់តំបន់មេគង្គ លើកទី០៩ ស្តីពីសំណាញ់ឯកភាព ឆ្ពោះទៅមុខនៃការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅទីក្រុងបាងកក ប្រទេសថៃ។

- មន្ត្រីជំនាញទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី "Promotion of Networking among ASEAN Countries on Anti-trafficking in Person" នៅប្រទេសជប៉ុន។
- ប្រធានមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីទៅចូលរួមសិក្ខាសាលាថ្នាក់តំបន់ ស្តីពីមជ្ឈមណ្ឌលធនធានសម្រាប់ពលករ នៅខេត្តង៉េអាន ប្រទេសវៀតណាម។

## ខ. សន្និសីទ កិច្ចប្រជុំ សិក្ខាសាលា ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. សន្និសីទថ្នាក់ជាតិ និងអន្តរជាតិ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**

លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញជា៖

- ជាអធិបតីភាពបើកអង្គសន្និសីទអន្តរជាតិកិច្ចសហប្រតិបត្តិការទ្វេភាគីលើកទី២ កម្ពុជា-ថៃ ស្តីពីទេសន្តរប្រវេសន៍ការងារ និងអំពើជួញដូរមនុស្ស ដែលមានការចូលរួមពីតំណាងមន្ទីរការងារប្រទេសថៃ តំណាងភាគីកម្ពុជា អាជ្ញាធរមានសមត្ថកិច្ច ប្រតិភូសហភាពអឺរ៉ុប ទីភ្នាក់ងារអង្គការសហប្រជាជាតិ តំណាងអង្គការសង្គមស៊ីវិល វិស័យឯកជន សរុបអ្នកចូលរួមប្រមាណ **៧០**នាក់ នៅសណ្ឋាគារ AngKor Miracle ខេត្តសៀមរាប។
- ជាអធិបតីភាពបើកអង្គសន្និសីទអន្តរជាតិ ស្តីពីទេសន្តរប្រវេសន៍ និងការជួញដូរមនុស្សនៅអាស៊ីពីការប្រឈម ការការពារ ការយល់ដឹង និងភាពជាដៃគូ ការចូលរួមក្នុងអង្គសន្និសីទ មានអង្គការជីវិតថ្លៃថ្នូរកម្ពុជា អង្គការដៃគូ អនុវត្តការងារពាក់ព័ន្ធនឹងទេសន្តប្រវេសន៍ចំនួន ១៤ប្រទេស តំណាងពីអង្គការយូអិនវូមែន តំណាងពីភ្នាក់ងារប្រចាំអាស៊ី និងប៉ាស៊ីហ្វិច(EICA) តំណាងពីអង្គការវីនរ៉ក់កម្ពុជា តំណាងពីការិយាល័យ សហគមន៍អង្គការឡូទៃវេនពិភពលោក និងពីអង្គការដៃគូមួយចំនួនក្នុងប្រទេសកម្ពុជា នៅសណ្ឋាគារអ៊ីរ៉ាភ្នំពេញ។
- តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **និងជាប្រធាន គ.ជ.ប.ជ** ចូលរួមសន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិនលើកទី១២ ស្តីពី "តួនាទីព្រះរាជអាជ្ញា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហា សេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅខេត្តសៀមរាប។

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារសម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម (CLMTV) ក្រោមប្រធានបទ "**ការឆ្ពោះទៅកាន់កិច្ចគាំពារពលករទេសន្តប្រវេសន៍នៅក្នុងប្រទេស CLMTV កិច្ចសហប្រតិបត្តិការវិស័យសន្តិសុខសង្គម**"។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានដឹកនាំគណៈប្រតិភូតាមក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន ១៦រូប ធ្វើទស្សនកិច្ចសិក្សា ស្តីពី ការគ្រប់គ្រងមជ្ឈមណ្ឌលជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅទីក្រុងបាងកក ប្រទេសថៃ។

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

បានចាត់ថ្នាក់ដឹកនាំក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ០១រូប និងមន្ត្រីក្រុមជំនួយកិច្ចការយុត្តិធម៌ ០១រូប ដើម្បីទៅចូលរួមកិច្ចប្រជុំពេញអង្គសន្និសិទថ្នាក់តំបន់អាស៊ីអាគ្នេយ៍ សម្រាប់វិស័យនេសាទ ដែលរៀបចំដោយអង្គការ ILO និង Ministry of Maritime Affairs ឥណ្ឌូនេស៊ី នៅកោះបាលី ដែលមាន

អ្នកចូលរួមចំនួន **៩៤**រូប មកពីប្រទេស កម្ពុជា ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ថៃ វៀតណាម ហ្វីលីពីន ភូមា និង UN NGOs ពិភាក្សាលើបញ្ហាដែលកើតឡើងនូវការរំលោភបំពានពលកម្ម និងជួញដូរមនុស្សលើវិស័យនេសាទ។

## ២.២. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស

### ➢ កិច្ចប្រជុំក្នុងប្រទេសជាលក្ខណៈអន្តរជាតិ

- **ថ្នាក់ជាតិ**

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**

លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំកិច្ចប្រជុំ៖

- រវាង ភាគីពាក់ព័ន្ធ កម្ពុជា ថៃ ដើម្បីពង្រឹងកិច្ចសហការ ក្នុងការដោះស្រាយបញ្ហាទេសន្តរប្រវេសន៍ ជាមួយគណៈប្រតិភូថៃ ដោយមានការអញ្ជើញចូលរួមចំនួន **៥៩**នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ។
- បូកសរុបលទ្ធផលនៃទស្សនកិច្ចជាមួយភាគីថៃ រយៈពេល២ថ្ងៃ និងអភិវឌ្ឍន៍ផែនការសកម្មភាព អ្នកចូលរួមចំនួន **៥៩**នាក់ នៅភោជនីយដ្ឋាន ទន្លេបាសាក់២។
- បូកសរុបលទ្ធផលនៃទស្សនកិច្ចជាមួយភាគីថៃ រយៈពេល៣ថ្ងៃ និងអភិវឌ្ឍន៍ផែនការសកម្មភាព អ្នកចូលរួមចំនួន **៦០**នាក់ នៅភោជនីយដ្ឋាន ទន្លេបាសាក់១។
- ប្រទេសបញ្ជូនពលករទេសន្តរប្រវេសន៍ ០៣ប្រទេស(កម្ពុជា ឡាវ និងប្រទេសភូមា) លើកទី២ នៅខេត្តសៀមរាប

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានរៀបចំកិច្ចប្រជុំ៖

- ក្រុមការងារបច្ចេកទេសមន្ត្រីជាន់ខ្ពស់កម្ពុជា-ថៃ ស្តីពីការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការវិស័យការងារ និងកិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់កម្លាំងពលកម្ម ដើម្បីពិនិត្យដោះស្រាយបញ្ហានានាដែលកើតឡើង និងទប់ស្កាត់រាល់បញ្ហាដែលអាចកើតឡើងជាយថាហេតុ។
- ថ្នាក់រដ្ឋមន្ត្រីលើកទី១ ជាមួយរដ្ឋមន្ត្រីសង្គមកិច្ចនិងការងារ និងជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចសេដ្ឋកិច្ចនៃរដ្ឋគូវ៉ែត ស្តីពី "**ការផ្លាស់ប្តូរវិស័យកម្លាំងពលកម្ម រវាងរាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលគូវ៉ែត**" និងការស្វែងយល់អំពីឱកាសវិនិយោគនៃរដ្ឋគូវ៉ែតនៅកម្ពុជា។

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**

បានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយភាគីថៃ ស្តីពីដំណើរការសាងសង់មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដឹកនាំដោយឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងភាគីថៃ ដឹកនាំដោយលោកជំទាវ **SASITORN WONGWEERACHOTKIT** អគ្គនាយករងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៅទីស្តីការក្រសួង ស.អ.យ មានអ្នកចូលរួមចំនួន **៣៥**នាក់(ស្រី **១២**នាក់)។

▪ **ក្រសួងកិច្ចការនារី** បានរៀបចំកិច្ចប្រជុំពិភាក្សាស្តីពី៖ សុខភាពបន្តពូជរបស់ស្ត្រី និងការអនុវត្តរួមទាំងការពេញពារជំនួសរវាងលោកជំទាវរដ្ឋមន្ត្រី និងអ្នកតំណាងរបស់ International Human Rights Clinic of the Chicago University Law School ក្រោមកិច្ចសម្របសម្រួលរបស់ការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា (OHCHR in Cambodia) នៅទីស្តីការក្រសួង។

▪ **អគ្គអន្តោប្រវេសន៍**

- ○ បានអញ្ជើញចូលរួមជាគណៈអធិបតីជាមួយលោកជំទាវ Angela Corcoran ឯកអគ្គរដ្ឋទូត នៃស្ថានទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបើក "**សិក្ខាសាលាអាស៊ាន-អូស្ត្រាលីស្តីពី ជំនាញសម្ភាសន៍សម្រាប់ការងារអន្តោប្រវេសន៍**" ដែលបានរៀបចំនៅរាជធានីភ្នំពេញ ។
- ○ បានទទួលជួបលោក Max Lenormand និងសហការីមួយរូប តំណាងការិយាល័យ ទំនាក់ទំនងនគរបាលន័រឌីក (Nordic Liaison Office) ប្រចាំទីក្រុងបាងកក ចូលជួបសម្តែងការគួរសម ពិភាក្សាការងារ និងបន្តពង្រឹងកិច្ចសហប្រតិបត្តិការ នៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍។

• **ថ្នាក់ក្រោមជាតិ**

▪ **ខេត្តព្រះវិហារ** រដ្ឋបាលខេត្ត និងសមត្ថកិច្ចច្រកទ្វារព្រំដែនតំបន់អានសេះ បានជួបប្រជុំជាមួយភាគីថៃ ស្តីពីកិច្ចសហប្រតិបត្តិការការពារសន្តិសុខតាមបណ្តោយព្រំដែន បញ្ហាពលករធ្វើចំណាកស្រុកដោយប្រថុយប្រថានដើម្បីស្វែងការងារធ្វើក្រៅប្រទេស និងពាក់ព័ន្ធអំពើជួញដូរមនុស្សឆ្លងដែនខុសច្បាប់ ចំនួន ០១លើក មនុស្សចូលរួមចំនួន ៣៨នាក់ នៅខេត្តព្រះវិហារ។

▪ **ខេត្តកោះកុង** បានរៀបចំកិច្ចប្រជុំក្រុមជួយខ្លួនឯង ផ្តោតលើប្រធានបទ អនុស្សរណៈយោគយល់គ្នារវាងប្រទេសកម្ពុជា និងប្រទេសថៃ ក្នុងការបញ្ជូនពលករទេសន្តប្រវេសន៍ក្នុងសហគមន៍ចំនួន៥ អ្នកចូលរួមចំនួន ៩៣នាក់ ស្រី ៦៦នាក់។

▪ **ខេត្តកែប**

- គណៈកម្មាធិការរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជាខេត្ត បានឯកភាពលើកំណត់ហេតុជាមួយគណៈកម្មាធិការរណសិរ្សមាតុភូមិខេត្តគៀនយ៉ាង នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាមលើវិស័យមួយចំនួន ជាពិសេស ក្នុងនោះក៏មានការបង្កើនភាពផ្សព្វផ្សាយអំពីគោលនយោបាយជូនដល់មន្ត្រីរាជការគ្រប់មន្ទីរ អង្គភាព សមាជិកសមាគមនារីគ្រប់លំដាប់ថ្នាក់បានយល់ដឹង និងទប់ស្កាត់ការប្រឆាំងការជួញដូរស្ត្រី និងកុមារឆ្លងដែន ។
- សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តកែប បានចុះកិច្ចសន្យាជាមួយសហព័ន្ធសមាគមនារីខេត្តគៀនយ៉ាង(វៀតណាម)លើវិស័យមួយចំនួន រួមទាំងការងារទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារផងដែរ ។

➢ **កិច្ចប្រជុំក្នុងប្រទេសជាលក្ខណៈជាតិ**

• **ថ្នាក់ជាតិ**

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**

- **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់៖
  - ○ ក្នុងកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ថ្នាក់ជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៨ និងលើកទិសដៅអនុវត្ត ឆ្នាំ២០១៩ ដែលមានអ្នកចូលរួមចំនួន ៣៦៩នាក់ (ស្រី ១១៩នាក់) នៅទីស្តីការក្រសួងមហាផ្ទៃ។

- ដឹកនាំកិច្ចប្រជុំក្រុមជំនាញអន្តរក្រសួង ស្ថាប័នទាំង៦ ប្រចាំឆមាសទី១ និងលើកទិសដៅអនុវត្តបន្ត ឆ្នាំ២០១៩ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន ៤៤នាក់ (ស្រី ១៨នាក់)។
- ក្នុងកិច្ចប្រជុំផ្សព្វផ្សាយផែនការយុទ្ធសាស្រ្តជាតិ(២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអ្នកចូលរួមចំនួន **២៧៦**នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ។
- ក្នុងកិច្ចប្រជុំឆមាសទី១ ឆ្នាំ២០១៩ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅទីស្តីការក្រសួងមហាផ្ទៃ។
- ក្នុងទិវាអន្តរសាសនាលើកទី ០៣ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកោះពេជ្រ។
- ក្នុងទិវាជាតិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ លើកទី១៣ ឆ្នាំ២០១៩ នៅសាលមហោស្រព និងពិព័រណ៍កោះពេជ្រ។

- **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានអញ្ជើញចូលរួមដឹកនាំកិច្ចប្រជុំ៖

**+កិច្ចប្រជុំពិភាក្សាជាមួយអន្តរក្រសួង ស្ថាប័ន** ស្តីពី៖

- ការកំណត់ទិន្នន័យជាក់លាក់ ដែលពាក់ព័ន្ធនឹងជនរងគ្រោះសម្រាប់របាយការណ៍ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន **១៩**នាក់ (ស្រី **០៥**នាក់)។
- ការពិគ្រោះយោបល់សម្រាប់ការរៀបចំកិច្ចប្រជុំពិភាក្សាលើកទី២ ស្តីពី "**ប្រទេសបញ្ជូន កម្ពុជា ឡាវ ភូមា**" មានអ្នកចូលរួមចំនួន **៣២**នាក់ (ស្រី **០៥**នាក់)។
- ការរកវិធានការគ្រប់គ្រងលំហូរពលករកម្ពុជា អំឡុងពេលមកចូលរួមអបអរក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីខ្មែរ និងពេលត្រឡប់ទៅវិញ។
- ករណីពលករកម្ពុជាចំនួន **០២**នាក់ បានស្លាប់ក្នុងពេលបំពេញការងារនៅប្រទេសថៃ កាលពីឆ្នាំ២០១៧ មានអ្នកចូលរួមចំនួន **១៤**នាក់ (ស្រី **០៤**នាក់)។
- លទ្ធផលនៃការសិក្សាស្រាវជ្រាវអំពីសេវាសង្គម ដើម្បីលើកកម្ពស់ការឆ្លើយតបទៅនឹងផលប៉ះពាល់លើកុមារក្នុងទេសន្តរប្រវេសន៍ មានអ្នកចូលរួមចំនួន **២៨**នាក់ (ស្រី **០៧**នាក)។
- ដើម្បីទទួលគណៈប្រតិភូនាយកសាលា និងគ្រូបង្រៀន ១៣សាលារៀន ពីប្រទេសថៃ ក្រោមកិច្ចសហការពីអង្គការមូលនិធិបណ្តាញលើកកម្ពស់សិទ្ធិពលកម្ម (LPN) និងអង្គការ Plan អន្តរជាតិ ដែលនឹងមកទស្សនកិច្ចនៅតាមសាលារៀន និងសហគមន៍ ដែលមានបណ្តាញ គាំពារសង្គមមួយចំនួននៅរាជធានីភ្នំពេញ មានអ្នកចូលរួមចំនួន **២៦**នាក់ (ស្រី **០៦**នាក់)។
- ការរៀបចំទិវាអន្តរសាសនាថ្នាក់ជាតិ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលើកទី៣ អ្នកចូលរួមចំនួន **២១**នាក់ (ស្រី **០៤**នាក់)។
- សេចក្តីព្រាងនីតិវិធីតាមស្តង់ដាប្រតិបត្តិ កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលព្រះរាជាណាចក្រថៃ លើកទី៤ ចំនួន **០៤**លើក អ្នកចូលរួមចំនួន **១០២**នាក់ (ស្រី **១៧**នាក់)។
- ពិនិត្យសម្រេចលើផែនការយុទ្ធសាស្រ្តជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល០៥ឆ្នាំ ២០១៩-២០២៣ អ្នកចូលរួមចំនួន **៧១**នាក់ (ស្រី **១៨**នាក់) នៅទីស្តីការក្រសួងមហាផ្ទៃ។

- កិច្ចប្រជុំពិនិត្យ ពិភាក្សាអំពីរបាយការណ៍ ១០ខែ ឆ្នាំ២០១៩ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន **១០៩**នាក់(ស្រី **៥៩**នាក់) នៅទីស្តីការក្រសួងមហាផ្ទៃ។

+**កិច្ចប្រជុំ ពិនិត្យ ពិភាក្សាជាមួយរាជធានី-ខេត្ត** អំពីរបាយការណ៍ ១០ខែ ឆ្នាំ២០១៩ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានអ្នកចូលរួមចំនួន **១០៩**នាក់ (ស្រី **៥៩**នាក់) នៅសាលប្រជុំក្រសួងមហាផ្ទៃ អគា(ទ)។

+**កិច្ចប្រជុំផ្ទៃក្នុង** ស្តីពី៖(**១**)យន្តការនៃការគ្រប់គ្រងមណ្ឌលទទួលពលករបញ្ជូនត្រឡប់ដោយអាជ្ញាធរថៃ និងប្រកាស ផ្សព្វផ្សាយអំពីសេចក្តីសម្រេចលេខ ១៦៨/១៧ សសរ ស្តីពីការបង្កើតក្រុមការងារទទួលពលករ ពលការិនីកម្ពុជាខុសច្បាប់មកពីប្រទេសថៃ និងសេចក្តីសម្រេចលេខ ២០៩/១៨ សសរ ស្តីពីការបង្កើតក្រុមការងារចម្រុះប្រចាំការទទួលពលករ ពលការិនីកម្ពុជាបញ្ជូនមកពីប្រទេសថៃ នៅខេត្តបន្ទាយមានជ័យ។ (**២**)ការកែសម្រួលខ្លឹមសាររបាយការណ៍ប្រចាំឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **០៣**លើក។(**៣**)ការឆ្លើយតបសំណួររបស់ស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃក្នុងការរៀបចំបទបង្ហាញក្នុងកិច្ចប្រជុំទាក់ទងនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅប្រទេសថៃ។(**៤**)ការពិភាក្សាត្រៀមរៀបចំវេទិកាជាតិអន្តរសាសនា លើកទី៣ ឆ្នាំ២០១៩ អ្នកចូលរួមចំនួន **២១**នាក់។(**៥**)ពិនិត្យតារាងសកម្មភាព នៃផែនការយុទ្ធសាស្ត្រ៥ឆ្នាំ(បន្តបញ្ចប់) និងបន្ថែមការកែសម្រួល បំពេញចន្លោះ ដែលត្រូវការទិន្នន័យតាមចំណុចនៃការងារពាក់ព័ន្ធក្រុមនីមួយៗ អ្នកចូលរួមចំនួន **១៤**នាក់ (ស្រី **០៤**នាក់)។ (**៦**)ការពិនិត្យលទ្ធផល និងការផ្តល់ពិន្ទុនៃការវាយតម្លៃសកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់គ.រ.ប.ជ/គ.ខ.ប.ជ អ្នកចូលរួមចំនួន **២១**នាក់ (ស្រី **០៣**នាក់)។ (**៧**)របាយការណ៍ការងារសង្ខេបខ្លីគ្រប់ក្រុម អ្នកចូលរួមចំនួន**២៥**នាក់ (ស្រី **០៣**នាក់)។(**៨**)សំណួរ ចម្លើយ របស់ UN អ្នកចូលរួមចំនួន **១៣**នាក់ (ស្រី**០៤**នាក់)។ (**៩**)ការបូកសរុប និងដោះស្រាយបញ្ហាការងារផ្សេងៗរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន **២២**នាក់ (ស្រី **០២**នាក់)។ (**១០**)ពិភាក្សាដៃគូអភិវឌ្ឍន៍ ក្នុងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្តីពីការរៀបចំកិច្ចប្រជុំកម្រិតបច្ចេកទេសប្រទេសបញ្ជូន (កម្ពុជា ឡាវ មីយ៉ា) អ្នកចូលរួមចំនួន **២៥**នាក់ (ស្រី **០៩**នាក់)។ (**១១**)កិច្ចប្រជុំ ដើម្បីសហការសិក្សាលទ្ធភាពរៀបចំសាងសង់អគារទទួលពលករ ពលការនីកម្ពុជាបញ្ជូនមកពីប្រទេសថៃ និងរៀបចំយន្តការ និងដំណើរការផ្តល់សេវាចម្រុះជូនពលករនៅច្រកទ្វាអន្តរជាតិដូង អ្នកចូលរួមចំនួន**១១**នាក់ ស្រី **០២**នាក់ ។

- **លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ** បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សា៖ (១)លើឯកសាររូបភាព វីដេអូ បទយកការសម្រាប់ទិវាជាតិ ១២ធ្នូ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ (២)ជាមួយក្រុមការងារពិធីការ ស្តីពីការពិនិត្យវឌ្ឍនភាពការងារ និងបែងចែកតួនាទីភារកិច្ចលម្អិត សម្រាប់កម្មវិធីទិវាជាតិ១២ធ្នូ ឆ្នាំ២០១៩ អ្នកចូលរួមសរុបចំនួន ២៦នាក់ ស្រី០៥នាក់។ (៣)ស្តីពីវឌ្ឍនភាពការងារតាមក្រុមនីមួយៗ ដែលបានទទួលខុសត្រូវក្នុងការរៀបចំទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៩ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ អ្នកចូលរួមចំនួន

១២នាក់ ស្រី០២នាក់។(៤)ដើម្បីត្រួតពិនិត្យការងារប្រចាំឆ្នាំ២០១៩ និងរបៀបរបបការងារឆ្លើយតបបានទាន់ពេលវេលា និងកាន់តែសុក្រិតភាព។

- **លោកជំទាវ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ ទទួលបន្ទុកជំនួយកិច្ចការ** សហប្រតិបត្តិការជាតិ និងអន្តរជាតិ នៃគ.ជ.ប.ជ បានសហការជាមួយក្រុមការងារ ខមមីតកម្ពុជា បានរៀបចំកិច្ចប្រជុំដើម្បីពិនិត្យមើលឡើងវិញ និងធ្វើបច្ចុប្បន្នភាពលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គដែលបានចុះហត្ថលេខាកាលពីខែតុលា ឆ្នាំ២០០៤។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)** បានរៀបចំកិច្ចប្រជុំ៖
  - ត្រីមាសទី១ ទី២ និងទី៣ ដឹកនាំដោយ **ឯកឧត្តម ឯក ក្រិត្យ** រដ្ឋលេខាធិការក្រសួង ស.អ.យ ដោយបានសហការជាមួយក្រុមការងារការពារជនរងគ្រោះ ស្តីពីកិច្ចសហការ និងត្រួតពិនិត្យ តាមដានការអនុវត្តសកម្មភាពការងាររបស់ក្រសួង ស្ថាប័ន និងអង្គការដៃគូពាកព័ន្ធ និងស្តីពីការចុះកិច្ចព្រមព្រៀងរវាងក្រសួង ស.អ.យ និងអង្គការដៃគូពាកព័ន្ធ បានចំនួន ០៤លើក មានអ្នកចូលរួមចំនួន **២៤៥**នាក់(ស្រី**១៣៧**នាក់)។
  - ស្តីពីការចុះកិច្ចព្រមព្រៀង រវាងក្រសួង ស.អ.យ ជាមួយអង្គការសួននៃក្តីសង្ឃឹមនៅកម្ពុជា នៅទីស្តីការក្រសួង មានអ្នកចូលរួមមកពីមន្ត្រីជំនាញ និងអង្គការដៃគូចំនួន **១៧**នាក់(ស្រី **១០**នាក់)។
  - ស្តីពីការធ្វើបច្ចុប្បន្នភាពលើទម្រង់ទទួល តាមដាន និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស លើកទី៦ មានអ្នកចូលរួមមកពីមន្ត្រីជំនាញរបស់នាយកដ្ឋាន និងអង្គការដៃគូពាក់ព័ន្ធចំនួន **២៧**នាក់ ក្នុងនោះដឹកនាំដោយ **ឯកឧត្តម តូច ចាន់នី ចំនួន ១លើក** ។
  - ចំនួន ០២លើក ដឹកនាំដោយ **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួង ស.អ.យ ដើម្បីសម្របសម្រួលដំណើរការសាងសង់មណ្ឌលសំចត និងស្តានីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្សកម្ពុជា-ថៃ ដែលមានសមាសភាពចូលរួមចំនួន **៥៣**នាក់ (ស្រី**១៧**នាក់)

- **ក្រសួងអប់រំយុវជន និងកីឡា បានរៀបចំកិច្ចប្រជុំ៖**
  - អន្តរក្រសួងស្តីពីការរៀបចំ ផែនសកម្មភាពការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស២០១៩-២០២៣ នៅអគាររដ្ឋបាលក្រសួងអប់រំ។
  - រៀបចំប្រជុំពិនិត្យ និងសម្រេចលើកចុងក្រោយ លើផែនការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរយៈពេល៥ឆ្នាំ ២០១៩-២០២៣ ។

- **ក្រសួងកិច្ចការនារី** បានរៀចំកិច្ចប្រជុំ៖
  - ប្រចាំខែ ត្រីមាស ឆមាស អឌ្ឍមាស និងកិច្ចប្រជុំផ្សេងទៀតចំនួន ៤លើកដែលមានអ្នកចូលរួមមកពីក្រសួង-ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលជាសមាជិកនៃក្រុមការងារដែលមានចំនួនសរុបប្រមាណ១៦០នាក់ ស្រី៦៥នាក់។
  - ធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រុមការងារខមមីតកម្ពុជា និងទទួលបានការឯកភាពពីរាជរដ្ឋាភិបាលតាមរយៈសេចក្តីសម្រេចលេខ ១៥៧ សសរ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩។

- **ក្រសួងសុខាភិបាល** បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីប្រមូលទិន្នន័យ សម្រាប់បំពេញជោយការណ៍សកល ស្តីពីការការពារអំពើហិង្សាលើកុមារ នៅទីស្តីការក្រសួងសុខាភិបាល។

- **ថ្នាក់ក្រោមជាតិ**
  - **ខេត្តសៀមរាប** លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ៖ (១)បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប ឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ អ្នកចូលរួមចូលរួម ២៥០នាក់ ស្រី៦៤នាក់ នៅសាលាខេត្តសៀមរាប។ (២)ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ និងកិច្ចប្រជុំពាក់ព័ន្ធ ចំនួន **១៨**លើក នៅសាលាខេត្តសៀមរាប អ្នកចូលរួមចំនួន **១.០២១**នាក់ ស្រី **៣៨៩**នាក់ ។
  - **ខេត្តកំពង់ឆ្នាំង** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំ៖(១)ប្រចាំខែ ឆ្នាំ២០១៩ ដែលមានសមាសភាពក្រុមទាំង៦ និងបណ្តាស្រុកទាំង៨ ចំនួន ០៦លើក។ (២)ត្រួតពិនិត្យការងាររយៈពេល១០ខែ ឆ្នាំ២០១៩ ដែលមានសមាសភាពក្រុមទាំង៦ និងស្រុក/ក្រុង ទាំង**៨០១**លើក។
  - **ខេត្តកណ្តាល** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត និងក្រុមការងារក្រុង-ស្រុកទាំង១១ ៖(១)បានរៀបចំកិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ២០១៩ ក្រោមអធិបតីភាពលោកជំទាវ **ហ៊ុន កុសនី** អភិបាលរងខេត្ត និងអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ អ្នកចូលរួម **៤៣៩**នាក់ ស្រី **២៥៧**នាក់។ (២) បានរៀបចំកិច្ចប្រជុំប្រចាំខែចំនួន **១០៦**លើក អ្នកចូលរួមចំនួន **២.៥១១**នាក់ ស្រី **១.៥៦០**នាក់។
  - **ខេត្តកំពង់ស្ពឺ លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត** បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពការងារប្រចាំខែ ត្រីមាស និងឆមាស ចំនួន **០៦**លើក អ្នកចូលរួមចំនួន **៤២៥**នាក់ ស្រី **៣៥១**នាក់។
  - **ខេត្តព្រះវិហារ៖** (១) លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបានរៀបចំកិច្ចប្រជុំ ប្រចាំខែ ត្រីមាស និងឆមាស ចំនួន ០៤ លើកអ្នកចូលរួមចំនួន **១៤៥**នាក់ ស្រី **៥១**នាក់។ (២)ស្ថាប័នតុលាការអមសាលាដំបូងខេត្ត សហការជាមួយអង្គការសម្ព័នចាប់ដៃរៀបចំកិច្ចប្រជុំ ២លើក ស្តីពីយុត្តិធម៌អនីតិជន និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានអ្នកចូលរួម ៤១នាក់ ស្រី **១០**នាក់។
  - **ខេត្តឧត្តរមានជ័យ** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបានរៀបចំកិច្ចប្រជុំ ប្រចាំខែ ត្រីមាស ចំនួន ០២លើកអ្នកចូលរួមចំនួន **៥០**នាក់ ស្រី **២២**នាក់។
  - ខេត្តក្រចេះ ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ បានប្រជុំបូកសរុបរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆ្នាំ២០១៩ អ្នកចូលរួមចំនួន**៣២**នាក់ ស្រី**២០**នាក់។
  - **ខេត្តតាកែវ** លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានដឹកនាំសម្របសម្រួលប្រជុំជាមួយក្រុមការងារថ្នាក់ខេត្ត ក្រុង ស្រុក និងថ្នាក់ឃុំ សង្កាត់ ចំនួន **១៤**លើក ស្តីពីយន្តការពង្រឹងការងារជួញដូរមនុស្ស និងការរំលោភសន្ថវៈ អ្នកចូលរួមចំនួន **៣.៦៦១**នាក់ ស្រី **២.៦០៣**នាក់។
  - **ខេត្តស្វាយរៀង** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំ៖ (១)បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំត្រីមាសទី១ និងទិសដៅបន្ត ឆ្នាំ២០១៩ អ្នកចូលរួមចំនួន **៤៧**នាក់ ស្រី២៨នាក់។ (២)ក្រុមការងារពាក់ព័ន្ធនឹងការទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស នៅច្រកទ្វារព្រំដែនអន្តរជាតិបាវិត អ្នកចូលរួម ១០នាក់ស្រី**០៧**នាក់។ (៣) សហការជាមួយអង្គការមូលនិធិកុមារ រៀបចំកិច្ចប្រជុំពិគ្រោះយោបល់អំពីសេចក្តីព្រាងខិត្តប័ណ្ណអប់រំផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុក និងការជួញដូរកុមារ នៅសាលាខេត្តស្វាយរៀង អ្នកចូលរួម **២៧**នាក់ ស្រី១១នាក់។

- **ខេត្តកំពង់ធំ** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី១ ត្រីមាសទី២ អ្នកចូលរួម**៣១**នាក់ ស្រី**១៣**នាក់។
- **ខេត្តប៉ៃលិន** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំ៖ (១)ពិនិត្យពិភាក្សាសេចក្តីព្រាង ស្តីពីការសម្រួលសមាសភាព និងរបាយការណ៍ប្រចាំខែមករា អ្នកចូលរួមចំនួន **៣២**នាក់ ស្រី**០៦**នាក់។ (២)បានរៀបចំកិច្ចប្រជុំពិនិត្យ ពិភាក្សាសេចក្តីព្រាងរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានអ្នកចូលរួម **១៣៨**នាក់ ស្រី**១៩**នាក់។
- **ខេត្តបាត់ដំបង** លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ៖ (១)បូកសរុបរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំ ឆ្នាំ២០១៩។ (២)ជួបពិភាក្សាការងារជាមួយអង្គការសាម៉ារីតាន់ភឺស ស្តីពីការទប់ស្កាត់ចំណាកស្រុកគ្មានសុវត្ថិភាព និងទប់ស្កាត់ការជួញដូរមនុស្ស នៅមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង។ (៣)ស្តីពីលទ្ធផលការងារទេសន្តរប្រវេសន៍ ក្នុងរយៈពេល២ឆ្នាំ និង ផែនការអនុវត្តបន្តនាថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ នៅសាលប្រជុំមន្ទីរការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង ។
- **ខេត្តកោះកុង**

+**លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំ៖** (១)ប្រចាំខែ ត្រីមាស១ ឆ្នាំ២០១៩ និងទិសដៅបន្ត អ្នកចូលរួមចំនួន **១៤៨**នាក់( ស្រី **៥៧**នាក់ )។ (២)បានប្រជុំពិភាក្សាការងារជាមន្ទីរសង្គមកិច្ចខេត្ត ពាក់ព័ន្ធនឹងការទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សនៅច្រកព្រំដែនអន្តរជាតិចាំយាម ចំនួន**០៤**លើក អ្នកចូលរួមចំនួន **១៨**នាក់(ស្រី **០៦**នាក់ )។ (៣)បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំត្រីមាសទី១ ឆ្នាំ២០១៩ ទិសដៅឆ្នាំ២០២០ អ្នកចូលរួម **១១០**នាក់( ស្រី **៤៥**នាក់ )។ (៤)ស្តីពី អនុស្សរណៈនៃការយោគយល់គ្នារវាងកម្ពុជា ថៃ ក្នុងការបញ្ជូន ពលករទេសន្តរប្រវេសន៍ ក្នុងសហគមន៍ចំនួន០៥ អ្នកចូលរួម **៩៣**នាក់ ស្រី**៦៦**នាក់។(៥)ស្តីពីការកំណត់អត្តសញ្ញាណពលករ តម្លៃសេវាប័ណ្ណពលករ និងប្រភេទការងារដែលថៃអនុញ្ញាតដល់ពលករបរទេសធ្វើ ក្នុងសហគមន៍ចំនួន០៥ អ្នកចូលរួម **៦៥**នាក់ ស្រី**៥១**នាក់។

+**លោកឧត្តមសេនីយ៍ត្រី កែវ នី អនុប្រធានលេខាធិការដ្ឋានខេត្ត** បានដឹកនាំកិច្ចប្រជុំត្រៀមរៀបចំក្រុមការងារចំពោះកិច្ចដើម្បីសម្របសម្រួល និងទទួលពលករធ្វើដំណើរឆ្លងកាត់ព្រំដែនពីប្រទេស ក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិ ចំនួន**០១**លើក អ្នកចូលរួម **១៣**នាក់( ស្រី **០២**នាក់ )។

- **ខេត្តព្រៃវែង** គណៈកម្មាធិការពិគ្រោះយោបល់ លេខាធិការដ្ឋានខេត្ត និងស្នងការដ្ឋាននគរបាលខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំ ដើម្បីផ្សព្វផ្សាយអប់រំ ស្តីពីច្បាប់ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងជំនាញប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដល់គណៈអភិបាលស្រុក និងក្រុមប្រឹក្សាឃុំ ជាពិសេសឲ្យពួកគាត់ជួយផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋដែលរស់នៅមូលដ្ឋានរបស់ខ្លួន តាមរយៈពិធីមង្គលការ ពិធីបុណ្យ និងពិធីកំសាន្តផ្សេងៗ ។ល។
- **ខេត្តព្រះសីហនុ** លោកជំទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត និងក្រុមការងារលេខាធិការដ្ឋានបាន៖ (១)សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ(APLE)រៀបចំកិច្ចប្រជុំតុមូល ស្តីពីការការពារកុមារសុវត្ថិភាពកុមារ ពីការកេងប្រវ័ញ្ចផ្លូវភេទ ការធ្វើចំណាកស្រុកខុសច្បាប់ តាមប្រព័ន្ធអ៊ិនធឺណេត នៅសណ្ឋាគារធ្មេរថ្មី អ្នកចូលរួមចំនួន **៤៧**នាក់ ស្រី **២០**នាក់។ (២)សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ ប្រជុំផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលស្តីពី កិច្ចបង្ការ ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី និងកុមារ ក្នុងសហគមន៍ អ្នកចូលរួមចំនួន **២៥**នាក់(ស្រី **១៤**នាក់)។

(៣)ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ប្រចាំឆ្នាំ ២០១៨ ទិសដៅឆ្នាំ២០១៩ អ្នកចូលរួម **៥៣**នាក់ ស្រី **២៣**នាក់។ (**៤**)ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រីមាសទី១ ឆ្នាំ២០១៩ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត អ្នកចូលរួមចំនួន **៥៧**នាក់ ស្រី ២២នាក់។ (**៥**)ដឹកនាំកិច្ចប្រជុំពិភាក្សាលើផែនការសកម្មភាពរបស់លេខាធិការដ្ឋាន និងក្រុមការងារអន្តរជំនាញទាំង៦ ដើម្បីលើកកម្ពស់ចំណេះដឹងក្នុងការបង្ការទប់ស្កាត់អំពើរំលោភបំពាន អំពើកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី និងកុមារ អ្នកចូលរួមចំនួន **២៤**នាក់ (ស្រី **១០**នាក់)។

- **ខេត្តកែប** លោកជំទាវ **អ៊ុល ភិរុណ** ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានដឹកនាំសម្របសម្រួលកិច្ចប្រជុំ ដើម្បីត្រួតពិនិត្យលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស របាយការណ៍ ១០ខែ ប្រចាំឆ្នាំ និងដាក់ចេញផែនការសម្រាប់អនុវត្តការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបន្តចំនួន ០៤លើក។
- **ខេត្តបន្ទាយមានជ័យ** លេខាធិការដ្ឋានគ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី១ កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ និងកិច្ចប្រជុំពិភាក្សាទាក់ទងកុមារចំណាកស្រុក និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងថៃ ជាមួយអង្គការ UNICEF។
- **ខេត្តក្រចេះ** លេខាធិការដ្ឋានគ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល៩ខែ និងប្រចាំឆ្នាំ២០១៩ ទិសដៅ២០២០ អ្នកចូលរួម **៦១**នាក់ ស្រី**៣៤**នាក់។
- **ខេត្តកំពង់ចាម** លេខាធិការដ្ឋាន គ.ខ.ប.ជ បានប្រជុំបូកសរុបរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែធ្នូ ឆ្នាំ២០១៩។

## ➢ កិច្ចប្រជុំក្រៅប្រទេស

### • ថ្នាក់ជាតិ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**

- **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានអញ្ជើញចូលរួម៖
  - ជាគណៈប្រតិភូរបស់កម្ពុជា ក្នុងកិច្ចប្រជុំពិភពលោកឆ្នាំ២០១៩ ស្តីពី "**សន្តិភាព សន្តិសុខ និងការអភិវឌ្ឍធនធានមនុស្ស**" នាទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ នៅក្នុងកិច្ចប្រជុំនេះមានការចូលរួមពី ប្រមុខរដ្ឋ និងអតីតប្រមុខរដ្ឋ សមាជិកសភា សមាជិកព្រឹទ្ធសភា មេដឹកនាំស្ត្រី និងមេដឹកនាំសង្គមស៊ីវិល រៀបចំដោយសហព័ន្ធសន្តិភាពសកល (UPF) ដែលជាអង្គការសហប្រជាជាតិ ឆ្នាំ២០១៩។
  - ដឹកនាំប្រតិភូអគ្គលេខាធិការ គ.ជ.ប.ជ ដើម្បីទៅចូលរួមក្នុងកិច្ចប្រជុំ ស្តីពីការផ្សព្វផ្សាយសកម្មភាពថ្មី ក្នុងការរួមគ្នាប្រឆាំងអំពើទាសភាពសម័យទំនើប ក្នុងសង្វាក់ផលិតកម្ម ដែលធ្វើឡើងនៅក្នុងប្រទេសអូស្ត្រាលី ដែលមានសមាសភាពចូលរួមប្រមាណជាង ៤០០នាក់ មកពី ២០ប្រទេសផ្សេងគ្នាជុំវិញពិភពលោក។
- **លោកជំទាវ ឧត្តមសេនីយ៍ទោ វ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ** បានដឹកនាំមន្ត្រីអញ្ជើញចូលរួមកិច្ចប្រជុំ៖

- ○ ថ្នាក់តំបន់អាស៊ីអាគ្នេយ៍សំរាប់វិស័យនេសាទ ដែលត្រូវបានរៀបចំ ដោយអង្គការ ILO និង Ministry of Maritime Affairs ឥណ្ឌូនេស៊ី នៅកោះបាលី
- ○ ស្តីពីការវាយតម្លៃលទ្ធផលកិច្ចសហការក្នុងការអនុវត្តកិច្ចព្រមព្រៀងរវាងកម្ពុជា និងវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការពារជនរងគ្រោះសម្រាប់ឆ្នាំ២០១៧-២០១៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម។

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**

- បានចូលរួមកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់លើកទី១៣ និងការពិនិត្យឡើងវិញនូវយុទ្ធនាការស៊ើបអង្កេតរួមគ្នារបស់ខមមីតឆ្នាំ២០១៨ នៅទីក្រុងណានចាង សាធារណរដ្ឋប្រជាមានិតចិន។
- **ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានដឹកនាំគណៈប្រតិភូព្រះរាជាណាចក្រកម្ពុជា សរុបចំនួន **២៥**នាក់ (ស្រី **០៧**នាក់) តំណាងមកពីៈ (ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងយុត្តិធម៌ និងក្រសួងសុខាភិបាល) គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃ អង្គការ IOM និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីទៅចូលរួមកិច្ចប្រជុំ ស្តីពីពិធីចុះហត្ថលេខាលើនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីដំណើរការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅទីក្រុងបាងកក ប្រទេសថៃ។
- បានចូលរួមកិច្ចប្រជុំទ្វេភាគីកម្ពុជា-វៀតណាម ពាក់ព័ន្ធនឹងការលុបបំបាត់ជួញដូរស្ត្រី និងកុមារ និងជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅទីក្រុងហាណូយប្រទេសវៀតណាម។

▪ **ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**

បានប្រជុំថ្នាក់រដ្ឋមន្ត្រីចំនួន៣លើក និងថ្នាក់មន្ត្រីជាន់ខ្ពស់ចំនួន៣លើកនៅប្រទេសម៉ាឡេស៊ី ដើម្បីអនុត្តអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី។

▪ **ក្រសួងកិច្ចការនារី**

- **លោកជំទាវ សាន្ត អរុណ រដ្ឋលេខាធិការស្រួងកិច្ចការនារី និងជាប្រធានក្រុមការងារខមមីត** បានដឹកនាំគណៈប្រតិភូកម្ពុជា មានថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ចំនួន **០២**រូប ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អគ្គស្នងការដ្ឋាននគរបាលជាតិ អង្គការ UNACT និងអង្គការចាប់ដៃ សរុបចំនួន **១៤**រូប (ស្រី **០៧**រូប) ដើម្បីទៅចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីត លើកទី១៣ និងពិនិត្យមើលឡើងវិញនូវសកម្មភាពស៊ើបអង្កេតរួមគ្នារវាងប្រទេសសមាជិកទាំង៦ (COMMIT Regional Taskforce Meeting និង COMMIT Senior Officials Meeting(SOM13) នៅខេត្តជាំងស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន។
- ចូលរួមកិច្ចប្រជុំក្នុងពិធីប្រកាសឱ្យប្រើគោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ ស្តីពីការដោះស្រាយតម្រូវការជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសិក្ខាសាលាពិគ្រោះយោបល់លើឯកសារគំរូសម្រាប់អ្នកអនុវត្តដែលគាំទ្រជនរងគ្រោះដោយអំពើជួញដូរមនុស្ស របស់គណៈកម្មការអាស៊ានលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) នៅទីក្រុងបាងកក ប្រទេសថៃ។

- **លោកជំទាវ ហ៊ូ សាមិត្ត រដ្ឋលេខាធិការនៃក្រសួងកិច្ចការនារី និង ជាប្រធានក្រុមការងារខេមមីត លោកជំទាវ ជួញ សុផៃ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ** បានដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំវាយតម្លៃលទ្ធផលកិច្ចសហការក្នុងការអនុវត្តកិច្ចព្រមព្រៀងរវាងកម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនិងការពារជនរងគ្រោះសម្រាប់ឆ្នាំ២០១៧-២០១៩ និងសម្រេចលើផែនការសកម្មភាពរួម២០២០-២០២២ ដែលមានសមាសភាពមកពីក្រសួងមហាផ្ទៃ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនិងតំណាងឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសវៀតណាម ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គស្នងការដ្ឋាននគរបាលជាតិ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សមាគមនារីដើម្បីសន្តិភាពនិងការអភិវឌ្ឍ អង្គការសម្ព័ន្ធចាប់ដៃ និងអង្គការរតនៈអន្តរជាតិសរុបចំនួន១៥រូប ដោយមានកិច្ចសហការ និងសម្របសម្រួលជាមួយ អង្គការ UN-ACT កម្ពុជា UNWOMEN និង UN-ACT វៀតណាម នៅទីក្រុងហាណូយប្រទេសវៀតណាម។
- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានចាត់បញ្ជូនថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋាន ចំនួន ០១រូប និងមន្ត្រី ០១រូប ចូលរួមជាមួយ និង Cambodia Acts ០២រូប អង្គការ Cambodia Acts ០១រូប និងអង្គការជាសមាជិករបស់ Cambodia Acts ០៥រូប សរុបចំនួន ១០រូប (ស្រី ០៩រូប) ចូលរួមកិច្ចប្រជុំ Reflection Between Cambodia-Thai (Annual Cross Border Meeting Between Cambodia and Thailand) នៅខេត្តត្រាត និងខេត្តរ៉ាក់យ៉ង ប្រទេសថៃ។

- **ថ្នាក់ក្រោមជាតិ**
  - **ខេត្តកែប** ឯកឧត្តម **កែន សត្ថា** អភិបាលនៃគណៈអភិបាលខេត្ត បានដឹកនាំគណៈប្រតិភូរដ្ឋបាល ខេត្តនៃព្រះរាជាណាចក្រកម្ពុជា បានសហប្រតិបត្តិការគ្នាជាមួយ ខេត្តគៀនយ៉ាង នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម បន្តកិច្ចប្រជុំបូកសរុបលទ្ធផលរួមគ្នា ក្នុងការអនុវត្តសម្រេចបានរយៈពេលកន្លងមក ០២ឆ្នាំ(២០១៧-២០១៨) និងបន្ត ០២ឆ្នាំទៀត(២០១៩-២០២០) ដោយមានការចុះហត្ថលេខាលើកំណត់ហេតុ ដើម្បីសហប្រតិបត្តិការ រវាងខេត្តទាំងពីរ លើវិស័យជាច្រើន ក្នុងនោះក៏មានការទប់ស្កាត់ការជួញដូរស្ត្រី និងកុមារឆ្លងដែនផងដែរ នៅមន្ទីរគណៈកម្មាធិការប្រជាជនខេត្តគៀនយ៉ាង។

## ២.៣. ការទទួលជួបពិភាក្សាការងារ

- **ថ្នាក់ជាតិ**
  - **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**
    - **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានអនុញ្ញាតិទទួលជួបពិភាក្សាការងារជាមួយៈ
      - អង្គការ ហេបភីទ្រី ដែលមានលោក **Jerry Vong** ជាប្រធានដើម្បីសិក្សា រកចំណុចដែលអាចសហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងការចូលរួមជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
      - តំណាងស្ថានទូតអាមេរិកប្រចាំកម្ពុជា ចំនួន ០២លើក ស្តីពីកិច្ចសហប្រតិបត្តិការលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
      - តំណាងស្ថានទូតអូស្ត្រាលីនិងរដ្ឋាភិបាល លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

- អង្គការ Child Fund កម្ពុជា នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- ប្រតិភូជាប្រធាន និងតំណាងអង្គការការីតាស ប្រចាំប្រទេសក្នុងតំបន់ (ថៃ ប៉ាគីស្ថាន ជប៉ុន) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- បានអនុញ្ញាតឲ្យលោកស្រី **Kristin Parco** តំណាងបេសកកម្ម IOM ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិច ប្រចាំនៅកម្ពុជាជួបពិភាក្សាការងារអំពីកតិកាសញ្ញាជាសកល ស្តីពីទេសន្តរប្រវេសន៍ (Global Compact for Migration)។

- **លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ** បានទទួលជំនួបពិភាក្សាការងារជាមួយតំណាងស្ថានទូត អូស្ត្រាលី ស្តីពីការរំលោភបំពានផ្លូវភេទទៅលើកុមារគ្រប់ប្រភេទ។
- **លោកជំទាវ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរងទទួលបន្ទុក ជំនួយកិច្ចការសហប្រតិបត្តិការជាតិនិងអន្តរជាតិ នៃ គ.ជ.ប.ជ** បានទទួលជំនួបពិភាក្សាការងារជាមួយ៖
  - តំណាងអង្គការ JICA មកពីប្រទេសជប៉ុនដើម្បីបង្ហាញពីវឌ្ឍនភាពនៃការអនុវត្តការងាររបស់ក្រសួងកិច្ចការនារីពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងស្វែងរកកិច្ចសហការជាមួយJICA លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរស្ត្រីនិងកុមារ និងអំពើហិង្សាលើស្ត្រីពលករទេសន្តរប្រវេសន៍។

▪ **ក្រសួងកិច្ចការនារី** បានទទួលជំនួបពិភាក្សាការងារជាមួយ៖
- តំណាងUNACT និងUN WOMENដើម្បីពិភាក្សាត្រៀមកិច្ចប្រជុំជាមួយស្ថានទូតម៉ាឡេស៊ីស្តីពីសេចក្តីព្រាងអនុស្សរណៈនៃយោគយល់គ្នា ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស។
- ឯកអគ្គរដ្ឋទូតម៉ាឡេស៊ី ដើម្បីស្នើសុំការបន្តរៀបចំអនុស្សរណៈយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដែលបានរៀបចំធ្វើឡើងតាំងពីឆ្នាំ២០០៨ និងមានការកែសម្រួលម្តងនៅឆ្នាំ២០១២។

▪ **អគ្គអន្តោប្រវេសន៍**
- សមាសភាពចំនួន ០៤រូប ដឹកនាំដោយលោក Michael A. Edson ប្រធានគ្រប់គ្រងជាន់ខ្ពស់នៃប្រព័ន្ធ PISCES ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍។
- បានអនុញ្ញាតឱ្យគណៈប្រតិភូចំនួន ០២ រូប ដឹកនាំដោយលោក John C. Koski សេនានុព័ន្ធរងនៃក្រសួងសន្តិសុខមាតុភូមិសហរដ្ឋអាមេរិច ដើម្បីចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ។
- បានអនុញ្ញាតឱ្យគណៈប្រតិភូចំនួន ០៣ រូប ដឹកនាំដោយលោក Parmer Heacox មន្ត្រីជាន់ខ្ពស់នៃទីភ្នាក់ងារ PEACE CORP សហរដ្ឋអាមេរិច និងលោកស្រី Alissa Ballot ប្រធានសន្តិសុខ PEACE CORP សហរដ្ឋអាមេរិក ប្រចាំនៅប្រទេសកម្ពុជា ដើម្បីចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ។
- បានអនុញ្ញាតឱ្យគណៈប្រតិភូចំនួន ០៤ រូប ដឹកនាំដោយលោក Zhou Yu Hui តំណាង ឯកឧត្តមអគ្គលេខាធិការបក្សខេត្តជីលីង ប្រទេសចិន ដើម្បីចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍។

- **ថ្នាក់ក្រោមជាតិ**
  - **ខេត្តសៀមរាប** លោកស្រីស្នងការរងនគរបាលខេត្ត និងជាអនុប្រធានលេខាធិការដ្ឋានខេត្ត មន្ត្រីជំនាញមន្ទីរទេសចរណ៍ មន្ទីរកិច្ចការនារី មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ត្រីសាលាខេត្ត បានទទួលជួបពិភាក្សាការងារជាមួយក្រុមការងាររបស់សកម្មភាពដើម្បីកុមារ(APLE)។
  - **ខេត្តបាត់ដំបង** បានជួបពិភាក្សាជាមួយអង្គការសាម៉ារីតាន់ភឺស ស្តីអំពីការទប់ស្កាត់ការចំណាកស្រុកគ្មានសុវត្ថិភាព និងការទប់ស្កាត់ការជួញដូរមនុស្សនៅ ក្នុងខេត្តបាត់ដំបង និងស្វែងរកការសហការ ជាមួយដៃគូនាពេលអនាគត នាថ្ងៃទី**១៦ ខែសីហា** ឆ្នាំ**២០១៩** នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង ។

### ២.៤. វេទិកានៅក្រៅប្រទេស

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានចាត់ថ្នាក់ដឹកនាំនារីក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិនិងអន្តរជាតិ ចំនួន ០១រូប និងមន្ត្រីនារី០១រូប ដើម្បីទៅចូលរួមក្នុងវេទិកាស្ត្រី ដែលមានអ្នកចូលរួមប្រមាន ១.២០០នាក់ មកពី៥០ ប្រទេស នៅប្រទេសសឹង្ហបុរី។

### ២.៥. ទស្សនកិច្ចក្នុងប្រទេស និងក្រៅប្រទេស

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)

**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានអញ្ជើញចុះទស្សនកិច្ចការងារដល់ទីតាំងទទួលពលករ និងបានជួបប្រជុំពិភាក្សាការងារ ដើម្បីពង្រឹងកិច្ចសហការ រវាងស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ និងអង្គការដៃគូក្នុងការងារទទួល និងផ្តល់សេវា ដល់ពលករបញ្ជូនត្រលប់ និងផ្តល់កិត្តិយសប្រគល់លិខិតថ្លែងអំណរគុណ របស់ គណៈកម្មាធិការជាតិ ដល់តំណាងក្រុមហ៊ុន **សុខ ស្រេង** ដែលបានផ្តល់ទីតាំងក្នុងការបំពេញការងារ នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានដឹកនាំគណៈប្រតិភូតាមក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន ១៦រូប មាន អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងតំណាងរដ្ឋបាលសាលាខេត្តបន្ទាយមានជ័យ បានធ្វើទស្សនកិច្ចសិក្សា ស្តីពីការគ្រប់គ្រងមជ្ឈមណ្ឌលជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅទីក្រុងបាងកក ប្រទេសថៃ។

### ២.៦. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅទូទាំងប្រទេស គឺ **៥៩៥**លើក មានអ្នកចូលរួមសរុប **១៦.១៩២**នាក់ (ស្រី **១.៤០៦**នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **២១៣**លើក ក្រសួងអប់រំ យុវជន និងកីឡា **២២**លើក ក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ **១០**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា **១៣**លើក ក្រសួងកិច្ចការនារី **០៦**លើក ក្រសួងព័ត៌មាន **០៤**លើក អគ្គនាយកដ្ឋានអន្តោប្រវេសន៍ **០៧**លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន **៣២០**លើក។ (ឧបសម្ព័ន្ធ១)

## IV. ការសន្និដ្ឋានវាយតម្លៃ

លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងឆ្នាំ២០១៩នេះ បានបង្ហាញឱ្យឃើញពីកិច្ចខិតខំប្រឹងប្រែងរបស់គ្រប់ភាគីពាក់ព័ន្ធនៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបានធ្វើឲ្យមានលទ្ធផលគួរជាទីមោទនៈ ដែលអាចវាយតម្លៃបានដូចខាងក្រោម៖

### ក. ចំណុចខ្លាំង

- ការប្តេជ្ញាចិត្តរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្រ្តី ក៏ដូច **ជាសម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្រ្តី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិ (គ.ជ.ប.ជ) ព្រមទាំងថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័ន អង្គភាពក្នុងគណៈកម្មាធិការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងបទល្មើសពាក់ព័ន្ធផ្សេងៗ បានលើកទឹកចិត្ត ឲ្យមន្ត្រីអនុវត្តគ្រប់ថ្នាក់ កាន់តែមានឆន្ទៈមុះមុត មានកម្លាំងចិត្តខិតខំប្រឹងប្រែងកាន់តែខ្លាំងក្លា ។
- គ្រប់ក្រសួង ស្ថាប័ន អង្គភាព ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាអង្គការដៃគូ ទាំងឡាយនៅតែបន្តប្រឹងប្រែងដោះស្រាយបញ្ហានៅមូលដ្ឋាន និងអប់រំផ្សព្វផ្សាយតាមគ្រប់វិធីប្រកបដោយឆន្ទៈខ្ពស់ ដើម្បីឲ្យប្រជាពលរដ្ឋ ក៏ដូចជាអាជ្ញាធរគ្រប់លំដាប់ថ្នាក់ បានយល់ដឹងអំពីអំពើជួញដូរមនុស្ស និងផលវិបាកទាំងឡាយ ដើម្បីនាំគ្នាបង្ការទប់ស្កាត់។
- កម្លាំងសមត្ថកិច្ច បន្តខិតខំស្រាវជ្រាវ និងបង្កើនការបង្ក្រាប ហេតុទទួលបានលទ្ធផល គួរជាទីមោទនៈ
- តុលាការរាជធានីខេត្ត បានខិតខំបង្កើនសវនាការផ្តន្ទាទោសជនល្មើស ទាំងករណីចាស់ ករណីថ្មី និងផ្តល់យុត្តិធម៌ជូនជនរងគ្រោះបានកាន់តែប្រសើរឡើង។
- ក្រសួងស្ថាប័ន ពាក់ព័ន្ធ អាជ្ញាធរដែនដី និងអង្គការដៃគូពាក់ព័ន្ធ បានសហការគ្នាបង្កើនគុណភាពនៃការផ្តល់សេវាជូនជនរងគ្រោះ តាមគ្រប់រូបភាព ទាំងសេវាសុខភាព សេវាសង្គមកិច្ច សេវាច្បាប់ និងសេវាសេដ្ឋកិច្ចលើកកម្ពស់ជីវភាព បានកាន់តែច្រើន ។
- ប្រទេសពាក់ព័ន្ធ និងអន្តរជាតិ ក៏បាន និងកំពុងខិតខំកែលម្អនីតិវិធី និងបទដ្ឋាននានា ដែលបម្រើឲ្យសុវត្ថិភាពពលករ នៅក្នុងប្រទេសគោលដៅ និងការសង្គ្រោះជនរងគ្រោះ ។

### ខ. ចំណុចខ្វះខាត និងភាពប្រឈម

ទោះបីជាមានលទ្ធផលល្អប្រសើរយ៉ាងនេះក្តី ក៏នៅមានភាពប្រឈម និងចំណុចខ្វះចន្លោះ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ ដូចខាងក្រោម ៖

- នៅមានមន្ត្រីឃុបឃិតសមគំនិត ប្រព្រឹត្តអំពើពុករលួយទាំងនៅក្នុងប្រទេស ទាំងនៅប្រទេសគោលដៅ ក្នុងប្រតិបត្តិការ និងការផ្តល់សេវាជូនជនរងគ្រោះ ដែលជាមូលហេតុ ដែលនាំឲ្យជនរងគ្រោះ នៅតែបន្តរងគ្រោះដោយអំពើជួញដូរមនុស្ស ។
- វិបត្តិសេដ្ឋកិច្ចពិភពលោក និងការផ្ទុះឡើងនៃជម្ងឺ ខូវីដ ១៩ នៅចុងឆ្នាំ២០១៩ គឺជាបញ្ហាដែលធ្វើឲ្យមានបម្រែបម្រួលថ្មីនៃរបត់ទេសន្តរប្រវេសន៍ ក្នុងអំឡុងពេលដែល ពេងចក្រសហគ្រាសនៅតាមបណ្តាប្រទេស ផ្អាកដំណើរការ ដែលចាំបាច់ត្រូវបន្តតាមដាន និងដាក់ចេញនូវវិធានការថ្មីៗ ដើម្បីបង្ការនូវហានិភ័យទាំងឡាយដែលអាចកើតមាន ។
- បទល្មើសជួញដូរមនុស្សកាន់តែវិវត្តប្រែប្រួល ក្លាយជាទាសភាពសម័យទំនើបដែលមនុស្សត្រូវបានគេប្រើឧបាយកលទាក់ទាញដើម្បីប្រើប្រាស់ដោយកេងប្រវ័ញ្ចផលប្រយោជន៍ស្មើរមួយជីវិត និងរហូតតកូនចៅ ដោយមិនគិតអើពើអំពីផលប៉ះពាល់ដល់ការខូចខាតផ្លូវកាយ ផ្លូវចិត្ត កិត្តិយស សេចក្តីថ្លៃថ្នូរ សិទ្ធិ និងអាយុជីវិតរបស់ជនរងគ្រោះ។
- ភាពប្រឈមនឹងការគ្រប់គ្រងតុល្យភាពនៃកម្លាំងពលកម្មនៅមិនទាន់បានដោះស្រាយ ដោយកម្ពុជាត្រូវទទួលបន្ទុកដោះស្រាយការវិលត្រឡប់នៃពលករដែលបាត់បង់សមត្ថភាពពលកម្មនិងគ្មានអ្វីសេសសល់សម្រាប់បន្តដោះស្រាយជីវភាព និងបាត់បង់ទីជម្រក ព្រោះតែការចាកចេញយូរអង្វែង និងការធ្វើ

សមាហរណកម្មទៅក្នុងសហគមន៍នូវកុមារ និងយុវវ័យ ដែលមានភាសា ឥរិយាបទ និងទម្លាប់រស់នៅខុសគ្នាពីសហគមន៍ដើមរបស់ខ្លួន ។

- សមត្ថភាពក្នុងការវិភាគស្ថានភាព ការដាក់វិធានការ និងការត្រៀមខ្លួនសម្រាប់បង្ការទប់ស្កាត់ចរន្តនៃបទល្មើសរបស់ អង្គភាព ស្ថាប័នពាក់ព័ន្ធ នៅមានកម្រិត ។
- ការចែករំលែកព័ត៌មាន និងរបាយការណ៍នៅយឺតយ៉ាវ មិនទាន់សភាពការណ៍ ។
- ថ្នាក់ដឹកនាំ និងមន្ត្រីដែលទើបនឹងទទួលបន្ទុកការងារប្រឆាំងការជួញដូរមនុស្ស តាមបណ្តាក្រសួង អង្គភាព ស្ថាប័ន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវការការបណ្តុះបណ្តាល និងស្វែងយល់បន្ថែមទៀតអំពី តួនាទី ភារកិច្ច ដើម្បីពង្រឹងការអនុវត្តការងារឲ្យបានកាន់តែល្អប្រសើរ ។

### គ.សំណូមពរ

- គួររៀបចំវិធានការទុកជាមុន ដើម្បីឆ្លើយតបស្ថានភាពចំពោះមុខ ។ ប្រទេសថៃ ប្រទេសឥណ្ឌូនេស៊ី ប្រទេសជប៉ុន ប្រទេសកូរ៉េខាងត្បូង និងប្រទេសចិន ដែលធ្លាប់ជាគោលដៅនៃទេសន្តរប្រវេសន៍ការងាររបស់ប្រជាជនកម្ពុជា កំពុងតែជួបប្រទះនឹងវិបត្តិធ្ងន់ធ្ងរដោយការរីករាលដាលនៃជម្ងឺខូវីដ-១៩ ធ្វើឲ្យស្ថានភាពសេដ្ឋកិច្ចកំពុងធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរ ។ ហេតុនេះ ការប្រមើលមើលអំពីការវិលត្រឡប់មិនប្រក្រតី របស់ពលករទេសន្តរប្រវេសន៍អាចនឹងមានភាពប្រឈម បើសិនជាសភាពការណ៍នេះ នៅអូសបន្លាយយូរអង្វែង ដែលចាំបាច់ត្រូវដាក់ចេញនូវវិធានការ ដើម្បីត្រៀមដោះស្រាយឲ្យបានល្អ ។
- ត្រូវមានគម្រោងជួបពិភាក្សា ឱ្យបានទៀងទាត់ ជាមួយប្រទេសជាភាគី នៃកិច្ចព្រមព្រៀង ឬអនុស្សរណៈក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីពិនិត្យ កែលម្អចំណុចខ្វះខាត និងពង្រឹងកិច្ចសហប្រតិបត្តិការ។
- ថ្នាក់ដឹកនាំក្រសួង និងប្រធានអង្គភាព ស្ថាប័នជាសមាជិកនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងអភិបាលរាជធានី ខេត្ត ដែលជាប្រធាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ គប្បីពង្រឹងបន្ថែមទៀតនូវរបៀបរបបការងារ និងការទទួលខុសត្រូវដោយចាត់មន្ត្រីឲ្យទទួលបន្ទុកច្បាស់លាស់ ដើម្បីសម្របសម្រួលទំនាក់ទំនង និងកិច្ចសហការ ក្នុងការប្រមូលព័ត៌មាន ទិន្នន័យ ធ្វើរបាយការណ៍ និងមានចំណាត់ការទាន់ពេលវេលា ។
- ស្នើឲ្យមានផែនការដាក់លាក់ និងសុំការគាំទ្រធនធាន និងស្មារតី ឲ្យបានសមស្រប តាមការគ្រោងទុកដើម្បីសម្រួលដល់ដំណើរការកិច្ចប្រតិបត្តិការរបស់ក្រុមការងារ និងមន្ត្រីអនុវត្តន៍។

## V. ទិសដៅ ឆ្នាំ ២០២០

១.បន្តពង្រឹងស្ថាប័ន និងពង្រីកកិច្ចសហការទូលំទូលាយរវាងសមាជិកក្នុងក្រុមការងារអន្តរស្ថាប័នទាំង០៦ និងគណៈកម្មាធិការថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) ដោយបង្កើនការយកចិត្តទុកដាក់រៀបចំកិច្ចប្រជុំក្រុមការងារជាប្រចាំ និងផ្តល់របាយការណ៍មកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ប្រចាំខែត្រីមាស ឆមាស និងប្រចាំឆ្នាំឲ្យបានទៀងទាត់ ។

២.បន្តរៀបចំ និងពន្លឿនការអនុម័តច្បាប់សំខាន់ៗ និងបន្តរៀបចំបទដ្ឋានគតិយុត្តិពាក់ព័ន្ធ ។

៣.រៀបចំផែនការអនុវត្ត ផ្អែកលើយុទ្ធសាស្រ្តរួម ដែលបានកំណត់ក្នុងផែនការជាតិ ។

៤.ជំរុញ និងតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០១៩-២០២៣) និងពង្រឹងប្រសិទ្ធភាពនៃការដឹកនាំបញ្ជា និងការអនុវត្ត នូវវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាព ។

៥.ត្រៀមកិច្ចប្រជុំ អន្តរស្ថាប័ន និងដៃគូ សង្គមស៊ីវិល អំពី សេចក្ដីព្រាងច្បាប់ស្ដីពី ការពពោះជំនួស ដើម្បីឈានទៅសម្រេចសេចក្ដីព្រាងរួមគ្នា ។

៦.ត្រៀមកិច្ចប្រជុំបួនប្រទេស កម្ពុជា លាវ វៀតណាម មីយ៉ាន់ម៉ា ក្នុងការពង្រឹងកិច្ចសហការការពារ និងបង្ការទប់ស្កាត់ ការនាំមនុស្សឆ្លងដែនខុសច្បាប់ ជាពិសេសស្ត្រី និងកុមារ ក៏ដូចជាទារក ។

៧.បន្តលើកកម្ពស់ការងារផ្សព្វផ្សាយ ច្បាប់ គោលនយោបាយ និងពង្រីកការអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៨.បន្តបើកវគ្គបណ្ដុះបណ្ដាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្ដាក្រសួងស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៩. បង្កើនវគ្គបណ្ដុះបណ្ដាលដល់មន្ត្រីជួរមុខ និងមន្ត្រីអនុវត្តន៍ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ច្បាស់អំពីការងារដែលទាក់ទងនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។

១០.បើកវគ្គបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធ ដល់មន្ត្រីទទួលបន្ទុកអនុវត្តថ្នាក់ក្រោមជាតិ លើការងារលេខាធិការដ្ឋាន របាយការណ៍ ផែនការ ការងារត្រួតពិនិត្យ និងពង្រឹងការងារជំនាញសម្រាប់អនុវត្តយុទ្ធសាស្ត្រទាំងបួន ។

១១.បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី អនុសញ្ញា និងផែនការអាស៊ានប្រឆាំងការជួញដូរមនុស្ស និង កាតិកាសញ្ញាពិភពលោកស្ដីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (Global Compact on Safe, Oderly and Regular Migration: GCM) និងនីតិវិធីប្រតិបត្តិបទដ្ឋាននានា ដែលបានឯកភាពគ្នាជាមួយប្រទេសពាក់ព័ន្ធ ។

១២.ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ ដើម្បីការពារសុវត្ថិភាព។

១៣.បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី**" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ)។

១៤.សិក្ខាសាលាពិគ្រោះយោបល់ រកវិធានការទប់ស្កាត់ អំពើរំលោភ និងការធ្វើអាជីវកម្មផ្លូវភេទ លើកុមារ ។

១៥.ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១៦.បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល និងការចុះតាមដានការអនុវត្តគោលនយោបាយ នៅថ្នាក់ក្រោមជាតិ ។

១៧.ពង្រឹងសកម្មភាពទទួលពលករ ការស្រាវជ្រាវទិន្នន័យ និងផ្តល់សេវាជូនពលករដែលត្រូវបានបញ្ជូនត្រឡប់ពីអាជ្ញាធរបរទេស និងពលកររិលត្រឡប់វិញនៅតាមច្រកព្រំដែនសំខាន់ៗ ៕

ថ្ងៃ ចន្ទ ៧រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០២០

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"**ដើម្បីគោរពជូនជាសេចក្តីរាយការណ៍**"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារគ.ជ.ប.ជ
-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"**ដើម្បីជូនជ្រាប**"

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ១

## ការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៥៩៥លើក) មនុស្សចំនួន ១៦.១៩២នាក់ (ស្រី ១.៤០៦នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | **បានសម្របសម្រួលចំនួន ២១៣លើក អ្នកចូលរួមចំនួន ១.៧៥៨នាក់ (ស្រី ៥២៣នាក់)**<br>▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>- (១)បើក និងបិទវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារពីការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងការជួញដូរកុមារវគ្គ២ ក្រោមកិច្ចសហការជាមួយអង្គការ Child Fund នៅសាលាខេត្តស្វាយរៀង។(២)កិច្ចប្រជុំពិនិត្យរបាយការណ៍ របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅទីស្តីការក្រសួងមហាផ្ទៃ។ (៣)ក្នុងពិធីបើកសន្និបាតត្រួតពិនិត្យការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅទីស្តីការក្រសួងមហាផ្ទៃ ។ (៤)ការប្រារព្ធពិធី អបអរសាទរខួបលើកទី១០៨ ទិវាសិទ្ធិនារីអន្តរជាតិ ៨មិនា ឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុនរ៉ានី ហ៊ុន សែន** នៅសាលមហោស្រពពិពណ៌កោះពេជ្រ។ (៥)ជាអធិបតីភាព ថ្លែងសុន្ទរកថាបើកក្នុងអង្គសិក្ខាសាលា ស្តីពីការអនុវត្តបែបកុមារមេត្រីក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌដើម្បីការពារកុមាររងគ្រោះ និងកុមារជាសាក្សីនៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ សមាសភាពចូលរួមក្នុងអង្គសិក្ខាសាលាអញ្ជើញមកពី ក្រសួងយុត្តិធម៌ តំណាងពីស្ថាប័នតុលាការ តំណាងអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ តំណាងអគ្គស្នងការនគរបាលជាតិ អគ្គលេខាធិការគណៈមេធាវីកម្ពុជា តំណាងអង្គការ UNICEF តំណាងមេធាវីអន្តរជាតិ នាយកដ្ឋានការពារក្តីជនក្រីក្រមកពីគណៈមេធាវីកម្ពុជាអង្គការដៃគូពាក់ព័ន្ធ នគរបាលមានសមត្ថកិច្ចអនុវត្តការងារ សរុបប្រមាណ ៩០នាក់(ស្រី **៣៨**នាក់) នៅសណ្ឋាគារសុខាភ្នំពេញ។ (៦)ការប្រារព្ធពិធី អបអរសាទរខួបលើកទី១០៨ ទិវាសិទ្ធិនារីអន្តរជាតិ ៨មិនា ឆ្នាំ២០១៩ ក្រោមប្រធានបទ "**ការលើកកម្ពស់សមភាពយេនឌ័រ និងការគាំពារសង្គមដើម្បីអភិវឌ្ឍធនធានមនុស្ស**" ក្រោមអធិបតីភាព**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មានសមាសភាពចូលរួមចំនួន **៧០០**នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ អគារ១។(**៧**)ក្នុងកម្មវិធីធ្វើបាឋកថាស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជូនដល់សិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាលការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលាបណ្ឌិត្យសភានគរបាលជាតិកម្ពុជា។(៨)ជាអធិបតីភាពបើកនូវកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០១៩ របស់គណៈកម្មាធិការប្រយុទ្ធអំពើជួញដូរមនុស្ស ខេត្តសៀមរាប នៅសាលាខេត្តសៀមរាប។(៩)ជាគណៈអធិបតី កិច្ចប្រជុំអន្តរក្រសួង ស្ថាប័ន របស់គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ។(១០)វគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្ត្រវិទ្យាសាស្ត្រមូលដ្ឋានប្រើប្រាស់សម្រាប់ការតាមដាន និងវាយតម្លៃគម្រោង/កម្មវិធី ក្រោមអធិបតីភាព លោកជំទាវ **ប៊ុន ឈិត វាសនា** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (ក.ជ.ក.ស.) នៅសណ្ឋាគារ ៧មករា ខេត្តកំពង់ចាម។(១១)សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការជ្រើសរើសពលករ ប្រកបដោយក្រមសីលធម៌ អ្នកចូលរួមចំនួនចំនួន**៥០**នាក់ (ស្រី **២៦**នាក់)នៅសាលប្រជុំទន្លេបាសាក់២ |

រាជធានីភ្នំពេញ។(១២)ជាអធិបតីភាពបើកសិក្ខាសាលា ស្តីពីការផ្តល់សេវាសមាហរណកម្មដល់ជនងាយរងគ្រោះ និងរងគ្រោះ ដោយចំណាកស្រុក អញ្ជើញចូលរួមជាគណៈអធិបតីមាន លោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ លោកជំទាវអភិបាលរងខេត្ត/ក្រុងគោលដៅ មានបន្ទាយមានជ័យ បាត់ដំបង ប៉ោយប៉ែត តំណាងពីនាយកដ្ឋានក្រសួងសង្គមកិច្ច និងនាយកប្រចាំប្រទេស អង្គការការីតាសស្វីស ជាអ្នករៀបចំកម្មវិធីដោយមានកិច្ចសហការជាមួយគ.ជ.ប.ជ មានសិក្ខាកាមចូលរួមមកពី មន្ទីរសង្គមកិច្ចខេត្ត តំណាងពីការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ តំណាងពីនាយកដ្ឋានប្រឆាំងការជួញដូរ អគ្គស្នងការដ្ឋាន ស្នងការដ្ឋាននគរបាលខេត្ត ការិយាល័យប្រឆាំងការជួញដូរមនុស្ស ក្រុមការងារចម្រុះទទួលពលករ មន្ត្រីពីមណ្ឌលសំចតប៉ោយប៉ែត និងការិយាល័យសមាហរណកម្ម អង្គការដៃគូអភិវឌ្ឍ ចំនួនសរុប **៥៥**នាក់(ស្រី **២៤**នាក់) នៅខេត្តសៀមរាប។ (**១៣**)ជាអធិបតីក្នុងវេទិកាសាធារណៈដើម្បីត្រួតពិនិត្យ គាំទ្រការអនុវត្តកម្មវិធីគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ដោយមានការចូលរួមពីក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានក្រុង អភិបាលរងខេត្ត អភិបាលក្រុងកំពង់ឆ្នាំង អាជ្ញាធរដែនដី សមត្ថកិច្ច ស្នងការរងនគរបាល មេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត មន្ត្រីពីក្រសួងអប់រំ និងក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីពាក់ព័ន្ធ និងប្រជាពលរដ្ឋអញ្ជើញពីភូមិ៣ របស់សង្កាត់កំពង់ឆ្នាំង ក្នុងសាលាបុណ្យ ភូមិដំណាក់ពពូល ឃុំកំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង។(១៤)កិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលការងារដេកហូតឯកសាររដ្ឋបាលកម្ពុជា មិនប្រក្រតីដែលជនបរទេសអន្តោប្រវេសន៍ និងប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។(**១៥**)កិច្ចប្រជុំប្រកាសសមាសភាពសមាជិក សមាជិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងពិនិត្យផែនការយុទ្ធសាស្ត្រ ស្តីពីការអភិវឌ្ឍកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សម្រាប់រយៈពេល ៥ឆ្នាំ២០១៩-២០២៣ នៅទីស្តីការក្រសួងសង្គមកិច្ច។(**១៦**) កិច្ចប្រជុំ ស្តីពី"**យុត្តិធម៌ព្រហ្មទណ្ឌ** "នៅសាលប្រជុំសាលាខេត្តសៀមរាប មានការចូលរួមពីតំណាងស្ថាប័ន តុលាការ មន្ទីរអង្គភាព ពាក់ព័ន្ធជុំវិញខេត្ត និងតំណាងអង្គការដៃគូអន្តរជាតិ។

- **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ បានដឹកនាំៈ

(១)កិច្ចប្រជុំពិភាក្សា ស្តីពី "**យន្តការ នៃការគ្រប់គ្រងមណ្ឌលទទួលពលករខ្មែរដែលអាជ្ញាធរថៃបញ្ជូនត្រឡប់ និងការផ្សព្វផ្សាយសេចក្តីសម្រេចលេខ ១៦៨/១៧ សសរ និងសេចក្តីសម្រេចលេខ ២០៩/១៨ សសរ**"នៅសាលប្រជុំសាលាក្រុមប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។(២)មន្ត្រីជាន់ខ្ពស់នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចុះពិនិត្យ ស្វែងយល់ពីបទពិសោធន៍ការងារ និងភាពប្រឈមក្នុងរយៈពេលកន្លងមក ដើម្បីរកវិធានការដោះស្រាយ ពីក្រុមការងារចម្រុះទទួលពលករ ច្រកអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។(៣)គណៈប្រតិភូក្រសួងមហាផ្ទៃ ចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩ របស់រដ្ឋបាលខេត្ត**តាកែវ** ក្រោមអធិបតីភាព **ឯកឧត្តម កិត្តិកោសល្យបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** នៅសាលប្រជុំសាលាខេត្តតាកែវ។(៤)ក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ ចុះសាកសួរសុខទុក្ខ និងសំណេះសំណាលស្ត្រីជាប់ចោទទណ្ឌិត មានផ្ទៃពោះនិងកុមារនៅមណ្ឌលព្រៃស។(៥)ប្រតិភូរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក.ស ចុះតាមដានវាយតម្លៃការអនុវត្តច្បាប់ជាតិ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់នាយករដ្ឋមន្ត្រី ការអនុវត្តអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងនារីភេទសីជរ (CEDAW) នៅសាលប្រជុំរដ្ឋបាលសាលា ខេត្តមណ្ឌលគីរី។(៦)កិច្ចប្រជុំពិភាក្សាលើឯកសាររូបភាព វីដេអូ បទយកការណ៍សម្រាប់ទិវាជាតិ ១២ធ្នូ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។(៧)កិច្ចប្រជុំក្រុមការងារពិធីការ ស្តីពីការពិនិត្យវឌ្ឍនភាពការងារ និងបែងចែកតួនាទី

ភារកិច្ចលម្អិត សម្រាប់កម្មវិធីទិវាជាតិ១២ធ្នូ ឆ្នាំ២០១៩ អ្នកចូលរួមសរុបចំនួន**២៦**នាក់ ស្រី**០៥**នាក់។(៨)កិច្ចប្រជុំ ស្តីពីវឌ្ឍនភាពការងារតាមក្រុមនីមួយៗ ដែលបានទទួលខុសត្រូវក្នុងការរៀបចំទិវាជាតិ ១២ធ្នូ ឆ្នាំ២០១៩ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ អ្នកចូលរួមចំនួន**១២**នាក់ ស្រី**០២**នាក់។(៩)កិច្ចប្រជុំដើម្បីត្រួតពិនិត្យការងារប្រចាំឆ្នាំ២០១៩ របៀបរបបការងារឆ្លើយតបបានទាន់ពេលវេលា និងកាន់តែសុក្រិតភាព។(**១០**)ក្រុមការងារបានចុះសួរសុខទុក្ខសំណេះសំណាលជាមួយស្ត្រីក្នុងករណីពពោះជំនួស ដែលកំពុងស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ។(**១១**)បានចុះទៅពិនិត្យ និងសាកសួរពលករនៅមណ្ឌលសំចត ដែលត្រូវអាជ្ញាធរថៃបញ្ជូនត្រឡប់មកវិញនៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ក្នុងនោះមានការចូលរួមអមដំណើរ ដោយលោកជំទាវ អគ្គលេខាធិការរង និងមន្ត្រីអគ្គលេខាធិការដ្ឋានមួយចំនួនទៀត។

- **លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ** បានអញ្ជើញចូលរួម៖

(១)កិច្ចប្រជុំ ស្តីពីការរៀបចំសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ អគារ ទ ។(២)ពិធីចុះហត្ថលេខាលើអនុស្សរណៈរវាងក្រសួងមហាផ្ទៃ និងអង្គការ IJM ក្រោមអធិបតីភាព ឯកឧត្តម សន្តិបណ្ឌិត **តេង សាវង្ស** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ អគារទ។(៣)កិច្ចប្រជុំ ស្តីពីគណៈកម្មាធិការលើកកម្ពស់សីលធម៌សង្គមតម្លៃស្ត្រី និងគ្រួសារ នៅក្រសួងកិច្ចការនារី។(៤)កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ នៅវិមានសន្តិភាព រៀបចំដោយក្រុមប្រឹក្សាជាតិដើម្បីស្ត្រីកម្ពុជា។(៥)កិច្ចប្រជុំលើទម្រង់របាយការណ៍បូកសរុបសកម្មភាព ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩។(៦)សម្ពោធមណ្ឌលសំចតពលករ នៅប៉ោយប៉ែតខេត្តបន្ទាយមានជ័យ តំណាងដ៏ខ្ពង់ខ្ពស់ លោកជំទាវអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។(៧)បិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងលើកទិសដៅអនុវត្តឆ្នាំ២០១៩ របស់ក្រសួងកិច្ចការនារី នៅសណ្ឋាគារភ្នំពេញ។(៨)កិច្ចប្រជុំ ស្តីពីពិធីចុះហត្ថលេខាលើនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីដំណើរការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសណ្ឋាគារកាំបូឌីយ៉ាណា។(៩)កិច្ចប្រជុំពិភាក្សាធ្វើបច្ចុប្បន្នភាពព័ត៌មាន ដើម្បីរៀបចំជំនួយស្មារតីជូន **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ក្នុងជំនួបជាមួយលោកស្រី **រ៉ូណា ស្មីត** អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា នៅសាលប្រជុំក្រុមប្រឹក្សានីតិកម្ម។(១០)កិច្ចប្រជុំពិភាក្សាជាមួយមេធាវីរបស់អង្គការ AIM ស្តីពីករណីរឿងក្តីនៃសាទខុសច្បាប់នៅប្រទេសថៃ របស់ពលករកម្ពុជាចំនួន **៤២**នាក់(ស្រី **១៨**នាក់)។(១១)កិច្ចប្រជុំក្រុមការងារការពារជនរងគ្រោះ ដោយអំពើជួញដូរមនុស្សប្រចាំត្រីមាសទី៣ ឆ្នាំ២០១៩ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ និងការតាមដាន អនុវត្តកន្លងមករបស់ក្រសួង ស្ថាប័ន អង្គភាព និងអង្គការដៃគូ ដែលជាអនុប្រធាន និងសមាជិក ក្នុងគោលបំណងរកដំណោះស្រាយរួមគ្នា និងទិសដៅអនុវត្តបន្ត នៅទីស្តីការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។(១២)កិច្ចប្រជុំផ្ទៃក្នុង ដើម្បីត្រួតពិនិត្យវឌ្ឍនភាពការងាររបស់ក្រុមដែលបានបែងចែកលើលិខិតលេខ ១៧៥/១៩ ល.ប.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩។(១៣)វគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្ត្រវិទ្យាសាស្ត្រមូលដ្ឋានប្រើប្រាស់សម្រាប់ការតាមដាន និងវាយតម្លៃគម្រោង/កម្មវិធី ក្រោមអធិបតីភាព លោកជំទាវ **ប៊ុន ឈិត វាសនា** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (ក.ជ.ក.ស.) នៅសណ្ឋាគារ ៧មករា ខេត្តកំពង់ចាម។(១៤)សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការជ្រើសរើសពលករ ប្រកបដោយក្រមសីលធម៌ អ្នកចូលរួមចំនួនចំនួន**៥០**នាក់(ស្រី

២៣នាក់ )នៅសាលប្រជុំទន្លេបាសាក់២ រាជធានីភ្នំពេញ។(១៥)កិច្ចប្រជុំក្រុមការងាររបស់កម្មវិធីអាស៊ាន អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស (AAPTIP) នៅសណ្ឋាគារភ្នំពេញ។(១៦) សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការវិភាគស្ថានភាពដំបូង លើការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអ៊ិនធើណេត នៅកម្ពុជា នៅសណ្ឋាគារ ៧មករា ខេត្តកំពង់ចាម។(១៧)កិច្ចប្រជុំផ្ទៃក្នុង ដើម្បីត្រួតពិនិត្យវឌ្ឍនភាពការងាររបស់ក្រុមដែលបានបែងចែកលើលិខិតលេខ ១៧៥/១៩ ល.ប.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩។(១៨)កិច្ចប្រជុំពិភាក្សាជាមួយលោកស្រី **Kristin Parco** តំណាងបេសកកម្ម IOM ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិច ប្រចាំនៅកម្ពុជានិងការងារ ស្តីពីកតិកាសញ្ញាជាសកល ស្តីពីទេសន្តរប្រវេសន៍) Global Compact for Migration)។

- **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់៖** លោកប្រធានក្រុមជំនួយកិច្ចការអនុវត្តន៍ច្បាប់ បានចូលរួម៖

- (១)សិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងវិស័យកសិកម្ម ក្រោមអធិបតីភាព**ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ** នៅសាលាភូមិន្ទកសិកម្មចំការដូង។(២)កិច្ចប្រជុំពិភាក្សាពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានចំនួន **៥៩**លើក។(២)ពិភាក្សាជាមួយមេធាវីរបស់អង្គការ AIM ស្តីពីករណី រឿងក្តីនេសាទខុសច្បាប់នៅប្រទេសថៃរបស់ពលករកម្ពុជាចំនួន **៤២**នាក់។(៣)ស្តាប់ការធ្វើបឋកថា ស្តីពីស្ថានភាពនៃអំពើជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជា។(៤)ទទួលជួបតំណាងអង្គភាពសារព័ត៌មាន Satawat FC 20 លោក K01 ស្តីពីការសម្របសម្រួល និងសង្គ្រោះស្ត្រីរងគ្រោះមួយរូបនៅប្រទេសចិន។(៥)ក្នុងកម្មវិធីដាក់បង្ហាញឱ្យដំណើរការសាកល្បងគេហទំព័រ និងកម្មវិធី " NCCT partner Resource and Service Referrals " លើស្នាតហ្វូនរបស់អគ្គ លេខាធិការដ្ឋាន គ.ជ.ប.ជ ចំនួន១លើក។(៦)ទទួលជួបជាមួយជនជាតិចិនដែលត្រូវជាឪពុករបស់ ទារកម្នាក់ ដែលបានឱ្យស្ត្រីខ្មែរពពោះជំនួស ស្តីពីការស្នើសុំយកកូននោះទៅប្រទេសចិន។(៧)ការងារសម្របសម្រួលឱ្យឪពុក ម្តាយ និងសាច់ញាតិស្ត្រីរងគ្រោះ នៅប្រទេសចិន បានទៅដាក់ពាក្យបណ្តឹងនៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានចំនួន៣ករណី។(៨)ទទួលជួបស្តាប់ការបំភ្លឺរបស់ម្តាយកុមារីរងគ្រោះ ដែលត្រូវបានឪពុកជាជនជាតិចិនលួចនាំយកចេញដោយខុសច្បាប់ពីប្រទេសកម្ពុជាទៅប្រទេសចិន និងបានសម្របសម្រួលឱ្យដាក់ពាក្យបណ្តឹងនៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារ អនីតិជន និងជួបជាមួយអង្គការចាប់ដៃដើម្បីទទួលជំនួយផ្នែកច្បាប់។

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់** ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស៊ុន វ៉ូ** អគ្គលេខាធិការរង បានអញ្ជើញចូលរួម៖

- (១) ជាគ្រូបង្គោល ធ្វើបទឧទ្ទេសនាម ច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព និងបោសសំអាតកាកសំណល់សង្គ្រាម។(២)ដឹកនាំមន្ត្រីក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ចំនួន ០២រូប បានចូលរួមក្នុងកម្មវិធីអប់រំផ្សព្វផ្សាយរបស់ក្រុមការងារកាយឫទ្ធិស្ត្រីកម្ពុជា ដឹកនាំដោយ លោកជំទាវ **ស៊ិន ស៊ីរី** អគ្គស្នងការកាយឫទ្ធិស្ត្រីកម្ពុជា និងសហការចូលរួមពីក្រសួងកិច្ចការនារី បានផ្សព្វផ្សាយពីស្ថានភាពទូទៅនៃអំពើជួញដូរមនុស្ស ដែលផ្តោតសំខាន់លើបទល្មើសស៊ីឈ្នួលពពោះជំនួស ដល់លោកមេឃុំ នាយិកា អ្នកគ្រូ សិស្សានុសិស្សសាលាសង្គម និងមាតាបិតាសិស្ស សរុបចំនួន **៨៥**នាក់ (ស្រី **១៤**នាក់ សិស្សស្រី **៧១**នាក់)។(៣)ដឹកនាំមន្ត្រីចំនួន០២រូប នៃក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានចូលរួមក្នុងកម្មវិធីអប់រំផ្សព្វផ្សាយរបស់ក្រុមការងារកាយឫទ្ធិស្ត្រីកម្ពុជា នៅភូមិស្រីប្រសើរ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ ដែលដឹកនាំដោយលោកជំទាវ **ម៉ែន នារីសុឌ្ឍី** ស្នងការទំនាក់ទំនងសាធារណៈនៃកាយឫទ្ធិកម្ពុជា និងមានការចូលរួមពីក្រសួងកិច្ចការនារី និងអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានផ្សព្វផ្សាយពីស្ថានភាពទូទៅ នៃអំពើជួញដូរ

មនុស្ស ដែលផ្តោតសំខាន់លើការធ្វើចំណាកស្រុក និងបទល្មើសស្ត្រីស៊ីឈ្នួលពពោះជំនួស ដល់លោកមេឃុំស្លា សិស្សានុសិស្សសាលាបឋម សិក្សា **ហ៊ុន សែន** បណ្ឌិត និងសមាជិកាក្រុមកាយឫទ្ធិស្ត្រីកម្ពុជា សរុបចំនួន៦៩នាក់ (ស្រី ៦៨នាក់)។

- លោកប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានចូលរួម៖(១)ដឹកនាំមន្ត្រីចំនួន ០៣រូប ទៅចូលរួមកម្មវិធីសិក្ខាសាលា ស្តីពីការពង្រឹងសមត្ថភាពលើក្របខណ្ឌច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការរៀបចំផែនការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ឆ្នាំ២០១៩-២០២០ ក្រោមអធិបតីភាព ឯកឧត្តម **ប៊ូ ជុំសេរី** អនុរដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ស សុខា** រដ្ឋលេខាធិការ នៅក្រសួងអប់រំ យុវជន និងកីឡា។(២) បានចូលរួមរៀបចំដំណើរទស្សនកិច្ច របស់គណៈប្រតិភូនាយកសាលា និងគ្រូបង្រៀនមកពី ១៣សាលានៅប្រទេសថៃ ដោយបានទស្សនកិច្ចតាមបណ្តាសាលា និងកន្លែងប្រវត្តិសាស្ត្រមួយចំនួនក្នុងរាជធានីភ្នំពេញ ដើម្បីធ្វើការសិក្សាស្វែងយល់ពីស្ថានភាពប្រឈមនានារបស់កុមារនៅតាមសាលារៀន។(៣)ក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការថែទាំដោយមានការយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត តបតាមការស្នើសុំរបស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM)កម្ពុជា នៅភោជនីយដ្ឋានទន្លេបាសាក់២។(៤)កិច្ចប្រជុំពិនិត្យសម្រេចទៅលើផែនការបង្ការ ទប់ស្កាត់ អន្តរក្រសួង ស្ថាប័ន ដឹកនាំដោយលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ ក្រុមបង្ការ ទប់ស្កាត់ អ្នកចូលរួមចំនួន **២១**នាក់ នៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡា។(៥)ដឹកនាំក្រុមការងារចូលរួមធ្វើបទឧទ្ទេសនាមក្នុងកម្មវិធីសិក្ខាសាលា ស្តីពីការពង្រឹងសមត្ថភាពក្រមសីលធម៌ និងការងារទប់ស្កាត់អំពើជួញដូរមនុស្ស ជូនដល់អ្នកសារព័ត៌មាន ពិធីករ និងពិធីការិនី វិទ្យុ និងទូរទស្សន៍ ក្រោមអធិបតីភាព ឯកឧត្តម **ជុំ កុសល** រដ្ឋលេខាធិការក្រសួងព័ត៌មាន និងបិទបញ្ចប់កម្មវិធីដោយ ឯកឧត្តម **ហ៊ុយ សារ៉ាវុធ** រដ្ឋលេខាធិការក្រសួងព័ត៌មាន និងជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម រដ្ឋមន្ត្រីក្រសួងព័ត៌មាន នៅសាកលវិទ្យាល័យអន្តរជាតិ IU។(៦)សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការសិក្សាមូលដ្ឋានលើយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅសណ្ឋាគារភ្នំពេញ។(៧)សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីសេចក្តីព្រាងដំបូង នៃគោលការណ៍ណែនាំ ស្តីពីយន្តការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស រៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារសាន់វេ។

▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ** បានអញ្ជើញចូលរួម៖

- (១)ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការមេត្រីអន្តរជាតិ ចុះសួរសុខទុក្ខស្ត្រីកេសីពពោះជំនួស មានទីលំនៅខេត្តកណ្តាល ដែលបានសម្រាលកូនប្រុសអាយុទើបតែ២ខែ។(២)បានចូលរួមកិច្ចប្រជុំពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីប្រព័ន្ធការពារកុមារ ដែលរៀបចំដោយក្រុមប្រឹក្សាជាតិដើម្បីកុមារ នៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកែប ដឹកនាំកិច្ចប្រជុំដោយ លោកជំទាវ **ញ៉េប សុភាព** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ្នកចូលរួមចំនួន**១៧**នាក់ ស្រី០៥នាក់។(៣)ជួបសំណេះសំណាល និងផ្តាំផ្ញើដល់ស្ត្រីពពោះជំនួសចំនួន **០៧**នាក់ ក្នុងចំណោម **១១**នាក់ ដែលត្រូវតុលាការដោះលែងឲ្យនៅក្រៅឃុំ តែក្នុងនោះមាន **០៣**នាក់ ទៅមុន និង០១នាក់ទៀត ពុំទាន់ចេញដោយមូលហេតុ គាត់មិនត្រូវការអន្តរាគមន៍ពីខាងអង្គការ AIM និងដោយ គាត់មានមេធាវីរបស់គាត់ហើយ។(៤)ប្រជុំឆ្លងផែនការយុទ្ធសាស្ត្រទី៤ ស្តីពីការលើកកម្ពស់កិច្ចការពារជនរងគ្រោះជាពិសេសស្ត្រី និងកុមារ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។(៥)បានចុះទៅពិនិត្យតាមដានការសាងសង់មណ្ឌលសំចតសម្រាប់ទទួលជនងាយរងគ្រោះ នៅប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។(៦)វគ្គបណ្តុះបណ្តាលគ្រូបង្គោលសង្គ្រោះបឋមផ្លូវចិត្តដល់ជន

រងគ្រោះ នៅសណ្ឋាគារ CAMBODIANIA រាជធានីភ្នំពេញ។(៧)កិច្ចប្រជុំប្រចាំត្រីមាសទី១ ឆ្នាំ២០១៩ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការការពារជនរងគ្រោះ ដឹកនាំកិច្ចប្រជុំដោយ ឯកឧត្តម **ឯក ក្រិស្ស** រដ្ឋលេខាធិការ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។(៨)ប្រជុំឆ្លងផែនការយុទ្ធសាស្ត្រទី៤ ស្តីពីការលើកកម្ពស់កិច្ចការពារជនរងគ្រោះជាពិសេសស្ត្រី និងកុមារ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។(៩)ជួបប្រជុំក្រុមការងារ ស្តីពីគម្រោងរៀបចំការចុះទៅបើកវគ្គបណ្តុះបណ្តាល នៅខេត្តត្បូងឃ្មុំ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស។(១០)ចូលរួមសិក្ខាសាលា ស្តីពីការពិនិត្យ និងប្រមូលធាតុចូលដើម្បីកែសម្រួលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ។(១១)ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការវិភាគស្ថានភាពដំបូងពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអ៊ិនធើណេតនៅកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម **ស៊ូ អាហ្វាត់** អភិបាលរងខេត្តបាត់ដំបង នៅសណ្ឋាគារ ឡឺប្រេស៊ីដង់ ខេត្តបាត់តំបង។(១២)ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវសុខភាពជនអន្តោប្រវេសន៍ ក្រោមអធិបតីភាព ឯកឧត្តម **ស៊ីវ ហួង** រដ្ឋលេខាធិការក្រសួងសុខាភិបាល នៅសណ្ឋាគារ អង្គរ ខេត្តសៀមរាប។(១៣)វគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារ កុមារ ពីការកេងប្រវ័ញ្ចផ្លូវភេទ តាមប្រព័ន្ធ អ៊ិនធើណេត ក្រោមអធិបតីភាពលោកជំទាវ **ខៀវ បូរី** រដ្ឋលេខាធិការក្រសួង សង្គមកិច្ច អតីតយុវជន និង យុវនិតិសម្បទា នៅសណ្ឋាគារ រ៉ក់រ៉ូយ៉ាល់ ខេត្តកែប។(១៤)សហការជាមួយក្រសួងសង្គមកិច្ច និង អង្គការមេត្រី អន្តរជាតិ បានចុះមកពិនិត្យ និងតាមដានស្ត្រីរកស៊ីពរពោះជំនួស នៅខណ្ឌព្រែកព្នៅ និងខណ្ឌសែនសុខ។(១៥) ចូលរួមសិក្ខាសាលា ស្តីពីគោលនយោបាយជាតិ អំពីប្រព័ន្ធកិច្ចការពាកុមារ ឆ្នាំ ២០១៩-២០២០ នៅភោជនីយដ្ឋានទន្លេបាសាក់ ២។(១៦)កិច្ចប្រជុំស្តីពីការសរសេររបាយការណ៍សិទ្ធិមនុស្សនៅកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម **ប៊ុន ហុន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅក្រសួងមហាផ្ទៃ។

▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌៖**

- ឯកឧត្តម **ឧត្តមសេនីយ៍ឯក យឹម វិរៈ** អគ្គលេខាធិការរង បានអញ្ជើញចូលរួមកិច្ចប្រជុំ និងសិក្ខាសាលា៖

  ○ (១)ត្រៀមដើម្បីចូលរួមធ្វើបទបង្ហាញ និងពិភាក្សាការងារក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ ជាមួយឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ នៅក្រសួងមហាផ្ទៃអគារV។(២)ស្តីពីការចូលរួមធ្វើបទបង្ហាញ និងពិភាក្សាការងារក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ ជាមួយឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ នៅទីស្តីការ នាយករដ្ឋមន្ត្រី (វិមានសន្តិភាព)។(៣)សិក្ខាសាលា អន្តរក្រសួង ស្ថាប័ន ផ្លុះបញ្ចាំង ស្តីពីការអនុវត្តល្អនៃការចូលរួមរបស់កុមារ ក្នុងកិច្ចសន្ទនាគោលនយោបាយថ្នាក់ជាតិ និងការអភិវឌ្ឍគម្រោងកម្មវិធីរៀបចំដោយអង្គការសម្ព័ន្ធសិទ្ធកុមារកម្ពុជា សហការ ជាមួយក្រុមប្រឹក្សាជាតិដើម្បីកុមារ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។(៤) កិច្ចប្រជុំក្រុមការងារបច្ចេកទេស នៃគណៈកម្មការការពារកុមារថ្នាក់ជាតិដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៨ រៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នៅខេត្តកំពង់ចាម។(៥) កិច្ចប្រជុំជ្រើសរើសប្រធានបទ សម្រាប់រៀបចំពិធីមីទ្ទិញអបអរសាទរខួបលើកទី៧០ ទិវាកុមារអន្តរជាតិ ១មិថុនា ខួបលើកទី១៨ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។(៦)សិក្ខាសាលាផ្លុះបញ្ចាំង ស្តីពីច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ មានការចូលរួមពីមន្ត្រីរបស់ស្ថាប័នរដ្ឋ សង្គមស៊ីវិល អង្គការជាតិ អន្តរជាតិ សរុបចំនួន **១៤០**នាក់ (ស្រី **៦៥**នាក់)នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ។(**៧**)កិច្ចប្រជុំពិភាក្សាលើ

| | |
|---|---|
| | សមាសភាព និងភារកិច្ចរបស់គណៈកម្មការ និងអនុគណៈកម្មការរៀបចំសន្ធានុក្រមបច្ចេកទេស ក្នុងវិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងពន្ធនាគារ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍សាស្ត្រាចារ្យ **សេង ផល្លី** ប្រធានបណ្ឌិត្យសភានគបាលកម្ពុជា នៅសាលប្រជុំអគារ A នៅសាលាបណ្ឌិត្យសភានគបាលកម្ពុជា។ (៨)កិច្ចប្រជុំចង្អៀតផ្តល់ជំនួយផ្លូវច្បាប់ ដល់អង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា ពាក់ព័ន្ធការងារប្រកបរបររកស៊ីផ្លូវភេទរបស់ស្ត្រី ដើម្បីបញ្ចៀសភាពខុសច្បាប់ក្នុងបររកស៊ីផ្លូវភេទរបស់ស្ត្រី។(៩)កិច្ចប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃនៃសាធារណរដ្ឋ ស៊ែប៊ី ក្រោមអធិបតីភាព ឯកឧត្តម **ឡាំ ជា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អ្នកចូលរួមចំនួន ១២នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ។ (១០)បានអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការបង្ការ ទប់ស្កាត់ និងឆ្លើយតបជាពហុវិស័យចំពោះការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណែត ក្រោមការដឹកនាំសម្របសម្រួលដោយលោកជំទាវ **ញ៉េប សុភាព** អគ្គលេខាធិការ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលមានការចូលរួមពីអន្តរក្រសួងពាក់ព័ន្ធ និងអង្គការដៃគូ នៅសណ្ឋាគារ សាន់វ៉េរាជធានីភ្នំពេញ។(១២)បានអញ្ជើញចូលរួមកិច្ចប្រជុំ ស្តីពីការសរសេររបាយការណ៍សិទ្ធិមនុស្សនៅកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម **ប៊ុន ហុន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ អគារ ទ។<br>- លោកអនុប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ និងមន្ត្រីបច្ចេកទេសបានចូលរួម៖(១)សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលការងារបឋមស្តីពីការឆ្លើយតបបែបយេនឌ័រក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មហាអនុតំបន់មេគង្គ ដោយមានការចូលរួមពីមន្ត្រីរបស់ស្ថាប័នរដ្ឋ សង្គមស៊ីវិល អង្គការជាតិ អន្តរជាតិ ប្រមាណ **៣០**នាក់ (ស្រី **១៣**នាក់នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ។(២)ប្រជុំឆ្លងសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃស៊ែប៊ី និងក្រសួងមហាផ្ទៃកម្ពុជា នៅទីស្តីការក្រសួងមហាផ្ទៃ។(៣)សិក្ខាសាលាពិគ្រោះយោបល់ដើម្បីពិនិត្យ និងសម្រេចលើសេចក្តីព្រាងឯកសារអប់រំ ស្តីពីការការពារកុមារពីការរំលោភបំពាន និងបៀតបៀនផ្លូវភេទ រៀបចំដោយ ក្រុមប្រឹក្សាជាតិដើម្បីកុមារ អ្នកចូលរួមចំនួន **៦០**នាក់ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ (៤)សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ រៀបចំដោយក្រុមប្រឹក្សាជាតិដើម្បីកុមារ នៅភោជនីយដ្ឋានទន្លេបាសាក់១ រាជធានីភ្នំពេញ។(៥) បានចូលរួមសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានកសុភារ និងហិរញ្ញវត្ថុ នៅទីស្តីការក្រសួងមហាផ្ទៃ។(៦)ពិនិត្យ និងផ្តល់ព័ត៌មានឆ្លើយតបទៅនឹងកម្រងសំណួររបស់គណៈកម្មាធិការសិទ្ធិកុមារ នៃ អ.ស.ប ពាក់ព័ន្ធនឹងរបាយការណ៍ជាតិលើកទី៤ ទី៥ និងទី៦ ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារនៅកម្ពុជា។(៧)ពិភាក្សាក្រុមការងារ ព័ត៌មានវិទ្យា រូបភាព បទយកការណ៍ និងផ្សព្វផ្សាយសម្រាប់ទិវាជាតិ១២ធ្នូ ឆ្នាំ ២០១៩។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ ឯកឧត្តម ឧត្តមសេនីយ៍ឯក ខៀវ ចាន់រ៉ា** អគ្គលេខាធិការរង ៖<br>- បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រឹក្សាគម្រោង ស្តីពីការរៀបចំផែនការការងាររបស់ កម្មវិធីត្រីកោណ ក្នុងតំបន់អាស៊ាន សម្រាប់ឆ្នាំ២០១៩ និងការត្រួតពិនិត្យវឌ្ឍនភាព ឆ្នាំ២០១៨ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំសមិទ្ធិផលនៃការអនុវត្តគម្រោងឆ្នាំ២០១៩ និងការរៀបចំផែនការសកម្មភាព បន្តសម្រាប់អនុវត្តគម្រោង ILO-TRIANGLE ឆ្នាំ២០២០ ក្រោមការរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការ ILO នៅសណ្ឋាគារភ្នំពេញ។ |

| | |
|---|---|
| | ▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ៖**<br>- **លោកជំទាវ ឧត្តមសេនីយ៍ត្រី រ៉េន សិរីលក្ខិណា** អគ្គលេខាធិការរង បានអញ្ជើញចូលរួម៖<br>○ (១)ដឹកនាំកិច្ចប្រជុំស្តីពីការពិភាក្សា និងរៀបចំកម្មវិធី និងធ្វើគម្រោងចំណាយផ្សេងៗ សម្រាប់ធ្វើបទបង្ហាញទាក់ទងនឹងការប្រើប្រាស់ប្រព័ន្ធប្រមូលព័ត៌មានដៃគូអភិវឌ្ឍន៍លើសេវាកម្មសម្រាប់ជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយមានការចូលរួមពីតំណាងអង្គការចាប់ដៃ និងអង្គការវីនរ៉ក ប្រចាំកម្ពុជា។ **(២)**កិច្ចប្រជុំ ក្រុមពិភាក្សាទី៨ នៅសាលប្រជុំអគារពន្ធនាគារ លើប្រធានបទការគ្រប់គ្រងជនជាប់ឃុំ ដើម្បីធានាបានសន្តិសុខ សុវត្ថិភាព សុខភាព មនុស្សធម៌ អប់រំកែប្រែ ឈានទៅធ្វើសមាហរណកម្មក្នុងសង្គម មានភាពងាយស្រួល និងប្រឈមអ្វីខ្លះ? ដោយមានការដឹកនាំពី ឯកឧត្តម **ប៉ារ ហមផាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាប្រធាន អ្នកចូលរួមចំនួន**៣៥**នាក់ ស្រី០៤នាក់។(៣)កិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកផែនការសកម្មភាពការងារឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី(ក.ជ.ក.ស) ដែលប្រព្រឹត្តទៅនៅវិមានសន្តិភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។(៤)កិច្ចប្រជុំដើម្បីត្រៀមរៀបចំឯកសារសម្រាប់ទៅចូលរួមកិច្ចប្រជុំ COMMIT Regional Taskforce Meeting និង COMMIT Senior Officials Meeting(SOM13) នៅខេត្តជាំងស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាព លោកជំទាវ **សាន្ត អរុណ** រដ្ឋលេខាធិការក្រសួងកិច្ចការនារី នៅទីស្តីការក្រសួងកិច្ចការនារី។(៥)កិច្ចពិភាក្សាស្តីពី ការងារប្រព័ន្ធទិន្នន័យ Database ក្នុងការកែលម្អលើបច្ចេកទេសទៅលើគេហទំព័រ ក៏ដូចជាកែសម្រួលទៅលើព័ត៌មានផ្សេងៗ ដែលក្នុងនោះមានការចូលរួមពីតំណាងអង្គការវីនរ៉ក់ និងសម្ព័ន្ធចាប់ដៃ។(៦)វគ្គបណ្តុះបណ្តាលសម្រាប់ថ្នាក់ដឹកនាំជាស្ត្រី ក្រោមប្រធានបទ **"Women's Leadership: A Catalyst for Gender Equality and Inclusive Growth"** ដែលប្រព្រឹត្តទៅនៅសណ្ឋាគារ Raffles Hotel Le Royal ក្រោមកិច្ចសហការ ក្រសួងកិច្ចការនារី ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលមានសមាសភាព ចូលរួមជាស្ត្រី និងបុរសថ្នាក់ដឹកនាំមកពីក្រសួងចំនួន៩ (ស្រី **២៣**នាក់ ប្រុស **០១**នាក់)។(**៧**)ដឹកនាំប្រជុំក្រុមការងារស្តីពី វឌ្ឍនភាពការងារដែលសម្រេចបាននៅចុងឆ្នាំ២០១៩ និងទិសដៅសម្រាប់អនុវត្តសម្រាប់ឆ្នាំ២០២០។(៨)កិច្ចពិភាក្សាត្រៀមចូលរួមកិច្ចប្រជុំទ្វេភាគីស្តីពី៖ ការត្រួតពិនិត្យឡើងវិញនូវការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគីរវាងកម្ពុជា និងវៀតណាម អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ **ហ៊ូ សាមិត្ត** រដ្ឋលេខាធិការក្រសួងកិច្ចការនារី នៅសាលប្រជុំទីស្តីការក្រសួងកិច្ចការនារី (ចំនួន ០២លើក)។(៩)សិក្ខាសាលាតាមដាន លើកម្មវិធីបង្កើតចំណេះដឹងរួមគ្នា ដើម្បីលើកកម្ពស់ទំនាក់ទំនងរវាងបណ្តាប្រទេសអាស៊ាន ក្នុងការប្រឆាំងអំពើជួញដូរមនុស្សនៅការិយាល័យ JICA ប្រចាំនៅកម្ពុជា។(១០)អញ្ជើញចូលរួមវគ្គបណ្តុះបណ្តាលស្តីពី៖ "ការធ្វើអាជីវកម្មផ្លូវភេទលើកុមារ" ដែលរៀបចំដោយ ស្ថានទូតអូស្ត្រាលី នៅសណ្ឋាគារសូហ្វីតែល ភូកេត្រា។(១១)កម្មវិធីយុទ្ធនាការនារីវ័យក្មេងឆ្ពោះទៅរកភាពជាអ្នកដឹកនាំ#Girl2Leader Cambodia នៅវិមានរដ្ឋសភា ក្រោមអធិបតីភាពលោកជំទាវ កិត្តិសង្គហបណ្ឌិត **ឃួន ដាវី** អនុប្រធានទី២ រដ្ឋសភា។(**១២**)កិច្ចប្រជុំក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រុមការងារខមីតកម្ពុជា ស្តីពីការពិនិត្យ និង ពិភាក្សាលើរបាយការណ៍វឌ្ឍនភាពរយៈពេល១០ខែ ឆ្នាំ២០១៩ ដើម្បីធ្វើជូនទៅ គ.ជ.ប.ជ និងរបាយការណ៍ពីស្ថានភាពបច្ចុប្បន្ននៃអំពើជួញដូរមនុស្សនៅកម្ពុជា ដើម្បីកំណត់បញ្ហាប្រឈមថ្មី និងលើកទិសដៅបន្តឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ **ហ៊ូ សាមិត្ត** |

រដ្ឋលេខាធិការក្រសួងកិច្ចការនារី អ្នកចូលរួមចំនួន**៣៨**នាក់ ស្រី**១៨**នាក់ ទៅសាលប្រជុំទីស្តីការក្រសួងកិច្ចការនារី។(**១៣**)កិច្ចប្រជុំស្តីពីការណែនាំកម្មវិធី និងសិក្ខាសាលាពិគ្រោះយោបល់ជាមួយដៃគូនៃកម្មវិធីអាស៊ាន «អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស នៃព្រះរាជាណាចក្រកម្ពុជា» នៅសាលប្រជុំសណ្ឋាគារភ្នំពេញ។

- **ប្រធានក្រុមជំនួយកិច្ចការ** និងមន្ត្រីបច្ចេកទេសចំនួន ០២រូបបានចូលរួម៖

○ (១)សិក្ខាសាលាវាយតម្លៃទៅលើគម្រោងពង្រឹងកិច្ចអន្តរាគមន៍ ទៅលើពលករខ្មែរមុននឹងធ្វើចំណាកស្រុក ដែលត្រូវបានរៀបចំដោយអង្គការ VARITE។(**២**)កិច្ចប្រជុំពិនិត្យ ពិភាក្សា និងត្រៀមរៀបចំឯកសារសម្រាប់ទៅចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីត លើកទី១៣ និងពិនិត្យមើលឡើងវិញនូវសកម្មភាពស៊ើបអង្កេតរួមគ្នារវាងប្រទេសសមាជិកទាំង៦ COMMIT Regional Taskforce Meeting និង COMMIT Senior Officials Meeting(SOM13) នៅខេត្តជាំងស៊ី នៃសាធារណៈរដ្ឋប្រជាមានិតចិន ក្រោមអធិបីភាពលោកជំទាវ **សាន្ត អរុណ** រដ្ឋលេខាធិការ នៅក្រសួងកិច្ចការនារី។(**៣**)ធ្វើបទបង្ហាញ ស្តីពីរបាយការណ៍ជួញដូរមនុស្សនៅប្រទេសកម្ពុជា ក្នុងកិច្ចប្រជុំរបស់អង្គការសម្ព័ន្ធចាប់ដៃ នៅមជ្ឈមណ្ឌលពាក់ព័ន្ធកិច្ចឯកភាពគ្រីស្ទបរិស័ទ ភ្នំពេញ (ICF) រាជធានីភ្នំពេញ។(**៤**)កិច្ចប្រជុំត្រៀមលើប្រធានបទសិទ្ធិមនុស្ស សិទ្ធិនយោបាយ និងបរិស្ថានសង្គមស៊ីវិល ក្នុងកិច្ចប្រជុំនឹងធ្វើការពិភាក្សាពីរបៀបវារៈទម្រង់នៃបទអន្តាគមន៍ និងការងារ ពាក់ព័ន្ធមួយចំនួននៅទីស្តីការក្រសួងមហាផ្ទៃ។(**៥**)កិច្ចប្រជុំក្រុមការងាររៀបចំផែនការបណ្តុះបណ្តាលក្នុងក្របខណ្ឌ កិច្ចសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃកម្ពុជា ជាមួយភាគីចិន រុស្ស៊ី កូរ៉េ និង ឥណ្ឌា នៅទីស្តី ការក្រសួងមហាផ្ទៃ។(**៦**)វគ្គបណ្តុះបណ្តាលស្តីពី "**កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ**" ក្រោមអធិបតីភាព លោកជំទាវ **ខៀវ បូរី** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។(**៧**)វគ្គបណ្តុះបណ្តាល ស្តីពីសេវាប្រកបដោយគុណភាពសមស្រប និងគុណភាពសម្រាប់ពលករទេសន្តរប្រវេសន៍ជាស្ត្រី ដែលទទួលរងអំពើហិង្សា រៀបចំដោយអង្គការ UN Women អ្នកចូលរួមចំនួន**៦៣**នាក់ ស្រី**៣៧**នាក់។(**៨**)ធ្វើបទបង្ហាញមួយស្តីពីគម្រោងគ្រប់គ្រងទិន្នន័យនៃការផ្តល់សេវា និងការបញ្ជូន នៅក្នុងវគ្គសិក្ខាសាលាសេវាសង្គមកិច្ចផ្ទាល់នៅកម្ពុជា សិក្ខាសាលានេះមានអ្នកចូលរួមចំនួន **១៣០**នាក់ ស្រី**៥៨**នាក់ មកពីក្រសួង មន្ទីរពាក់ព័ន្ធ អង្គការជាតិ អង្គការអន្តរជាតិ និងគ្រឹះស្ថានអប់រំ ដែលប្រព្រឹត្តិទៅនៅមជ្ឈមណ្ឌល អាយ ស៊ី អែហ្វ។(**៩**)វគ្គបណ្តុះបណ្តាលស្តីពី "ការថែទាំដោយមានការយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត" រៀបចំដោយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) កម្ពុជា ដែលប្រព្រឹត្តិទៅនៅភោជនីយដ្ឋាន ទន្លេបាសាក់២។(**១០**)ដឹកនាំមន្ត្រីបច្ចេកទេសលេខាធិការដ្ឋាន គ.ជ.ប.ជ ចុះទៅបំពេញបេសសកម្មនៅទីក្រុងប៉ោយប៉ែត ដើម្បីធ្វើការសិក្សាពីតម្រូវការបច្ចេកទេសផ្នែកព័ត៌មានវិទ្យា សម្រាប់កសាងប្រព័ន្ធ Database នៅមណ្ឌលសំចតសម្រាប់ទទួលពលករ។(**១១**)ដឹកនាំមន្ត្រីក្រុមការងារបច្ចេកទេសគ្រប់គ្រងព័ត៌មានវិទ្យានៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចុះទៅមណ្ឌលសំចតពលករប៉ោយប៉ែត ដើម្បីធ្វើបច្ចុប្បន្នភាពការងារទាក់ទងនឹងប្រព័ន្ធគ្រប់គ្រងពលករ និងធ្វើការដោះស្រាយទៅលើបញ្ហាប្រឈមផ្សេងៗ។(**១២**)ដឹកនាំមន្ត្រីក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ប្រជុំជាមួយក្រុមការងារខមមីតកម្ពុជា ដែលដឹកនាំដោយលោកជំទាវ **ហ៊ូ សាមិត្ត** រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី អ្នកចូលរួមចំនួន **២៥**នាក់ ស្រី**១០**នាក់ នៅទីស្តីការក្រសួងកិច្ចការនារី។

▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**

(១)លិខិតរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖ លិខិតចេញ ចំនួន **១៧២**ច្បាប់ និងលិខិតចូល ចំនួន **៧៩**ច្បាប់។(**២**)លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ចំនួន **៩៧**ច្បាប់ លិខិតចូល ចំនួន **៩៩**ច្បាប់។(**៣**)ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន រាជធានី-ខេត្ត និង

| | |
|---|---|
| | បូកសរុបរបាយការណ៍ ប្រចាំខែ និងរបាយការណ៍ត្រីមាស ឆមាស និងប្រចាំឆ្នាំ របស់ គ.ជ.ប.ជ។(៤)រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។(៥)ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវីគី(wiki)។(៦)ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។<br>(៧)ស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា Convert ជា PDF បានចំនួន **៧០**ច្បាប់ និងបានចងក្រងជាសៀវភៅដាក់ជូនលោកជំទាវរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងលោកជំទាវឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ។(៨)បោះពុម្ពសៀវភៅភ្នាក់ងារជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករ ពលការិនី ទៅធ្វើការស្របច្បាប់នៅក្រៅប្រទេស ដាក់ជូនលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ និងលោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ។<br>(៩)Scan & Uploaded ឯកសារចូលក្នុងបណ្ណាសារនៃប្រព័ន្ធវីគី(wiki) បានចំនួន **៧៨**ច្បាប់។(១០)អាប់ឡូតរូបភាពសកម្មភាពចូលក្នុងប្រព័ន្ធអ៊ីនធើណែតក្នុងបណ្ណាល័យវីគី(wiki)គ.ជ.ប.ជ បានចំនួន **១៤០**សកម្មភាព។(១១) អាប់ឡូតព័ត៌មានចូលគេហទំព័រ គ.ជ.ប.ជ ធ្វើលិខិតថ្លែងអំណរគុណជូនដល់អង្គការ ក្រុមហ៊ុន ស្ថាប័នរដ្ឋ ស្ថានីយ៍ទូរទស្សន៍ តារាចម្រៀង ដែលបានចូលរួមសហការរៀបចំទិវាជាតិ ១២ធ្នូ ខួបលើកទី១២ ឆ្នាំ២០១៨។(**១២**)កែសម្រួលលើមាតិកាក្នុង Project: terms.ncct.gov.kh និងបកប្រែខ្លឹមសារនៅក្នុង keyword ដែលអង្គការវីនរ៉ក់ផ្តល់អោយ និងដាក់ Keyword ទៅក្នុងវីគី(wiki) terms.ncct.gov.kh សម្រាប់ផ្តល់ភាពងាយស្រួលទាញយកមកប្រើប្រាស់ពេលក្រោយ។(**១៣**)ដោះស្រាយបញ្ហា Error មួយចំនួននៅក្នុង terms.ncct.gov.kh និងត្រួតពិនិត្យមើលការងារទូទៅនៅក្នុង wiki.ncct.gov.kh។ (១៤)ចុះបេសកម្មទៅកាន់ក្រុងប៉ោយប៉ែតដើម្បីធ្វើការសិក្សាពីតម្រូវការផ្ទែកព័ត៌មានវិទ្យាសម្រាប់កសាងប្រព័ន្ធ Database នៅមណ្ឌលសំចត សម្រាប់គ្រប់គ្រងព័ត៌មាន លំហូរទេសន្តរប្រវេសន៍។(**១៥**)លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១៥ច្បាប់ លិខិតចូល ១៦ច្បាប់។(**១៦**) លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១៦ច្បាប់ លិខិតចូល ០៧ច្បាប់។(**១៧**)រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។(**១៨**)បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ ខែ និងឆ្នាំ២០១៩ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។(**១៩**)បូកសរុបរបាយការណ៍ខែ និងឆ្នាំ២០១៩ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។(**២០**)ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។(**២១**)រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។(**២២**)ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវីគី។(**២៣**)ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។(**២៤**)Scan & Uploaded ឯកសារចូលក្នុងបណ្ណាសារនៃប្រព័ន្ធ wiki បានចំនួន ១៧ច្បាប់។(**២៥**)អាប់ឡូតរូបភាពសកម្មភាព គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធអ៊ិនធើណេត wiki បានចំនួន ១៧សកម្មភាព។(**២៦**)លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ៣១ច្បាប់ លិខិតចូល ០៥ច្បាប់។(**២៧**)លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ០៧ច្បាប់ លិខិតចូល ១១ច្បាប់។(**២៨**)រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។(**២៨**)រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។(**២៩**)ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវីគី។(**៣០**)ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅ |

| | |
|---|---|
| | ក្នុងបណ្ដាញសង្គម និងគេហទំព័រនានា។(៣១)Scan & Uploaded ឯកសារចូលក្នុងបណ្ណាសារនៃប្រព័ន្ធ wiki បានចំនួន ៥១ច្បាប់។(៣២)អាប់ឡូតរូបភាពសកម្មភាព គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធអ៊ិនធើណេត wiki បានចំនួន ២៦សកម្មភាព។ |
| | **ក្រសួង ស្ថាប័ន សម្របសម្រួលចំនួន ៦២លើក អ្នកចូលរួមសរុបចំនួន ១២.៤៣២នាក់ (ស្រី ៥២១នាក់)** |
| **ក្រសួងអប់រំ យុវជន និងកីឡា** | - បានចូលរួមកិច្ចប្រជុំ និងសិក្ខាសាលា ៖ (១) ស្ដីពីការពិភាក្សារកវិធានការលើការគ្រប់គ្រងលំហូរពលករកម្ពុជា( លំហូរចេញ-លំហូរចូល )អំឡុងពេលពិធីចូលឆ្នាំប្រពៃណីជាតិខ្មែរ អ្នកចូលរួមចំនួន ២២ ស្រី ០៤នាក់។(២)អន្តរក្រសួង ស្ដីពីការរៀបចំផែនសកម្មភាពការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស២០១៩-២០១៣។ (៣)ស្ដីពីការប្រឹក្សាយោបល់លើការវាយតម្លៃពាក់កណ្ដាលគម្រោងនៃការអនុវត្តផែនការសកម្មភាពតំបន់អាស៊ានស្ដីពីការលុបបំបាត់អំពើហិង្សាលើកុមារ។(៤) ប្រចាំត្រីមាសទី១ ឆ្នាំ២០១៩ របស់ក្រុមការងារការពារជនរងគ្រោះ។(៥)ដើម្បីពិភាក្សាលើដំណើរការការអនុវត្តកម្មវិធីសហប្រតិបត្តិការកម្ពុជា-អូស្ត្រាលីក្នុងការផ្ដល់សេវាជួយដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រប្រកបដោយចិរភាព និងសមធម៌ ACCESS នៅសណ្ឋាគារកាំបូឌីយ៉ាណា។(៦)រៀបចំលិខិតគាំទ្រគម្រោងកម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលរៀបចំឡើងដោយអង្គការវីនរ៉ក់អន្តរជាតិ។(៧)ស្ដីពីការពិភាក្សារកវិធានការលើការគ្រប់គ្រងលំហូរពលករកម្ពុជា( លំហូរចេញ-លំហូរចូល )អំឡុងពេលពិធីចូលឆ្នាំប្រពៃណីជាតិខ្មែរ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។(៨)ពិភាក្សា ពិនិត្យលទ្ធផល និងការផ្ដល់ពិន្ទុ នៃការវាយតម្លៃសកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជូនរាជធានី ខេត្ត សម្រាប់ឆ្នាំ២០១៨ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។(៩)ស្ដីពីការប្រឹក្សាយោបល់លើការវាយតម្លៃពាក់កណ្ដាលគម្រោង នៃការអនុវត្តន៍ផែនការសកម្មភាពតំបន់អាស៊ាន ស្ដីពីការលុបបំបាត់អំពើហិង្សាលើកុមារ នៅសណ្ឋាគារកាំបូឌីយ៉ាណា។(១០)អន្តរក្រសួងស្ដីពី"ក្រុមប្រទេសបញ្ជូនកម្ពុជា ឡាវ ភូមា ដើម្បីពិភាក្សាអំពីបញ្ហារួម និងដំណោះស្រាយរួម នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។(១១)ប្រចាំត្រីមាសទី១ ឆ្នាំ២០១៩ របស់ក្រុមការងារការពារជនរងគ្រោះ នៅទីស្ដីការក្រសួងសង្គមកិច្ច។(១២)ផ្សព្វផ្សាយរបាយការណ៍ជាតិការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ នៅក្រសួងមហាផ្ទៃ។(១៣)រៀបចំលិខិតលេខ១៨៥៤ អយក.នក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ ស្ដីពីការស្នើសុំសមាសភាពថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ដើម្បីធ្វើបច្ចុប្បន្នភាពក្រុមបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស។(១៤)ពិភាក្សាអំពីទស្សនកិច្ចរបស់ប្រតិភូថៃ ជានាយកសាលា និងគ្រូបង្រៀន ១៣សាលារៀនពីប្រទេសថៃ ដោយមានកិច្ចសហការពីអង្គការមូលនិធិបណ្ដាញលើកកម្ពស់សិទ្ធិពលកម្ម(LPN) និងអង្គការ(Plane )អន្តរជាតិ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។(១៥)ស្ដីពីទស្សនកិច្ចរបស់ប្រតិភូថៃ ជានាយកសាលា និងគ្រូបង្រៀន ដែលមកពីខេត្តត្រាត និងខេត្តរ៉ាក់យ៉ង ដើម្បីស្វែងយល់ពីវិស័យអប់រំ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងវប្បធម៌ជាតិ នៅក្រសួងមហាផ្ទៃ អាគារ ១ ។(១៦)ក្នុងការផ្ដល់ព័ត៌មានជាមួយក្រុមការងារសិក្សាស្រាវជ្រាវស្ដីពី "កម្ពុជាការជួញដូរកុមារ នៅការិយាល័យនីតិកម្ម ។(១៧)ពិភាក្សា សម្រេចលើផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរយៈពេល០៥ឆ្នាំ ២០១៩-២០២៣ នៅក្រសួងមហាផ្ទៃ អាគារ ១ ។(១៨)រៀបចំលិខិតបញ្ជូនសមាសភាព ដើម្បីចូលរួមជាសមាជិកក្រុមការងារកម្ពុជាប្រឆាំងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គហៅកាត់ថា "ក្រុមការងារខេមមីតកម្ពុជា" នៅក្រសួងកិច្ចការនារី។(១៩)សិក្ខាសាលា ពិនិត្យសម្រេចលើលទ្ធផលនៃការសិក្សាអំពីសេវាសង្គម ដើម្បីលើកកម្ពស់ការឆ្លើយតបទៅនឹងផលប៉ះពាល់លើកុមារក្នុងទេសន្តរប្រវេសន៍ នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។(២០)ពិនិត្យ សម្រេច និងផ្ដល់ធាតុចូលបន្ថែមទាក់ទងនឹងការអនុវត្តសេចក្ដីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ៧២/២៩៥ ស្ដីពីការធ្វើឱ្យប្រសើរឡើងនូវកិច្ចប្រឹងប្រែង សម្របសម្រួលក្នុង |

| | |
|---|---|
| | ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។(២១)ក្នុងការប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិ គ.ជ.ប.ជ។** |
